CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែកក្កដា ឆ្នាំ២០១៧ លក់តម្លៃ ១០០០រៀល

លេខ ១០៤




# ពលរដ្ឋកម្ពុជា ៖ អាជ្ញាធរគួរតែយកចិត្តទុកដាក់រឿងការអនុញ្ញាតច្បាប់ឲ្យប្រើប្រាស់ទ្រូងផ្លូវធ្វើពិធីផ្សេងៗ

ថតដោយ លីហៀង

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# មន្ត្រីរាជការ ប្រជាពលរដ្ឋ អបអរសាទរប្រាសាទសំបូរព្រៃគុក បានចូលជាបេតិកភណ្ឌពិភពលោក

គ្រប់ក្រសួងស្ថាប័ន មន្ត្រីរាជការ ព្រះសង្ឃ និងប្រជាពលរដ្ឋកម្ពុជា នៅទូទាំងប្រទេសបាននាំគ្នាប្រារព្ធពិធីទូងស្គរ ដើម្បីប្រកាសជាសញ្ញាអបអរសាទរ ប្រាសាទសំបូរព្រៃគុក ដែលបានចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែង របស់រាជរដ្ឋាភិបាល ក្នុងការព្យាយាមតស៊ូមតិដាក់សម្បត្តិវប្បធម៌បុរាណនេះ ឱ្យពិភពលោកចូលរួម ថែរក្សាសម្រាប់មនុស្សលោកនាជំនាន់ក្រោយៗ។

ក្នុងពិធីរៀបចំអបអរសាទរប្រាសាទសំបូរព្រៃគុក ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក នាព្រឹកថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកឧត្តម ជុច ភឿន រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈ បានមានប្រសាសន៍ថា ប្រទេសកម្ពុជាកាន់តែមានកិត្តិយស និងមានកម្លាំងបន្ថែមទៀត ក្នុងការថែរក្សាការពារអភិរក្ស និងអភិវឌ្ឍន៍ប្រាសាទដែលប្រជុំទៅដោយប្រាសាទតូចៗច្រើនទៀតទាំងនៅលើដី និងកប់ក្នុងដី។

ឯកឧត្តមបានបញ្ជាក់ថា អង្គការយូណេស្កូ បានសម្រេចចុះបញ្ជីប្រាសាទសំបូរព្រៃគុករបស់ប្រទេសកម្ពុជា ជាបេតិកភណ្ឌពិភពលោក នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ នាសម័យប្រជុំលើកទី៤១ នៃគណៈកម្មការបេតិកភណ្ឌពិភពលោក ដែលមានប្រទេស ជាសមាជិក១៩៣ ចូលរួម នាទីក្រុង ក្រាកូវ(Krakow) ប្រទេសប៉ូឡូញ។

ឯកឧត្តមបានបន្តថា អង្គការយូណេស្កូបានសម្រេចនូវលក្ខណៈ វិនិច្ឆ័យចំនួន៣ក្នុងចំណោមលក្ខណៈ សម្បត្តិចំនួន៦ ដែលកម្ពុជាបានស្នើសុំចុះបញ្ជីបេតិកភណ្ឌពិភពលោក ក្នុងនោះមានដូចជា ភាពល្អឯកនៃតួប្រាសាទ អាយុកាលនៃប្រាសាទ រចនាបថតួប្រាសាទ គុណតម្លៃនៃភាពលេចធ្លោនៅក្នុងតំបន់ជាដើម។

ដោយឡែក ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានសម្ដែងនូវការចូលរួមអបអរសាទរយ៉ាងកក់ក្ដៅបំផុត ប្រកបដោយសេចក្ដីសោមនស្សរីករាយ ដែល "តំបន់ប្រាសាទសំបូរព្រៃគុក" ត្រូវបានសម្រេចអនុម័តបញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង ២១:៣៧នាទី (ម៉ោងនៅកម្ពុជា) តាមសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងឱកាសកិច្ចប្រជុំកំពូលលើកទី៤១ នៃគណៈកម្មការបេតិកភណ្ឌពិភពលោក នៅទីក្រុង Krakow ប្រទេសប៉ូឡូញ។

ការសម្រេចរបស់គណៈកម្មការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូនេះ គឺជាមោទនភាពជាតិដ៏ធំធេងមួយថ្មីបន្ថែមទៀត ដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ ក្នុងការលើកស្ទួយកិត្យានុភាពជាតិ និងកិត្តិយសជាតិនៅលើឆាកអន្តរជាតិ ហើយជាការឆ្លុះបញ្ចាំង អំពីការយកអស់កម្លាំងកាយចិត្តក្នុងការគ្រប់គ្រង ការពារអភិរក្ស និងអភិវឌ្ឍន៍បេតិកភណ្ឌជាតិប្រកបដោយចីរភាព។ នេះក៏ជាការទទួលស្គាល់របស់ពិភពលោកទាំងមូល លើគតម្លៃជាប្រវត្តិសាស្ត្ររបស់តំបន់ប្រាសាទសំបូរព្រៃគុកនេះដែលញ៉ាំងទឹកចិត្តយើងទាំងអស់គ្នាចូលរួមថែរក្សាតំបន់នេះឱ្យបានល្អផូរផង់ សម្រាប់កូនចៅកម្ពុជាជំនាន់ក្រោយនិងសម្រាប់មនុស្សជាតិទាំងអស់។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើតគណៈកម្មការអន្តរក្រសួងមួយដើម្បីរៀបចំពិធីអបអរសាទរចំពោះការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុកទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧កន្លងទៅនេះ ដើម្បីបង្ហាញអំពីមោទនភាព នៃសម្បត្តិវប្បធម៌ខ្មែរ។

ក្នុងសេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីអបអរសាទរការបញ្ចូល តំបន់ប្រាសាទសំបូរព្រៃគុកក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពី ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ដែលចុះហត្ថលេខាដោយសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ កម្ពុជា ដោយបានចាត់តាំងឱ្យឯកឧត្តម ប៊ុន ឈិន ឧបយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្ដីទីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ធ្វើជាប្រធាន និងលោកជំទាវ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាអនុប្រធាន ដើម្បីដឹកនាំរៀបចំព្រឹត្តិការណ៍អបអរសាទរ ចំពោះតំបន់ប្រាសាទ សំបូរព្រៃគុក ក្រោយពីគណៈកម្មាធិការបេតិកភណ្ឌពិភពលោកបានសម្រេចចុះក្នុង បញ្ជីបេតិកភណ្ឌពិភពលោក។

ក្នុងសេចក្ដីសម្រេចនេះ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចឱ្យគណៈកម្មការអន្តរក្រសួងដើម្បីដឹកនាំ និងសម្របសម្រួលដំណើរការការងារ រៀបចំអបអរសាទរការបញ្ចូលតំបន់ប្រាសាទសំបូរព្រៃគុក ក្នុងបញ្ជីបេតិកភណ្ឌពិភពលោកដោយធ្វើការចាត់ចែងត្រួតពិនិត្យសម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

ការរៀបចំខ្លឹមសារ ឯកសារ លិខិតបទដ្ឋានរដ្ឋបាល បដា ពាក្យស្លោក និងបោះពុម្ពអាវសម្រាប់ពិធីរៀបចំគម្រោងចំណាយនៃដំណើរការរៀបចំពិធី រៀបចំទម្រង់សិល្បៈ ទស្សនីយភាព និងការសម្ដែងនានាក្នុងព្រឹត្តិការណ៍ ការពារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសង្គ្រោះបន្ទាន់ រៀបចំការពារសន្តិសុខ របៀបរៀបរយការពារសណ្ដាប់ធ្នាប់ចរាចរ និងធានាសុវត្ថិភាពឱ្យបានគ្រប់គ្រាន់នៅមុន និងក្រោយពេលប្រារព្ធពិធី និងតាមផ្លូវឆ្លងកាត់ទំនាក់ទំនង និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចស្ថាប័នពាក់ព័ន្ធក្នុងការអញ្ជើញភ្ញៀវជាតិនិងអន្តរជាតិចូលរួម។

សូមបញ្ជាក់ថា ការសម្រេចបញ្ចូល "ប្រាសាទសំបូរព្រៃគុក" ក្នុងបញ្ជីបេតិកភណ្ឌពិភពលោក នេះ ត្រូវបានធ្វើឡើងនៅក្នុងកិច្ចប្រជុំកំពូលលើកទី៤១នៃគណៈកម្មាធិការ បេតិកភណ្ឌពិភពលោក ដែលប្រារព្ធឡើងនៅពីថ្ងៃទី០២ ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ដែលមាន១៩៣ប្រទេសជា សមាជិក និង២១ប្រទេសជាគណៈកម្មាធិការអចិន្ត្រៃយ៍ បានសម្រេចអនុម័តបញ្ចូល "ប្រាសាទសំបូរព្រៃគុក" ជាសម្បត្តិបេតិកភណ្ឌពិភពលោក នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ នាទីក្រុងប្រទេសប៉ូឡូញ។

ជាមួយគ្នានេះដែរ ប្រាសាទសំបូរព្រៃគុក មានទីតាំងស្ថិតនៅក្នុងភូមិសំបូរ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដែលមានចម្ងាយ២៥គីឡូម៉ែត្រ ពីទីរួមខេត្តកំពង់ធំ តាម ផ្លូវជាតិលេខ៦៤។

ប្រាសាទសំបូរព្រៃគុកនេះ ជារាជធានីចាស់បុរាណឈ្មោះថាឦសានបុរៈ ដែលកាលពីសម័យនោះ ជាមជ្ឈមណ្ឌលនៃសាសនា ដ៏សំខាន់ក្នុង សង្គមមុនអង្គរ និងសម័យអង្គរ ឧទ្ទិសថ្វាយដល់សិវៈនិយម។ ក្រុមប្រាសាទនេះសាងសង់អំពីឥដ្ឋតាន់ថ្មបាយក្រៀម និងថ្មភក់ ដែលលម្អលើជញ្ជាំងប្រាសាទ ហើយត្រូវបានកសាងឡើងនៅរជ្ជកាល ព្រះបាទឦសាន វរ្ម័នទី១ក្នុងសតវត្សរ៍ទី៧ ដែលមានប្រាសាទប្រមាណជាង១០០ប្រាសាទ ចែកចេញជា៤ក្រុមធំៗ។

បច្ចុប្បន្ន មានសំណល់បុរាណពីអតីតរាជធានី ដែលមានអាយុ កាលជាង៥០០ឆ្នាំ និងហ៊ុមព័ទ្ធទៅដោយទេសភាពព្រៃឈើប្រមាណ៣.០០០ហិកតានេះ បានបន្សល់កេរដំណែលដូចជាប្រាសាទឥដ្ឋ កសិណទឹក កំពែង សំណង់ធារាសាស្ត្រ សម្រាប់ការប្រើប្រាស់ និងជំនឿសាសនា៕ ដោយ សុផានិត



# អ្នកមានចំណូលទាបកំពុងតែរស់នៅឆ្ងាយពីក្តីសង្ឃឹមចង់បានលំនៅដ្ឋាននៅតាមទីក្រុង

ខណៈដែលសំណង់ជាច្រើនកំពុងតែសាងសង់ឡើងព្រោងព្រាតនៅតាមទីប្រជុំជននានា ជាពិសេសគឺនៅរាជធានីភ្នំពេញ បណ្តាអ្នកដែលមានចំណូលទាប បានបង្ហាញនូវក្តីអស់សង្ឃឹមចំពោះ លទ្ធភាពនៅក្នុងការទទួលបាននូវផ្ទះសមរម្យមួយដើម្បីស្នាក់នៅនឹងគេ។

លី ចម្រើន ដែលជាអ្នករត់ម៉ូតូកង់បីមួយរូបនៅរាជធានីភ្នំពេញ បានថ្លែងថា មើលទៅមួយជាតិនេះ លោក និងគ្រួសារប្រហែលជាត្រូវនៅក្នុងផ្ទះជួលមួយជីវិតហើយ ដោយសារតែមិនមានលទ្ធភាព ដើម្បីស្វែងរកទ្រនំដែលសមរម្យនឹងគេបាន។

លោកបានបន្តថា នៅក្នុងឋានៈជាមនុស្សដែលមានកម្រិតប្រាក់ចំណូលមិនច្រើន ដូចជាពួកគាត់ គឺប្រហែលជារកមិនបានទេ នូវលុយសម្រាប់ទិញផ្ទះរស់នៅសមរម្យនឹងគេ ដោយសារតែចំណូល ដែលរកបាន គឺបានត្រឹមតែមួយគ្រប់សម្រាប់ថ្លៃជីវភាពតែប៉ុណ្ណោះ ។ លោកបានបន្តថា មួយថ្ងៃរកបានត្រឹម ៤០.០០០រៀល ឬ ១០ ដុល្លារ ហើយប្រពន្ធធ្វើការរោងចក្រប្រាក់ខែ ថែមម៉ោងផងអីផង បានត្រឹម ២០០ ដុល្លារ គឺបានចំណូលមក គ្រាន់តែទប់នឹងជីវភាព គឺថ្លៃស្នាក់នៅជួលផ្ទះ ថ្លៃទឹក ថ្លៃភ្លើង កូនរៀន និងថ្លៃម្ហូបអាហារ ចុះនៅផាត់ថ្លៃសាំង និងថ្លៃម៉ូតូខូចទៀតនោះ។

ចម្រើនបានបញ្ជាក់ដោយបញ្ចេញដង្ហើមធំថា "លុយដូចជាច្រើនដែរ តែមួយខែៗរកអីមិនសល់សោះ ចាយមិនហ៊ានចាយផ្តេសផ្តាសទេណ្ហើយបង (អ្នកសារព័ត៌-មាន)! ទៅមានលុយឯណា សល់ទិញផ្ទះបើផ្ទះមួយល្វែង សុទ្ធតែ៤០.០០០ ទៅ៥០០.០០០ ដុល្លារ"។

ចម្រើនបានបញ្ជាក់ថា "ម៉ាខែៗកុំថាតែសល់ដល់ទៅ ១០០ ឬ២០០ដុល្លារ ត្រឹមតែ ៥០ក៏បានដែរ តែមានឯណាដល់ខែដាច់ខ្យល់ ខែខ្លះត្រូវខ្ចីគេចាយទៀតផង"។

ចម្រើនបានរៀបរាប់ថា នៅក្នុងមួយខែថ្លៃជួលផ្ទះគេ គឺ ៨០ ដុល្លារ ចុះនៅថ្លៃទឹកថ្លៃភ្លើងទៀតចូលជាង ១០០ដុល្លារ ចុះនៅអង្ករ ថ្ងៃម្ហូប កូនទៅរៀន ចំណូលដែលលោករកបានគឺគ្រប់ ហើយប្រាក់ខែប្រពន្ធគឺសម្រាប់ជួយថ្លៃព្យាបាលម្តាយនៅស្រុកដែលគាត់ត្រូវផឹករាល់ខែ។

លោក នៅ កេត្យា ជាបុគ្គលិកក្រុមហ៊ុនឯកជនមួយនៅក្នុងទីក្រុងភ្នំពេញក៏បានថ្លែងត្អូញត្អែរ អំពីការបាត់បង់នូវក្តីសង្ឃឹមថា នឹងអាចមានលទ្ធភាពស្វែងរកនូវទីជម្រកមួយបានសមរម្យនឹងគេនៅក្នុងទីក្រុងណាស់ ដោយសារតែ ទីលំនៅវាមានតម្លៃថ្លៃ។

លោក កេត្យា បានថ្លែងថា ផ្ទះល្វែង វីឡា ខុនដូ ត្រូវគេសាងសង់ច្រើនណាស់ ប៉ុន្តែមិនមែនសម្រាប់ គាត់និងអ្នកដែលមានប្រាក់ចំណូលទាប មួយខែរកប្រាក់បានត្រឹមតែមួយគ្រប់ៗសឹងពិបាកនោះទេ។

លោកបានបញ្ជាក់ថា "ខ្វះអីផ្ទះគេសង់លក់ ឲ្យព្រោងព្រាត ប៉ុន្តែខ្ញុំបានត្រឹមតែសម្លឹងមើលប៉ុណ្ណោះ ពីព្រោះបានលុយពីណាមកទិញ បើផ្ទះសុទ្ធតែរាប់ម៉ឺន ដុល្លារ រីឯខ្ញុំរកលុយខ្ទង់រយចង់យ៉ាប់ផងនោះហ៊ី"។

លោកបានបន្តថា ជាមួយនឹងប្រាក់ចំណូលដ៏តិចតួចស្តួចស្តើង នៅក្នុងនាមជាអ្នកបើកឡានឲ្យគេ គឺអាចមានលទ្ធភាពត្រឹមរស់នៅបន្ទប់ជួលមួយខែ ៤៥ ដុល្លារ ប៉ុណ្ណោះ ពីព្រោះលោកត្រូវសន្សំលុយ ទុកផ្ញើទៅចិញ្ចឹមប្រពន្ធកូននៅស្រុក។

លោកបានបញ្ជាក់ថា "ស្រមៃនោះវាស្រមៃហើយ ប៉ុន្តែខ្ញុំទាល់តម្រិះហើយ ដើម្បីរកក្តីសង្ឃឹមទៅ ធ្វើឲ្យក្តីស្រម័យនោះក្លាយជាការពិតបាននោះ"។

លោកស្រី ហេង ចំណាន ដែលជាអ្នកលក់បន្លែចល័តមួយរូប នៅក្នុងទីក្រុង ក៏មានក្តីស្រមៃចង់បាន ទីលំនៅសមរម្យនឹងគឺដែរ ប៉ុន្តែមិនដឹងពេលណាអាចបាននោះទេ។

លោកស្រី បានថ្លែងថា គ្មាននរណាចង់នៅផ្ទះជួលគេទេ ដោយសារតែបើកភ្នែកដាច់ខែ គេមកយកលុយស្រស់ៗ ប៉ុន្តែមិនដឹងធ្វើម៉េច បើយើងវាមានចំណូលទាប ។ លោកស្រីបានបន្តថា ជាមួយនឹងប្រាក់ចំណូលពីការលក់នេះ គឺអាចនឹងទប់ចំណាយថ្លៃជីវភាព និងការហូបចុកបានហើយ ប៉ុន្តែលុយនោះវាសល់តិចពេក។

លោកស្រីបានបញ្ជាក់ថា "ខ្ញុំរករាល់ថ្ងៃនេះសល់ដែរ តែសន្សំយ៉ាងណា គឺមិនចេះគ្រប់ទេ! ចេះតែមានតម្រូវការ ចេះតែមានហេតុផលដែលត្រូវចាយ "។

លោកស្រីបានថ្លែងថា កន្លងមកកាត់ធ្លាប់សាកល្បងទៅទាក់ទងខ្ចីធនាគារតាមរយៈកម្មវិធីកម្ចី ទិញផ្ទះនេះនឹងគេដែរ ប៉ុន្តែគេទាមទារថ្លៃ៣០ ភាគរយនៃថ្លៃផ្ទះនៅមុន ក៏ចេះតែហ៊ីៗខំសន្សំ ពីរនាក់ ប្តីប្រពន្ធមកដល់សព្វថ្ងៃនេះទៀតនោះ។

លោកស្រីបានបញ្ជាក់បន្ថែមថា "សន្សំចេះតែសន្សំទៅ តែតម្លៃផ្ទះចេះតែឡើងទៅៗដែរ អីចឹងមើលទៅមានតែនៅផ្ទះជួលនេះ ម៉ាជីវិតហើយ"។

លោកស្រីបានបន្តថា លុយសន្សំមិនដែលចេះគ្រប់ទេ វាចេះតែមានហេតុផលនេះហេតុផលនោះតែរហូត។ ជួលកាលទៅសន្សំៗឃើញដូចជាក្រៃល ស្រាប់តែឈឺ ហើយតែហ៊ានចូលពេទ្យទិញថ្នាំ ពេលខ្លះខ្ទង់រយដុល្លារក៏មានដែរ។

ទាក់ទិននឹងបញ្ហាទីលំនៅនេះ មន្ត្រីរាជការនៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈមួយរូប បានថ្លែងនៅ ក្នុងលក្ខខណ្ឌមិនចេញអត្តសញ្ញាណថា លោកក៏គ្មានសង្ឃឹមថា នឹងមានលទ្ធភាពទទួលបានផ្ទះស្នាក់នៅសមរម្យនឹងគេនោះពេលណាដែរ។

លោកបានបន្តថា កាលលោកនៅរៀនគឺស្នាក់នៅវត្ត ដល់ពេលមានការងារធ្វើចេញពីវត្តស្នាក់នៅ ផ្ទះជួលហើយទម្រាំសន្សំលុយបានគ្រប់ការប្រពន្ធនឹងគេមានអីជិតចូលដល់ពាក់កណ្តាលជីវិត។ លោកបានបន្តថា សព្វថ្ងៃនេះលោកក៏កំពុងតែស្វែងរកទ្រនំសមរម្យជាងផ្ទះជួលស្នាក់នៅនឹងគេដែរ ប៉ុន្តែខ្វះលទ្ធភាព។

លោកបានថ្លែងថា កាលពីប៉ុន្មានខែមុននេះពេល ឮថាក្រសួងរៀបចំដែនដីនគរូប-នីយកម្ម និងសំណង់សហការជាមួយនឹងខាងក្រុមហ៊ុនឯកជន និងអង្គការមួយចំនួនសាងសង់ផ្ទះតម្លៃថោក ជូនមន្ត្រីរាជការ និងអ្នកក្រីក្រ លោកខំតែសង្ឃឹមប៉ុន្តែមានអី គម្រោងនេះបានត្រឹមតែសង្ឃឹមប៉ុណ្ណោះ។

លោកបានបន្តថា ក្រោយពេលគេសម្ពោធបើកការដ្ឋាន គាត់បានប្រញាប់ប្រញាល់ជិះម៉ូតូទៅដល់ការដ្ឋានសាងសង់លំនៅឋានសាធារណៈ ដែលគេប្រកាសថាមានតម្លៃសមរម្យសម្រាប់គ្រួសារមន្ត្រីរាជការ រហូតដល់ ឃុំកោះខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ហួសផ្ទះសម្តេចនៅតាខ្មៅទៅទៀត ប៉ុន្តែមានអីគឺបានត្រឹមតែការខកចិត្តតែប៉ុណ្ណោះ ។

លោកបានបញ្ជាក់ថា "ពេលដែលទៅដល់ខាងបុគ្គលិកនៅទីនោះ គេពន្យល់ ថាផ្ទះនោះវាយ៉ាងម៉េចៗ ហើយគេតម្រូវឲ្យត្រូវតែស្នាក់នៅទីនោះរយៈពេល៥ឆ្នាំ។ ផ្ទះនោះមិនធំទេ គឺត្រឹមតែ៤ ម៉ែត្រគុណនឹង ១០ម៉ែត្រ ហើយខ្លះមានត្រឹម ៤ ម៉ែត្រគុណនឹង៧ ម៉ែត្រប៉ុណ្ណោះ ប៉ុន្តែដល់ពេលគេសួររឿងប្រាក់ចំណូល ជាប្រាក់ខែមន្ត្រីរាជការ គេប្រាប់ថា ចាំគេសិក្សាសិន ចាំគេទូរស័ព្ទមកប្រាប់វិញ ។

លោកបានបញ្ជាក់ថា "ចាំបាត់ចាំបាត់ខ្ញុំក៏តេ (ទំនាក់ទំនងតាមទូរស័ព្ទ) សួរគេទៅចម្លើយដែលបាន គឺថាអស់សង្ឃឹម"។ លោកអាចទិញផ្ទះនេះបាន គឺយ៉ាងហោចណាស់ក៏ត្រូវមានប្រាក់ចំណូលក្នុងគ្រួសារមួយខែ ៥០០ដុល្លារដែរ "ខ្ញុំគ្រាន់តែឮមានអីក្រៅពីអរគុណគេតែប៉ុណ្ណោះ "។

*ដោយ អរិយបុត្រ*



ថតដោយ រិទ្ធី

# ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិជិតមកដល់ តែសកម្មភាពសិស្សានុសិស្សហាក់មានភាពស្ងប់ស្ងាត់ក្នុងការសិក្សាគួរបន្ថែម



ថតដោយ លីហៀង

ការប្រឡងយកសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) កាន់តែហាក់កៀកជិតចូលមកដល់ តែសកម្មភាពសិស្សានុសិស្សតែកំពុងត្រៀមខ្លួនប្រឡងនោះហាក់មានសភាពស្ងប់ស្ងាត់ ក្នុងការស្វះស្វែងរកការសិក្សាគួរបន្ថែម ទាំងនៅតាមសាលារដ្ឋ និងសាលាឯកជន ដែលមានភាពផ្ទុយស្រឡះខុសប្លែក ពីបណ្ដាឆ្នាំសិក្សាកន្លងទៅ។

បើតាមលោកស្រី ឡា លីន ដែលជាអ្នកគ្រប់គ្រងសាលារៀន ជ័យដ្ឋារី បានឲ្យដឹងថា មកដល់ដំណាក់កាលនេះមិនទាន់មានសិស្សមករៀនច្រើននោះទេ។

លោកស្រី បានបន្ថែមថា ដោយសារតែសាលារដ្ឋ មិនទាន់បានប្រឡង បញ្ចប់នៅឡើយ (ប្រឡងឆមាសទី២) ដែលជាហេតុធ្វើឲ្យសិស្សមិនទាន់មករៀនច្រើន។

បើតាមការអះអាង របស់លោកស្រីបន្ថែមថា សិស្សដែលមករៀនបន្ថែមនៅទីនេះ មានលទ្ធភាពប្រឡងជាប់សញ្ញាបត្រច្រើនជាងគេ។

លោកស្រីបានបញ្ជាក់បន្ថែមថា លោកស្រីមើលឃើញថា ដោយសារតែពួកគាត់ (សិស្សានុសិស្ស) មិនទាន់បានប្រឡងឆមាសទី២ ជាហេតុកំណើននៃសិស្សរៀងមានច្រើន ដែលគាត់មកសិក្សារៀនគួរបន្ថែមនេះ។ ប៉ុន្តែមិនទាន់ច្រើនប៉ុន្មាននោះទេ រហូតដល់តែគាត់ប្រឡងឆមាសលើកទី២ ហើយថ្ងៃទី២៤ នឹងមានថ្នាក់រៀនត្រៀមប្រឡងវិញ្ញាសារ ទូរទាំងប្រទេសចឹងខ្ញុំគិតថា កូនសិស្សនឹងមករៀនច្រើនដែលមកពីតាមបណ្ដារខេត្តកាន់តែច្រើន។

លោកស្រី បានបន្ថែមថា សម្រាប់សិស្សដែលមករៀនបន្ថែមនៅទីនេះ លទ្ធផលដែលគាត់ប្រឡងគឺល្អ និទេសន្ត គឺបានល្អនិទេសន្ត A ភាគច្រើនជាពិសេសគឺសិស្សដែល រៀននៅវិទ្យាល័យបាក់ទូកមកប្រឹងប្រែងនៅទីនេះ ដែលសាលានេះមានគ្រូមានបទពិសោធច្រើន ហើយសាលានេះមានឈ្មោះយូរណាស់មកហើយ នឹងសិស្សភាគច្រើនក៏គាត់ទទួលស្គាល់ថា គាត់មករៀនបំពេញបន្ថែមនៅទីនេះ ឥលូវបើតាមខ្ញុំដឹង គឺគាត់បានដំណែងធំៗខ្លាំងណាស់។

ជាមួយគ្នានេះផងដែរ ប្អូនស្រីម្នាក់ដែលជាសិស្សវិទ្យាល័យ មកពីទីក្រុងភ្នំពេញដែលបានមករៀនគួរបំពេញបន្ថែមនៅទីនេះ បានអះអាងថា ពួកគេបានត្រៀមរួចជាស្រេចហើយ ទាំងការរៀនបំពេញបន្ថែម និងការរៀននៅតាមផ្ទះដើម្បីប្រឡងយកសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬការប្រឡងបាក់ឌុប នាពេលខាងមុខនេះ គឺជាប់តែម្ដង ដោយសារតែពួកគេគិតថា ក្រសួងអប់រំនៅតែរឹតបន្តឹង ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២១ សីហា ២០១៧ នេះនៅតែមានការរឹតបន្តឹងដដែល។

កញ្ញាលក្ខិណា បានថ្លែងថា នៅពេលខាងមុខដែលជាពេលប្រឡងនេះ គឺខ្ញុំបានខិតខំនៅផ្ទះខ្លួនឯង និងឧស្សាហ៍មករៀនគួរនៅទីនេះរួមទាំងរៀននៅតាមសាលារដ្ឋព្រមទាំងមើលសៀវភៅ។ នៅពេលមានវិញ្ញាសារអ្វី ខ្ញុំធ្វើវាព្រោះថាឆ្នាំនេះក្រសួងនៅរឹតបន្តឹងជាហេតុខ្ញុំស្វ័យសិក្សាខ្លួនឯងផង និងធ្វើវិញ្ញាសារអ្វីដែលគ្រូបានដាក់ឲ្យមកផង។ កញ្ញាបានបញ្ជាក់ថា ក្រសួងធ្វើការរឹតបន្តឹងនេះគឺដើម្បីធ្វើឲ្យយើងល្អ ណាមួយធ្វើនេះដើម្បីឲ្យចំនួនប្រជាជនយើង មានសមត្ថភាពកាន់តែខ្ពស់ទៅៗ ដូចប្រទេសគេដែរ។

បើតាមការគូសបញ្ជាក់ពី ឯកឧត្ដមបណ្ឌិត ហង្ស ជួនណារ៉ុន រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡាបានថ្លែងឲ្យដឹងនាពេលថ្មីៗនេះថា ការប្រឡងបាក់ឌុប ឬការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយ-ភូមិ ឆ្នាំ២០១៧នេះ គឺក្រសួងនៅតែមានការរឹតបន្តឹង ទៅលើគ្រប់មុខវិជ្ជា គឺមិនអនុញ្ញាតឲ្យសិស្សានុសិស្ស គ្រប់ប្រភេទដែលជាបេក្ខជន ប្រឡងមធ្យមសិក្សានេះ យកសំណៅឯកសារ ឬគ្រឿងអេឡិចត្រូនិចចូលក្នុងបន្ទប់ប្រឡងនោះទេ ប្រសិនបើមើលឃើញថា សិស្សដែលជាបេក្ខជនប្រឡង សញ្ញាបត្រធម្យមសិក្សានេះ យកសំណៅឯកសារចូល ក្រសួងនឹងឲ្យធ្លាក់ដោយស្វ័យប្រវត្តិ។

បច្ចុប្បន្ននេះ ការប្រឡងយកសញ្ញាបត្រធម្យមសិក្សាទុតិយភូមិនេះ មិនពិបាកក្នុងការស្វ័យសិក្សាឡើយ ដោយហេតុក្រសួង បានបង្កើតនៅកម្មវិធី អ៊ីឡើននីង (E-learning) ដែលក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនេះ សិស្សានុសិស្សអាចធ្វើការ តេស្តនៅសមត្ថភាពរបស់ខ្លួន តាមរយៈការដោះស្រាយនៅលំហាត់ផ្សេងៗ តាមរយៈមធ្យោ-បាយនេះក៏មានដែរ ដែលផ្ដល់ភាពងាយស្រួលច្រើនសម្រាប់សិស្សានុសិស្ស។

ការប្រឡងបាក់ឌុបឆ្នាំ២០១៧នេះ មានបេក្ខជនសរុបចំនួន ១០៣.១១២ នាក់ និងមានមណ្ឌលប្រឡងចំនួន ១៧៦ មណ្ឌលបែកចេញជា ៤.១៥៥ បន្ទប់ នៅរាជធានីខេត្តទាំង២៥។ លទ្ធផល នឹង ប្រកាសនៅតាមមណ្ឌលប្រឡងនីមួយៗ គឺនៅរសៀលថ្ងៃទី១២ កញ្ញា ២០១៧ សម្រាប់មណ្ឌលប្រឡងនៅរាជធានីភ្នំពេញ និងខេត្តកណ្ដាល និង នៅថ្ងៃទី ១៣ កញ្ញាឆ្នាំ២០១៧ សម្រាប់មណ្ឌលប្រឡងនៅខេត្តផ្សេងៗទៀត។

ចំពោះការប្រឡងមានការបែងចែកវិញ្ញា-សារជាពីរ គឺផ្នែកវិញ្ញាសាវិទ្យាសាស្ត្រ និងផ្នែកវិទ្យាសាស្ត្រសង្គម។ មុខវិជ្ជាវិទ្យាសាស្ត្រមាន ៧មុខវិជ្ជា ក្នុងនោះរួមមានអក្សរសាស្ត្រខ្មែរ គណិតវិទ្យា គីមីវិទ្យា រូបវិទ្យា ជីវវិទ្យាភាសាបរទេស (បារាំង អង់គ្លេស) និងវិញ្ញាសារទី៧ គឺជាមុខវិជ្ជាជ្រើសរើស មានបរិស្ថាន ភូមិវិទ្យា ផែនដីវិទ្យា សីលធម៌ពលរដ្ឋ។ ចំណែកមុខវិជ្ជា វិទ្យាសាស្ត្រសង្គម មាន អក្សរសាស្ត្រខ្មែរ គណិតវិទ្យាភូមិវិទ្យា ប្រវត្តិវិទ្យា សីលធម៌ ពលរដ្ឋភាសាបរទេស (បារាំង អង់គ្លេស) និងមុខវិជ្ជាទី៧ គឺមុខវិជ្ជាជ្រើសរើស មានគីមីវិទ្យា រូបវិទ្យា ផែនដីវិទ្យា និងបរិស្ថាន៕

*ដោយ សុផានិត*

# យុវជនក៏ចង់ឃើញសង្គមកម្ពុជានាំគ្នាគោរពច្បាប់ចរាចរណ៍ផ្លូវគោកដែរ !

យុវជននិងយុវនារីកម្ពុជាដែលកំពុងតែក្លាយជាទំពាំងទៅស្នងឫស្សីបណ្ដើរៗ និងនៅពេលអនាគតដ៏ខ្លីខាងមុខនេះ ក៏ចង់ឲ្យសង្គម កម្ពុជាមានការគោរពច្បាប់ចរាចរណ៍និងច្បាប់ឯទៀតឲ្យបានខ្ជាប់ខ្ជួនផងដែរ។

ខណៈដែលយុវជន និងប្រជាពលរដ្ឋមួយចំនួននៅតែបន្តរំលោភច្បាប់ចរាចរណ៍ ដូចជាមិនគោរពភ្លើងបញ្ជាចរាចរណ៍ បើក-បរហួសល្បឿនកំណត់ ប្រើប្រាស់គ្រឿងស្រវឹងនៅមុនពេលបើកបរជាដើមនោះ ... ក៏មានយុវជនមួយចំនួន បានថ្លែងនិងចង់ឲ្យសង្គមកម្ពុជាកែប្រែ មុខមាត់តាមរយៈការជំរុញឲ្យគ្រប់គ្នាអនុវត្តច្បាប់ជាពិសេសគឺច្បាប់ចរាចរណ៍។

លោកហូត វាសនា ជានិស្សិតនៅសាកលវិទ្យាល័យ ជាតិគ្រប់គ្រងមួយរូប បានថ្លែងថា សង្គមកម្ពុជា គួរតែរៀនគោរព និងចូលរួមអនុវត្តច្បាប់ឲ្យបានខ្ជាប់ខ្ជួន ជាពិសេស គឺច្បាប់ចរាចរណ៍។

លោកបន្តទៀតថា ច្បាប់ចរាចរណ៍គឺជាច្បាប់ដែលឈរមុខគេ ហើយដែលបង្ហាញអំពីឥរិយាបទ និងភាពថ្លៃថ្នូរបស់ពលរដ្ឋសម្រាប់សង្គមមួយដែលមានច្បាប់ទម្លាប់ និងមានការអនុវត្តច្បាប់បានត្រឹមត្រូវ។

លោកបញ្ជាក់ថា "សង្គមមួយដែលមានច្បាប់ ឬអត់នោះ តាមខ្ញុំគិតប្រហែលជាគេមើលលើ ការអនុវត្តច្បាប់ចរាចរណ៍នេះឯង ដោយសារតែវាបង្ហាញត្រង់ៗហ្នឹង"។

លោកបានបញ្ជាក់បន្តទៀតថា "បើយើងម្នាក់ៗមិនទាំងគោរពច្បាប់នេះ (ច្បាប់ចរាចរណ៍) តើឲ្យគេជឿថាសង្គមយើងមានច្បាប់ម៉េចកើត បើទង្វើនិងសកម្មភាពយើងបង្ហាញគេឯងឲ្យឃើញច្បាស់ពេញតែផ្លូវបែបនេះ"។

កញ្ញាសេង សុជាតា ជាយុវនារី មួយរូបដែលមិនប្រាប់អំពីមុខរបរ បានចូលរួមបញ្ចេញមតិយល់ស្រប នឹងការលើកឡើងរបស់លោកហូត វាសនា។ កញ្ញា បានឲ្យដឹងថា យើងម្នាក់ៗតែងតែចង់ឲ្យសង្គមកម្ពុជាមានច្បាប់មានទម្លាប់ដូចជាស្រុកគេ ប៉ុន្តែមានម៉េចកើតបើគ្រាន់តែច្បាប់ចរា-ចរណ៍ នាំគ្នាគោរពសឹងមិនបានផងនោះ។

កញ្ញាបានបញ្ជាក់ទៀតថា "ឥឡូវនេះអ្នករំលោភច្បាប់មើលឃើញពេញផ្លូវ "។ កញ្ញាបានបន្តថា ឲ្យតែអង្គុយចាំមើលបទល្មើសនៅលើទ្រូងផ្លូវ គ្រាន់តែឈប់ញ៉ាំអីនៅតាមចញ្ចើមផ្លូវ គឺឃើញមានរាប់មិនអស់។

កញ្ញាបានរៀបរាប់ថា កំហុសក៏ដូចជាការរំលោភច្បាប់ចរាចរណ៍ គឺមានតាំងពីមិនពាក់មួកសុវត្ថិភាព បើកបរយានយន្តដោយគ្មានស្លាកលេខ បើកល្បឿនវ៉ាគេខាងស្ដាំ មិនគោរពភ្លើងចរាចរណ៍ ជិះបញ្ច្រាស់ មិនគោរពសិទ្ធិអាទិភាពរបស់គេ ប្រើប្រាស់គ្រឿងស្រវឹងជ្រុលហើយបើកបរ ដឹកលើសទម្ងន់កំណត់ជាដើម...។ល។

កញ្ញា បានបន្តថា នៅស្រុកគេគឺដូចជាកម្រឃើញសកម្មភាពល្មើសច្បាប់ចរា-ចរណ៍ដូចជានៅស្រុកយើងណាស់ ។

កញ្ញាបានបន្តទៀតថា មិនបាច់និយាយដល់ស្រុកណាទេ ត្រឹមនៅស្រុកថៃ ស្រុកម៉ាឡេស៊ីអីដែលកញ្ញា និងគ្រួសារបានទៅដើរលេង ដូចជាកម្រឃើញបទល្មើសចរាចរណ៍នៅលើទ្រូងផ្លូវណាស់។

កញ្ញាបានបន្តទៀតថា ដូចជាករណីគោរពភ្លើងចរាចរណ៍ជាដើម គឺតែក្រហមគឺឈប់ហើយ មិនមែនឈប់តែពេលមនុស្សច្រើន តែនៅម៉ោងមានមនុស្សតិច និងមិនសូវមានអ្នកធ្វើដំណើរច្រើន បើកចេញទៅភ្លេត ដូចជានៅស្រុកយើងនោះទេ។

កញ្ញាបានបន្តចែករំលែកបទពិសោធន៍ថែមទៀតថា ត្រឹមតែប្រទេសកម្ពុជាយើង និងវៀតណាម ក៏មើលទៅគេគោរពច្បាប់ជាងយើងដែរ។

កញ្ញាបានបញ្ជាក់ថា "ពេលជិះឡានក្រុងទៅវៀតណាមនៅទឹកដីកម្ពុជា តែកុងឡាន មិនសូវជាគោរពល្បឿន នៃការបើកបរទេ គឺជាន់ឲ្យតែឈ្នះដៃ តែគ្រាន់តែឆ្លងចូលដីវៀតណាមភ្លាម គឺមិនធ្វេចធ្វាចឡើយ។ ច្បាប់គេឲ្យបើកល្បឿនប៉ុន្មានគឺប៉ុណ្ណឹង មិនឆ្លៀតឱកាសដូចជានៅខ្មែរឡើយ"។

លោក រិន រតនាគុណ ជាយុវជនដែលកំពុងតែបម្រើការនៅក្រុមហ៊ុនឯកជនមួយ ក៏បានចូលរួមបញ្ចេញយោបល់ទាក់ទងនឹងច្បាប់ចរាចរណ៍ថា សង្គមកម្ពុជាយើង បើសិនជាយើងម្នាក់ៗនាំគ្នា គោរពច្បាប់ចរាចរណ៍នោះសង្គមរបស់យើងនឹងមានរបៀបរៀបរយ ហើយសង្គមរបស់យើងក៏អាចបង្ហាញពីភាពថ្លៃថ្នូរ និងភាពស៊ី-វិល័យមួយនៅក្នុងតំបន់ផងដែរ ប៉ុន្តែមានឯណាពេលភ្លើងស្ដុបម្ដងៗ ពលរដ្ឋយើងគោរព ហើយភាគច្រើនគោរពមែន ប៉ុន្តែរាងដូចជាឧស្សាហ៍ឃើញករណីឈប់ ហួសកន្លែងកំណត់ហៀរទៅដល់កន្លែងគំនូសដែលគេគូសសម្រាប់ផ្ដល់សិទ្ធិដល់អ្នកដំណើរថ្មើរជើងឆ្លងកាត់ពេលមានភ្លើងស្ដុប។

លោកបានថ្លែងថា បើយើងចង់ឲ្យសង្គមរបស់យើងថ្លៃថ្នូរនឹងគេ គួរព្យាយាមកែចរិក និងទម្លាប់ឆ្លៀតឱកាសនៅលើទ្រូវផ្លូវចេញ ហើយព្យាយាម អានច្បាប់ចរាចរណ៍ យ៉ាងហោចណាស់ក៏ទុកជា ចំណេះដឹងផងដែរ។

យោងទៅតាមរបាយការណ៍របស់អគ្គ-ស្នងការប៉ូលីសជាតិបានឲ្យដឹងថា ក្នុងឆមាសទី១ ដើមឆ្នាំ ដោយគិត ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១៧ គ្រោះថ្នាក់ចរាចរណ៍ បានកើតឡើង ១៩០៧ លើក បណ្ដាលឲ្យមានអ្នកស្លាប់ ៩៣១ នាក់ និងរបួសសរុប ៣០០៦ នាក់។ ដោយឡែកនៅខែមិថុនា ឆ្នាំ២០១៧ គ្រោះថ្នាក់ចរា-ចរណ៍ផ្លូវគោក បានកើតឡើង ២៧២ លើក ស្លាប់ ១៣២ នាក់ និងរបួស ៤២០ នាក់។

តាមរបាយការណ៍របស់នាយកដ្ឋាននគរបាលចរាចរណ៍ និងសណ្ដាប់ធ្នាប់សាធារណៈ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បង្ហាញថាមូលហេតុនៃគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ទាំងនេះគឺកើតឡើងដោយសារបើកបរលើសល្បឿនកំណត់ ស្រវឹង ប្រជែងមិនគោរពសិទ្ធិ មិនប្រកាន់ស្ដាំ បត់គ្រោះថ្នាក់ ងងុយដេក និងកត្តាយាន។

ប្រភពដដែលបានឲ្យដឹងថា ក្នុងនោះនៅខែមករា គ្រោះថ្នាក់ចរាចរណ៍បានកើតឡើង ៣៧៩លើក ស្លាប់ ១៨៥នាក់ និងរបួស ៥៧៤នាក់។ ខែកុម្ភៈ ឆ្នាំ២០១៧ កើតឡើង ២៨៤លើក ស្លាប់ ១៤០នាក់ និងរបួស ៤១៨នាក់។ ខែមីនា គ្រោះថ្នាក់ចរាចរណ៍ បានកើតឡើង ៣២៦លើក ស្លាប់ ១៦៧នាក់ និងរបួសសរុប ៤៧៦នាក់។ ខែមេសា គ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក នៅទូទាំងប្រទេស បានកើតឡើង ៣៧៤ លើក បណ្ដាលឲ្យស្លាប់ ១៧៨ នាក់ និងរបួស ៦៨៣នាក់។ នៅខែឧសភា ឆ្នាំ២០១៧ គ្រោះថ្នាក់ចរាចរណ៍ បានកើតឡើង ២៧២ លើក ស្លាប់ ១២៩នាក់ និងរបួស ៤៣៥ នាក់។ រីឯខែមិថុនា ឆ្នាំ២០១៧ គ្រោះថ្នាក់ចរាចរណ៍ បានកើតឡើង ២៧២ លើក ស្លាប់ ១៣២នាក់ និងរបួស ៤២០ នាក់។

កញ្ញា សុជាតា បានថ្លែងថា តាមដែលកញ្ញាដឹង គ្រោះថ្នាក់ចរាចរណ៍សម្លាប់មនុស្សច្រើនណាស់នៅកម្ពុជាយើងនេះ ដូច្នេះគួរតែប្រុងប្រយ័ត្នទាំងអស់គ្នា។ កញ្ញាបានបញ្ជាក់ថា សុវត្ថិភាពចរាចរណ៍មិនអាចកើតមានឡើយ ដរាបណាយើងទាំងអស់គ្នានៅតែបន្តរំលោភច្បាប់ និងបើកបរដោយខ្វះការទទួលខុសត្រូវ។

កញ្ញាបានបន្តថា "ឃើញតែញយ អ្នកគោរពច្បាប់ ត្រូវជនល្មើសច្បាប់បុកស្លាប់ និងរបួសនោះ"។

*ដោយ អរិយបុត្រ*




ថតដោយ រិទ្ធី

# ទោះជាមិនពេញលេញ ប៉ុន្តែកម្មការិនីរោងចក្រនៅកម្ពុជាទទួលបានសិទ្ធិសម្រាកមាតុភាព

ថ្វីបើស្ត្រីជាកម្មការិនីនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជាមិនបានទទួលការសម្រាកមាតុភាពពេញលេញ ប៉ុន្តែក្នុងចំណោម បុគ្គលិក កម្មការិនី និយោជិក ដែលបានបំពេញការងារក្នុងវិស័យនេះភាគច្រើនជាស្ត្រីដែលមានវ័យចន្លោះ ពី១៨ឆ្នាំ ដល់ ៤៥ឆ្នាំ បានអះអាងថា ពួកគេបានទទួលសិទ្ធិសម្រាកមាតុភាព។

អ្នកនាង រស់ ស៊ីណា ដែលបច្ចុប្បន្នកំពុងតែបំពេញការងារក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់មួយកន្លែង ដែលស្ថិតក្នុងមូលដ្ឋានខណ្ឌមានជ័យបានថ្លែងថា គាត់បានបំពេញការងារ ជាកម្មការិនីរោងចក្រក្នុងរោងចក្រខាងលើអស់រយៈពេលជាង ៤ឆ្នាំមកហើយ ដោយចាប់ផ្តើមនៅម៉ោង ៧ព្រឹក និងសម្រាកនៅម៉ោង ប្រហែល៦ ទៅ៧ល្ងាចបើមានការថែមម៉ោង។

អ្នកនាង ស៊ីណាត បានបន្ថែមថា សព្វថ្ងៃគាត់មានកូនក្នុងបន្ទុកចំនួនមួយ មានអាយុជាង២ឆ្នាំ។ អ្នកនាងបានបន្តថា សម្រាប់កូនរបស់គាត់នៅក្នុងថ្ងៃធ្វើការបែបនេះ គឺគាត់បានយកមកឲ្យកន្លែងថែទាំទារកក្នុងរោងចក្រ ជាអ្នកមើលថែ ។

អ្នកនាងស៊ីណាតបានបន្ថែមថា អំឡុងពេលគាត់មានផ្ទៃពោះសម្រាលកូននោះ ខាងរោងចក្រ បានបើកប្រាក់ឈប់សម្រាកមាតុភាព ត្រឹមពាក់កណ្តាលនៃប្រាក់ខែរបស់គាត់ និងបានឈប់សម្រាករយៈពេល២ខែ។

អ្នកនាង ស៊ីណាត បន្ថែមថា "ខ្ញុំធ្វើការរហូតដល់ថ្ងៃសម្រាល។ ថៅកែរោងចក្រមិនអនុញ្ញាតឲ្យឈប់មុននោះទេ តែការសម្រាលនោះ ខ្ញុំមិនបានចំណាយប្រាក់ក្នុងការសម្រាលទេ ដោយខាងរោងចក្របានចុះកិច្ចសន្យាជាមួយ បសស (បេឡាជាតិរបបសន្តិសុខសង្គម) ខ្ញុំចំណាយតែថ្លៃហូបចុក និងថ្នាំពេទ្យតែប៉ុណ្ណោះ"។

បើតាមអ្នកនាងស៊ីណាត អ្នកនាង និងកម្មករចង់ឲ្យខាងរោងចក្រផ្តល់ប្រាក់បៀវត្សនៅពេលសម្រាកនោះពេញ ហើយរយៈពេលឈប់គួរតែ៣ខែ។

អ្នកនាងស៊ីណាត បានបន្តថា "សំណាងហើយ បើគេមិនបើកឲ្យមិនដឹងធ្វើអ្វីទេ មានតែយកទៅជាជាងអត់"។

អ្នកនាង សុខ សុធីតា ជាកម្មការិនី ដែលមានវ័យជាង២០ឆ្នាំ បានថ្លែងថា គាត់បម្រើការងារក្នុងរោងចក្រអស់រយៈពេលជាង២ឆ្នាំមកហើយ ដែលអ្នកនាងធ្វើការងារនេះដោយសារតែរៀនមិនបានខ្ពស់ដូចអ្នកដទៃ(ថ្នាក់ទី៨) ទើបសម្រេចចិត្តធ្វើការងាររោងក្រ។

អ្នកនាង ធីតា បានបន្ថែមថា សព្វថ្ងៃគាត់មានបុត្រក្នុងបន្ទុកចំនួនមួយ អាយុជាង១ខួប(១ឆ្នាំ)។ អ្នកនាងបានចែករំលែកថា ពេលដែលកូននេះនៅក្នុងពោះគាត់ពិបាកក្នុងការអង្គុយធ្វើការណាស់ ដោយអង្គុយរយៈពេលយូរធ្វើឲ្យគាត់ឈឺចង្កេះតែដើម្បីជីវភាពគាត់ត្រូវទ្រាំ។

អ្នកនាង ធីតា បានបញ្ជាក់ថា "ពេលអង្គុយដេរខោអាវ យូរឈឺចង្កេះ តែដើម្បីសន្សំលុយពេលសម្រាលកូននោះ ត្រូវទ្រាំ មិនដូចស្ត្រីដទៃ ដែលអង្គុយធ្វើការក្នុងម៉ាស៊ីនត្រជាក់នោះទេ តែក៏គ្រាន់បើជាងនៅផ្ទះធ្វើស្រែចម្ការដែរ"។

អ្នកនាង ធីតា បានបន្តថា សម្រាប់ពេលសម្រាលកូននោះ គឺត្រូវចំណាយលុយដោយខ្លួនឯង គ្មានថៅកែរោងចក្រជាអ្នកចេញនោះទេ គ្រាន់តែបានឈប់សម្រាកពេលឆ្លងទន្លេរយៈពេល៣ខែ ហើយក៏មិនបានទទួលប្រាក់បៀវត្សន៍ពេលសម្រាកនោះនឹងគេដែរ ដោយសារតែរោងចក្រដែលគាត់ធ្វើការមិនមែនជារោងចក្រធំ ពោលគឺគ្រាន់តែគេយកខោអាវពីរោងចក្រធំមកដេរតែប៉ុណ្ណោះ។

អ្នកនាងធីតា បានបន្តថា ពេលសម្រាលកូននោះគឺ បានប្រាក់ខែប្តីជាអ្នកទប់តែប៉ុណ្ណោះដោយឡែកខាងថៅកែរោងចក្រគឺឲ្យថ្លៃទឹកដោះគោកូនបន្តិចបន្តួច។

ចំណែកអ្នកស្រី សំ ស្រីនាង មានវ័យជាង ៣០ឆ្នាំ ដែលជាកម្មការិនីរោងចក្រមួយស្ថិតក្នុងខណ្ឌដង្កោ បានថ្លែងថា គាត់បានបំពេញការងាររោងចក្រជាង៥ឆ្នាំមកហើយ ដែលបំពេញការងារផ្នែកចេញគំរូម៉ូតខោអាវ។

អ្នកស្រី ស្រីនាង បានបន្តថា សម្រាប់ការឈប់សម្រាកមាតុភាពនោះគឺ គាត់បានឈប់សម្រាករយៈពេលបីខែ និង ទទួលបានប្រាក់ខែពាក់កណ្តាល។ អ្នកស្រីបានបន្តថា ពេលសម្រាលគាត់បានទៅសម្រាលនៅមន្ទីរពេទ្យរដ្ឋ ដែលរោងចក្របានសហការណ៍ជាមួយនោះ គឺមិនអស់លុយទេ។

អ្នកស្រីបានបន្តថា ការសម្រាលគឺមានការយកចិត្តទុកដាក់ពីថៅកែរោងចក្រណាស់ដោយផ្តល់ប្រាក់លើកទឹកចិត្តដល់គាត់ដែលបានបំពេញការងាររយៈពេលយូរ។អ្នកស្រីបានបន្តថា កាលពេល សម្រាលគាត់ក៏ប្រើប្រាស់ កាតបសស ដែរ ពោលគឺគ្រាន់តែមានកាតរោងចក្រ និងប័ណ្ណបសស ទៅជួបបុគ្គលិកគេ យើងបានសម្រាលហើយ ដោយមិនអស់លុយនោះទេ។

ចំណែក ស្ត្រីកំពុងមានផ្ទៃពោះម្នាក់ដែលជាបុគ្គលិករោងចក្រកាត់ដេរម្នាក់ទៀតឈ្មោះ វីយ៉ា ដែលមានវ័យជាង២០ឆ្នាំ ជាបុគ្គលិក ផ្នែកគណនេយ្យ បានថ្លែងដូចនេះថា គាត់ទើបតែចូលបម្រើការងារបានជាង៦ខែតែប៉ុណ្ណោះ និងបានធ្វើការរោងចក្រនេះដែលនៅជិតផ្ទះ។ អ្នកនាងវីយ៉ា បានបន្តថា សម្រាប់ការឈប់សម្រាកសម្រាលបុត្រនោះ គាត់មានការភ័យព្រួយដែរ ព្រោះមិនដឹងថា ត្រូវធ្វើដូចម្តេច តែថៅកែរោងចក្របានប្រាប់ឲ្យអ្នកនាង ទៅសម្រាលបុត្រនៅមន្ទីរពេទ្យរដ្ឋ។

អ្នកនាង វីយ៉ា បានបញ្ជាក់ថា "ថៅកែរោងចក្របានប្រាប់ថា ឲ្យទៅសម្រាលបុត្រនៅមន្ទីរពេទ្យរដ្ឋ ព្រោះរោងចក្របានចុះកិច្ចសន្យាជាមួយ ក្រសួងការងារ ហើយគឺមិនអស់លុយនោះទេ"។

អ្នកនាង វីយ៉ា បានបន្តថា "សម្រាប់ការឈប់សម្រាកវិញ ខ្ញុំឮគេប្រាប់ថា ឈប់សម្រាកបាន៣ខែដែរ និងទទួលប្រាក់ខែបានពាក់កណ្តាល ប៉ុន្តែយ៉ាងណាក៏ខ្ញុំមិនទាន់ដឹងដែរ ព្រោះមិនទាន់ឆ្លងទន្លេផង"។

ទាក់ទិននឹងសិទ្ធិទទួលបានមាតុភាពនេះ តំណាងរោងចក្រ ប៉ៃស៊ែ មួយរូបដែលសុំមិនបញ្ចេញអត្តសញ្ញាណ បានបញ្ជាក់ថា សម្រាប់ការឈប់សម្រាកមាតុភាពរបស់កម្មការិនីបុគ្គលិកផ្សេងៗ គឺអនុញ្ញាត្ត ឲ្យឈប់សម្រាករយៈពេល ៣ខែ និងទទួលបានប្រាក់ខែ ដូចអ្វីដែលរោងចក្រ បានចុះកិច្ចសន្យា ជាមួយក្រសួងការងារ ហើយក៏មានកញ្ចប់ ប្រាក់ឧបត្ថម្ភ បន្តិចបន្តួចដល់បុគ្គលិកទាំងនោះផងដែរ។

តំណាងខាងលើ បានបញ្ជាក់បន្ថែមថា មិនថាតែស្ត្រីមានផ្ទៃពោះនោះទេ សូម្បីតែកម្មករប្រុសៗ ដែលឈឺក៏អាចទៅព្យាបាលនៅមន្ទីរពេទ្យដែល គេមាន បសស ដែរប៉ុន្តែត្រូវធ្វើលិខិតសុំច្បាប់ មករដ្ឋបាលរោងចក្រផង ដើម្បីសម្រួលការងារឲ្យ។

តាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានសភាអនុម័ត្តកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ និតិកាលទី១ ហើយត្រូវបានចុះហត្ថលេខាប្រកាសអោយប្រើ នៅថ្ងៃទី១៣ ខែមិនា ឆ្នាំ១៩៩៧ ដោយប្រមុខរដ្ឋស្តីទី សម្តេច ជា ស៊ីម។ មាត្រា ១៨២ ក្នុងសហគ្រាសទាំងអស់ដែលមានរាប់ក្នុង មាត្រា១ នៃច្បាប់នេះ ស្រីទាំងឡាយត្រូវមានសិទ្ធីឈប់សម្រាក កៅសិបថ្ងៃ ដើម្បីសម្រាលកូន។ ក្រោយពីឈប់សំរាលកូនមកក្នុងរយៈពេលពីរខែដែលបានចូលធ្វើការត្រូវឱ្យស្ត្រីនោះធ្វើតែការណាស្រាលៗ។ មាត្រា ១៨៣ ក្នុងពេលដែលឈប់សំរាលដូចមានចែងក្នុងមាត្រាខាងលើនេះ ស្ត្រីមានសិទ្ធិត្រូវបានប្រាក់ឈ្នួលពាក់កណ្តាល គិតទាំងប្រាក់បន្ទាប់បន្សំផង ដោយនិយោជកបើកឱ្យ។

*ដោយ សុផានិត និងអរិយបុត្រ*



ថតដោយ រិទ្ធី

# លោកបូជាចារ្យមួយរូបលះបង់ ពេលវេលា ចិត្តនិងគំនិត ១៧ឆ្នាំ ដើម្បីបម្រើបេសកកម្មមនុស្សធម៌នៅកម្ពុជា



ថតដោយ លីហៀង

*រហូតមកដល់ពេលនេះមានជនបរទេសជាច្រើនដែលកំពុងតែបម្រើការងារនៅកម្ពុជាតាមមុខជំនាញនិងទេពកោសល្យរបស់ពួកគេរៀងៗខ្លួន ប៉ុន្តែនៅក្នុងចំណោមនោះ ក៏មានបុរសអ៊ីរ៉ុបមួយរូប ដែលមានសម្បុរសរមកពី អ៊ីតាលី គឺលោក ហ្គេហ្ស៊ី ម៉ារីយ៉ូ ជាបូជាចារ្យមួយរូបដែលជាអតីតតំណាងពេញសិទ្ធិលោកអភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដែលបានចំណាយពេលវេលា១៧ឆ្នាំ នៅលើទឹកដីនៃកម្ពុជា។ ដើម្បីឲ្យដឹងថា តើនៅក្នុងរយៈពេល ១៧ ឆ្នាំនេះ លោកបូជាចារ្យ បានបំពេញការងារ និងជួយដល់ប្រជាពលរដ្ឋកម្ពុជាយ៉ាងណាខ្លះ អ្នកនាំសារសូមណែនាំលោកបូជាចារ្យជូនមិត្តអ្នកអាន ។*

អ្នកនាំសារ ៖ តើលោកបូជាចារ្យបានចូលមកបម្រើសហគមន៍គ្រីក្រនៅកម្ពុជាតាមរយៈបេសកកម្មជាសាសនទូតនៅព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញតាំងពីពេលណាមក?

លោក ហ្គេហ្ស៊ី ម៉ារីយ៉ូ ៖ ខ្ញុំបានមកបំពេញតួនាទីជាសាសនាទូតនៅកម្ពុជាអស់រយៈពេល១៧ឆ្នាំមកហើយ ដោយខ្ញុំមកស្រុកខ្មែរនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០០០ ហើយនៅខែកញ្ញា ឆ្នាំនេះខ្ញុំនឹងចាកចេញពីកម្ពុជា។

អ្នកនាំសារ៖ នៅក្នុងតួនាទីជាសាសនទូតនៅកម្ពុជា តើលោកបូជាចារ្យធ្លាប់បានជួយសហគមន៍ណាខ្លះ តាមរយៈកិច្ចការនិងកម្មវិធីរបស់ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងព្រះសហគមន៍កាតូលិក នៅកម្ពុជានៅក្នុងរយៈពេល១៧ឆ្នាំនេះ ?

លោក ហ្គេហ្ស៊ី ម៉ារីយ៉ូ ៖ ដំបូងខ្ញុំរៀនភាសាខ្មែរបីឆ្នាំ ដោយឆ្នាំទី១ខ្ញុំបម្រើការងារនៅទីក្រុងភ្នំពេញ ជាមួយនឹងក្រុមសាសនទូតពីមេ។ ក្រោយមកខ្ញុំបានបន្តរៀននៅព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង ហើយបន្ទាប់មកក៏បានផ្លាស់ប្តូរមកភ្នំពេញវិញ។ នៅឆ្នាំទី៣ខ្ញុំក៏បានមកបម្រើការនៅទេវវិទ្យាល័យ ហើយក៏ទទួលការតែងតាំងឲ្យមកសម្របសម្រួលព្រះសហគមន៍បឹងទំពុន។ ខ្ញុំបម្រើការងារនៅទេវវិទ្យាល័យ ខែកក្កដា ឆ្នាំ ២០០៧ ។ ក្រោយមក បន្ទាប់ពីព្រះសហគមន៍បានសាងសង់ព្រះវិហារថ្មីនៅបឹងទំពុន ខ្ញុំបានចេញពីទេវវិទ្យាល័យ ទៅស្នាក់នៅព្រះសហគមន៍បឹងទំពុនតែម្តងរហូតដល់ឆ្នាំ២០១៤។ បន្ទាប់មកទៀតខ្ញុំចាកចេញពីបឹងទំពុនទៅជួយព្រះសហគមន៍នៅទីក្រុងតាខ្មៅរហូតដល់សព្វថ្ងៃ។

អ្នកនាំសារ៖ នៅពេលដែលបានមកដល់ប្រទេសកម្ពុជាដំបូង តើលោកបូជាចារ្យមានអារម្មណ៍យ៉ាងម៉េច? ចុះដល់ពេលដែលលោកបូជាចារ្យជិតដល់ពេលត្រូវចាកចេញ តើលោកបូជាចារ្យមានអារម្មណ៍យ៉ាងណា?

លោក ហ្គេហ្ស៊ី ម៉ារីយ៉ូ៖ ពេលខ្ញុំមកដល់ដំបូង ដូចជាមានអារម្មណ៍ស្រួលម៉្យាងពិបាកម៉្យាង។ ស្រួលដោយសារយើងសប្បាយចិត្ត ស្រុកខ្មែរឃើញថា អាកាសធាតុស្រួលជាងប្រទេសអ៊ីតាលី ប្រជាជនខ្មែរញញឹមរហូត ហើយមានអារម្មណ៍ថាប្រជាជនខ្មែរទទួលស្វាគន៍យើងស្រួល ក៏ប៉ុន្តែដើមដំបូងខ្ញុំអត់ទាន់ចេះភាសាខ្មែរ ដូច្នេះវាពិបាកទំនាក់ទំនង។ ខ្ញុំយល់ថា សម្រាប់ជនជាតិអឺរ៉ុបមករៀនភាសាខ្មែរមិនស្រួលទេ ត្រូវការពេលវេលា ត្រូវការភាពអត់ធ្មត់ច្រើនដើម្បីរៀនភាសាខ្មែរឲ្យមានលទ្ធភាពដើម្បីទំនាក់ទំនងជាមួយបងប្អូនខ្មែរ។ នេះជាអារម្មណ៍របស់ខ្ញុំ ហើយឥឡូវខ្ញុំត្រូវចាកចេញពីស្រុកខ្មែរ ខ្ញុំសោកស្តាយមែនទែនដោយសារ១៧ឆ្នាំហើយ ដែលខ្ញុំបានបម្រើការ និង រស់នៅកម្ពុជា។ ១៧ឆ្នាំមកនេះខ្ញុំមានអារម្មណ៍ថា នេះជាប្រទេសខ្ញុំ នេះជាផ្ទះរបស់ខ្ញុំ។ នៅពេលដែលខ្ញុំទៅប្រទេសក្រៅខ្មែរម្តងៗ ដោយសារមូលហេតុផ្សេងៗ ពេលខ្ញុំជិះយន្តហោះត្រឡប់មកស្រុកខ្មែរវិញខ្ញុំមានអារម្មណ៍ថា ខ្ញុំមកផ្ទះមិនមែនខ្ញុំត្រឡប់មកកន្លែងធ្វើការវិញនោះទេ។ ការចាកចេញរបស់ខ្ញុំជាការសោកស្តាយក៏ប៉ុន្តែការចាកចេញនេះ គឺដោយសារខ្ញុំត្រូវត្រឡប់ទៅអ៊ីតាលីវិញ ចាប់ផ្តើមការងារថ្មីនៅទីនោះ នេះក៏ជាអំណរសប្បាយមួយដោយសារតែនេះជាការត្រាស់ហៅរបស់ព្រះជាម្ចាស់។

អ្នកនាំសារ៖ បន្ទាប់ពីការចាកចេញពីប្រទេសកម្ពុជា តើលោកបូជាចារ្យត្រូវបម្រើនៅព្រះសហគមន៍ណា នៅកន្លែងណា?

លោក ហ្គេហ្ស៊ី ម៉ារីយ៉ូ៖ ដោយសារខ្ញុំជាសមាជិកនៃសាសនទូត ដូច្នេះជារឿងធម្មតាដែលយើងត្រូវប្តូរវេនគ្នាដោយសារយើងមានសកម្មភាពខ្លះនៅប្រទេសអ៊ីតាលី។ បូជាចារ្យនៅប្រទេសក្រៅយូរៗត្រូវទៅវិញម្តងមួយរយៈ ដូចជា៣ ទៅ៤ ឆ្នាំ ដើម្បីផ្លាស់វេនគ្នាបន្តសកម្មភាព។ ក្រុមបានចាត់ខ្ញុំតាំងពីឆ្នាំ២០១០ ក៏ប៉ុន្តែដោយសារមូលហេតុផ្សេងៗខ្ញុំក៏បានបន្តបេសកកម្មនៅកម្ពុជាបានរហូតដល់បច្ចុប្បន្នដល់ឥឡូវចប់ហើយត្រូវតែទៅ ត្រូវតែតាំងចិត្តស្តាប់បង្គាប់ត្រូវទៅវិញ។ ពេលត្រឡប់ទៅវិញខ្ញុំអាចបម្រើការ នៅក្នុងកម្មវិធីមួយនៅមណ្ឌលវប្បធម៌មួយ ដើម្បីផ្សព្វផ្សាយសាសនទូត ធ្វើការនៅប្រទេសផ្សេងៗ ដើម្បីប្រកាសដំណឹងល្អ។ នៅទីនោះមានសារមន្ទីរមួយ មានបណ្ណាល័យមួយ។ នៅទីនោះខ្ញុំអាចមាន សកម្មភាពជួយក្មេងៗសិស្សសាលា ការងារពាក់ព័ន្ធនឹងយុវជនដែរ។ ខ្ញុំនឹងអាចទទួលបាននូវបទពិសោធន៍ថ្មីៗ ដោយសារនៅទីនោះ មានបុគ្គលិកប្រមាណជា ៥០នាក់ ។

អ្នកនាំសារ៖ តើការចាកចេញទៅនេះលោកបូជាចារ្យសង្ឃឹមថានឹងមានឱកាសអាចវិលត្រលប់មកបម្រើនៅព្រះសហគមន៍កាតូលិកនៅកម្ពុជាវិញដែរឬទេ?

លោក ហ្គេហ្ស៊ី ម៉ារីយ៉ូ៖ ខ្ញុំសង្ឃឹមដែរ ! ជាធម្មតាដូចជាយើងទៅមួយរយៈយើងអាចត្រលប់ទៅប្រទេសដើមវិញ ។

អ្នកនាំសារ៖ ក្នុងពេលដែលលោកមកបម្រើការងារនៅព្រះសហគមន៍កាតូលិកនៅកម្ពុជាអស់រយៈពេល ១៧ឆ្នាំនេះ តើលោកចាប់អារម្មណ៍ទៅលើអ្វីខ្លាំងជាងគេ?

លោក ហ្គេហ្ស៊ី ម៉ារីយ៉ូ៖ នៅកម្ពុជា ខ្ញុំចាប់អារម្មណ៍ជាងគេគឺព្រះសហគមន៍នៅស្រុកខ្មែរ។ ខ្ញុំមកកម្ពុជានៅឆ្នាំ២០០០ និងចាប់ផ្តើមពីសូន្យ។ ឧទាហរណ៍ខ្ញុំចាប់ផ្តើមនៅបឹងទំពុន នៅទីនេះមាននិស្សិតទេវវិទ្យាល័យ៣នាក់ ដែលពេលនោះគេអត់បានរៀនទេវវិជ្ជាទេ គេរៀននៅវិទ្យាល័យ។ នៅបឹងទំពុនកន្លែងដែលខ្ញុំចាប់ផ្តើម ដូចជាពេលនោះមានក្មេងៗជាច្រើនមែនទែន ក្មេងមត្តេយ្យ និងបឋមសិក្សាច្រើនណាស់ ក្មេងជំទង់ខ្លះៗដែរ ប៉ុន្តែយើងចាប់ផ្តើមពីសកម្មភាពនេះបន្តិចម្តងៗ ព្រះសហគមន៍រីកចម្រើន ហើយសព្វថ្ងៃខ្ញុំមានអារម្មណ៍សប្បាយដោយខ្ញុំមើលឃើញថា ព្រះសហគមន៍បានសាបព្រោះរយៈពេល១៧ឆ្នាំ កន្លងមកនេះវាចាប់ផ្តើមមានផលផ្លែល្អ មានន័យថា ពីមុនគេជាក្មេងៗកុមារតចឹងទៅ។ ឥឡូវគេជាគ្រីស្តបរិស័ទពេញវ័យហើយ មានគ្រួសារមានកូន ដូច្នេះមានន័យថា ជំនឿរបស់គេបានចាក់ឫសមាំ។ មិនតែប៉ុណ្ណោះ គេចាប់ផ្តើមណែនាំកូនគេដើម្បីទទួលជាគ្រីស្តបរិស័ទដែរ តចឹងនេះជាអ្វីដែលខ្ញុំចាប់អារម្មណ៍ខ្លាំងជាងគេ។ ព្រះសហគមន៍នៅស្រុកខ្មែរចាប់ផ្តើមមានមុខខ្មែរតែម្តង អត់មានមុខបរទេសច្រើនដូចជាពីមុនឡើយ។

អ្នកនាំសារ ៖ ជុំវិញបេសកកម្មរបស់លោកបូជាចារ្យនៅក្នុងប្រទេសកម្ពុជា តើលោកបូជាចារ្យធ្លាប់ជួបការលំបាកទេ?

លោក ហ្គេហ្ស៊ី ម៉ារីយ៉ូ ៖ ១៧ឆ្នាំមកនេះ ខ្ញុំជួបអំណរសប្បាយច្រើនជាងដោយសាររបៀបធ្វើការនៅទីនេះវាស្រួលម៉្យាង និងយើងឃើញថា ព្រះសហគមន៍រីកចម្រើនច្រើនព្រោះសកម្មភាពរបស់ព្រះសហគមន៍មានការរីកចម្រើនទៅមុខ និងមានផលប្រយោជន៍។ ហើយសម្រាប់បងប្អូនគ្រីស្តបរិស័ទយើង ឃើញថា មានការជួយសង្គម សកម្មនៅក្នុងការជួយអ្នកក្រីក្រ អ្នកជម្ងឺ សិស្ស និស្សិត ដូច្នេះយើងឃើញថា មានអំណរសប្បាយច្រើនមែនទែន។ ការលំបាកមានខ្លះដែរ តែខ្ញុំគិតថា ទាំងនេះជាការលំបាកទូទៅធម្មតារបស់មនុស្សយើង។ ការធ្វើអ្វីមួយ យើងត្រូវតែជួបឧបសគ្គខ្លះ ការលំបាកខ្លះរឿងធម្មតាដែលយើងអាចដោះស្រាយបាន។

*ដោយ ស្រីម៉ាច និងអរិយបុត្រ*

# នារីម្នាក់ច្នៃសាប៊ូចេញពីធម្មជាតិ


ថតដោយ សុផានិត

សាប៊ូជាគ្រឿងធាតផ្សំគីមីមួយប្រភេទ ដែល មានប្រសិទ្ធភាពខ្លាំងមកលើសុខភាពស្បែក ការថែសម្រស់ ជាដើម។ សាប៊ូជាទូទៅត្រូវបានគេទទួលស្គាល់ថា ត្រូវបានផលិតចេញពីរោងចក្រ លាយបញ្ចូលល្បាយធាតុផ្សំជាច្រើនប្រភេទ។ សាប៊ូ មានច្រើនយ៉ាងដូចជា សាប៊ូដុសខ្លួន សាប៊ូលាងចាន សាប៊ូបោកគក់សំលៀកបំពាក់។

កញ្ញា វត្ថា វិច្ឆិការ ជាស្ត្រីខ្មែរមួយរូប ដែលបានផលិតសាប៊ូចេញពី គ្រឿងផ្សំធម្មជាតិ រុក្ខជាតិខ្មែរសុទ្ធសាធ។ កញ្ញា ជាកូនស្រីមួយរូបក្នុងចំណោម បងប្អូន២រូប ដែល មានស្រុកកំណើតក្នុងខេត្តតាកែវ។ ទីតាំងដែលកញ្ញា ផលិតសាប៊ូស្ថិតក្នុងភូមិព្រៃជាតុ ស្រុកត្រាំកក់ ខេត្តតាកែវ។

ក្រោយពេលបង្កើតបានជារោងចក្រមួយផលិតសាប៊ូខ្មែរប្រភេទទឹក ត្រូវបានផលិត ហើយក៏ចាប់ផ្តើមបង្ហាញខ្លួននៅលើទីផ្សារ។ នេះគឺជាលើកទី១ហើយ ដែលសាប៊ូធ្វើឡើងដោយដៃខ្មែរ មានឈ្មោះជាខ្មែរ នៅលើសំបកវេចខ្ចប់។

សាប៊ូដុំរូបមន្តពីប្រេងដូង ត្រូវបានបង្កើតឡើងដោយអាជីវកម្មផ្ទាល់ "ដៃខ្មែរ" សហការជាមួយប្រជាជនក្នុងសហគមន៍នៃឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ ដោយអាចលក់បានក្នុងមួយខាំ ៥ដុល្លារ។

កញ្ញា វិច្ឆិកា បានរៀបរាប់ថា ដំបូងអ្វីដែលកញ្ញាធ្វើគឺប្រេងដូង ដែលចាប់ផ្តើមផលិតក្នុងឆ្នាំ២០១៤ ខែសីហា ដោយសារតែកញ្ញាបានមកថត ហើយកញ្ញាក៏បានជួបដៃគូរពាណិជ្ជកម្មរបស់កញ្ញា ដោយដៃគូរកញ្ញាបានបង្កើតគម្រោងមួយ ដែលកញ្ញាចាប់អារម្មណ៏ទៅលើប្រេងដូងជាខ្លាំង ដោយសារតែប្រេងដូងមានអត្ថប្រយោជន៍យ៉ាងច្រើនចំពោះសុខភាព ស្បែក និងសម្ផស្ស។

កញ្ញា វិច្ឆិកា បានបន្តទៀតថា សាប៊ូដែលកញ្ញា ផលិតមានច្រើនប្រភេទ និងព័ណធម្មជាតិ ដោយប្រើតែប្រេងដូងតែមួយទេ ប៉ុន្តែ មានក្លិនច្រើនដូចជា ក្លិនឡាវេនឌឺ ចាស្មីន សាប៊ូស្ពៅ និង ម្រុំជាដើម។ ដោយផលិតផលរបស់កញ្ញាមានតែសាប៊ូដុំតែមួយមុខទេ ហើយនៅថ្ងៃអនាគតកញ្ញា មានគម្រោងជាសាប៊ូទឹកបន្ថែមដែរ។

កញ្ញា បានបញ្ជាក់ថា វត្ថុធាតុដើមសុទ្ធតែមាននៅក្នុងស្រុកទាំងអស់ ប្រើប្រេងដូងនៅកន្លែងដែលកញ្ញាផលិត បន្ទាប់មកមានដើមម្រុំ ដើមស្ពៅ បន្ទាប់មកបេះក្រឡុកច្របាច់យកតែទឹក ហើយបានជាសាប៊ូស្ពៅ សាប៊ូម្រុំ លាយបញ្ចូលគ្នា។

ផលិតករខាងលើក៏បានបន្ថែមថា សាប៊ូរបស់កញ្ញាពេញនិយមជាមួយភ្ញៀវបរទេស និងភ្ញៀវជាតិដែរ ដោយសារតែ ពួកកញ្ញាបានដាក់សាប៊ូនេះលក់នៅក្នុង ផ្សារទំនើបអ៊ីអនម៉ល (Eaon Mall) ដែលសហការណ៍ជាមួយនឹង អេមេសីងខេមបូឌា (Amazing Cambodia) ហើយដំណើរការបានល្អ នឹងនៅខេត្តសៀមរាប កូនហាងមួយ ឃើញថាខ្មែរៗយើងពេញចិត្តនឹង សាប៊ូនេះ ដោយពួកគាត់ត្រឡប់មកទិញបន្ថែមទៀត។

ចំពោះបច្ចុប្បន្នក្រុមរបស់កញ្ញា បានធ្វើដោយខ្លួនឯងជាជំហ៊ានដំបូងសិន បន្ទាប់មកនឹងស្វែងរកអ្នកភូមិដែលពួកគាត់ចូលចិត្តធ្វើសាប៊ូ ដែលកញ្ញានឹងបង្រៀនគាត់ដែលនេះជាដំណើរការ ការងារដែលកញ្ញាធ្វើ ដោយផលិតខ្លួនឯងឲ្យមានការយល់ដឹង សាប៊ូនេះមានអត្ថប្រយោជន៍អ្វីខ្លះ ប្រើរបៀបយ៉ាងមិចជាដើម ។

អ្វីដែលកញ្ញាធ្វើគឺដើម្បីបង្កើតការងារជូនប្រជាពលរដ្ឋក្នុងភូមិ ថ្ងៃអនាគតកញ្ញានឹងរកអ្នកភូមិជាពិសេសស្ត្រីៗ ដែលត្រូវការជំនួយពីក្រុមរបស់កញ្ញា។

ចំពោះតម្លៃវិញ គឺ៥០ដុល្លារក្នុងមួយគីឡូក្រាម ឬ១ខាំ ៥ដុល្លារ។ សាប៊ូដុំទាំងអស់មិនមានការវេចខ្ចប់ឡើយ ដោយរក្សាទុកជាលក្ខណៈធម្មជាតិ ហើយនៅពេលមានអ្នកទិញទើបវេចខ្ចប់តាមក្រោយ។ ត្រង់ចំណុចនេះ វិច្ឆិកា បានបញ្ជាក់ថា ដោយសារចង់រក្សាភាពដើម និងឲ្យអតិថិជនអាចប៉ះ អាចហិតក្លិន ឃើញរូបរាងនៃសាប៊ូធម្មជាតិពីប្រេងដូងច្បាស់។

តាមពិត អាជីវកម្មផ្ទាល់ "ដៃខ្មែរ" បានបង្កើតឡើងជិត ៣ឆ្នាំហើយ ដោយផលិតជាប្រេងដូងលក់។ ចំណែកសាប៊ូដុំនេះទើបបង្កើតឡើង និងឃើញថាមានការចាប់អារម្មណ៍ខ្លាំងទាំងបរទេស ក៏ដូចជាប្រជាជនខ្មែរ ហើយពួកគេថែមទាំងចូលរួមសាកល្បងធ្វើផងដែរ។ ក្រុមរបស់ វិច្ឆិកា បានបង្រៀនដល់ប្រជាជនក្នុងសហគមន៍ឲ្យចេះធ្វើ រួចផ្តល់កម្រៃដល់ពួកគាត់វិញសម្រាប់វត្ថុធាតុដើមដូចជាប្រេងដូងជាដើម៕

*ដោយ សុផានិត*

# ក្រសួងពាណិជ្ជកម្មដាក់ចេញនូវដំណោះស្រាយរយៈពេលខ្លី ទៅលើបញ្ហាកសិផលពោតធ្លាក់ថ្លៃ

បញ្ហាកសិផលពោតធ្លាក់ថ្លៃឆ្នាំនេះនឹងត្រូវបានដោះស្រាយ ដោយប្រើប្រាស់ថវិការបន្ថែមរហូតដល់៥០លានដុល្លារក្នុងនោះមាន២៧លានដុល្លាដែលជាទឹកប្រាក់សល់ពីការដោះស្រាយបញ្ហាស្រូវកាលពីឆ្នាំមុន។ បន្ថែមពីលើនេះ ក្រសួងពាណិជ្ជកម្មបានសម្រេចប្រើយុទ្ធសាស្រ្តមួយចំនួនដើម្បីដោះស្រាយបញ្ហាពោតក្នុងឆ្នាំ២០១៧។ នេះបើតាមសេចក្តីជូនដំណឹងរបស់ខ្លួនស្តី ពីបញ្ហាកសិផលពោត កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧។

យោងតាមសារព័ត៌មានវិទ្យុបារាំងអ៊ែអេហ្វអ៊ី (RFI) ចុះថ្ងៃទី១៩ កក្កដា ២០១៧ បានឲ្យដឹងថា លោកកៅ ថាច អគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ បានលើកឡើងថា សម្រាប់ការដោះស្រាយបញ្ហាថវិការកសិផលពោតឆ្នាំនេះ គោលការណ៍របស់ធនាគារនឹងផ្តល់កម្ចីសម្រាប់ទុនបង្វិល ឥណទានវិនិយោគ ដល់ម្ចាស់សៃឡូ ក្នុងការប្រាក់ទាបជាងមុន ពោលគឺចន្លោះពី៥%ទៅ៧%។ គួបញ្ជាក់ថា បច្ចុប្បន្ន ធនាគារអភិវឌ្ឍន៍ជនបទមានទឹកប្រាក់ក្នុងដៃចំនួន ២៧លានដុល្លារ ខណៈដែលរដ្ឋាភិបាលគ្រោងនឹងបង្កើនថវិកាបន្ថែមដល់ប្រមាណ ៥០ លានដុល្លារ។

ទន្ទឹមនឹងនេះ ក្រសួងពាណិជ្ជកម្មនឹងអនុវត្តលើវិធានការរយៈពេលខ្លី សហការជាមួយម្ចាស់សៃឡូ ដែលត្រូវការខ្ចីប្រាក់ ដើម្បីទិញកសិផលពោតធ្វើឡសម្ងួត និងពង្រីកឃ្លាំងស្តុកពោតបន្ថែម។ ក្រសួងបានបន្ថែមថា ខ្លួននឹងចងក្រងរបាយការណ៍ដើម្បីស្នើសុំទៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធទាំងអស់ ឲ្យកាត់បន្ថយលើការចំណាយក្រៅផ្លូវការនានាឲ្យបានពេញលេញ។ ហើយក្រសួងបានបញ្ជាឲ្យភ្នាក់ងារគយ និងកាំកុងត្រូល ឈប់យកកម្រៃលើការនាំចេញកសិផលពោត ចាប់ពីពេលនេះតទៅ។

បញ្ហាកសិផលពោត បានធ្លាក់ថ្លៃពី ៤៤០រៀល មកត្រឹម ៣៦០រៀល ព្រោះតែអាកាសធាតុមិនអំណោយផល ដោយមានភ្លៀងធ្លាក់ច្រើនដែលធ្វើឲ្យកសិករមានការលំបាកក្នុងការសម្ងួតកសិផលពោត។ ក្រៅពីនេះ កត្តាមួយចំនួនទៀត ដែលធ្វើឲ្យពោតធ្លាក់ថ្លៃដែរមានដូចជា ការចំណាយលើប្រាក់ក្រៅផ្លូវការទៅដល់មន្រ្តីពាក់ព័ន្ធតាមច្រកព្រំដែន កង្វះខាតហេដ្ឋារចនាសម្ព័ន្ធក្នុងការស្តុកពោត និងបរិមាណផលិតលើសពីតម្រូវការទីផ្សារ។

គួរបញ្ជាក់ថា ខណៈពេលដែលតម្រូវការទីផ្សារកសិផលពោតនៅមានកម្រិតចំនួនកសិផលពោតឆ្នាំ២០១៧មានការកើនឡើងខ្លាំងដល់ទៅ១លានតោនបើធៀបទៅនឹងឆ្នាំ២០១៦ មានចំនួនត្រឹមតែ ១០តោនប៉ុណ្ណោះ ដែលគិតជាទឹកប្រាក់ប្រមាណ១៤លានដុល្លា។

*ដោយ សុផានិត*

## រដ្ឋសភាកម្ពុជាអនុម័តជាថ្មីម្តងទៀតនូវវិសោធនកម្មច្បាប់ស្តីអំពីគណបក្សនយោបាយ

បន្ទាប់ពីការអនុម័តនូវការធ្វើវិសោធនកម្មច្បាប់ ស្តីអំពីគណបក្សនយោបាយកាលពីពេលថ្មីៗនេះ ច្បាប់នេះត្រូវបានសមាជិកសភា អនុម័តធ្វើវិសោធនកម្មជាថ្មីក្រោយសំណើររបស់រាជរដ្ឋាភិបាល។

ការធ្វើវិសោធនកម្មនៃច្បាប់នេះត្រូវបានសមាជិកសភាចំនួន ៦៥រូបនៅក្នុងចំណោមសមាជិកសភា ៦៦រូបដែលបានចូលរួមប្រជុំសភា លើកទី៨ នីតិកាលទី៥ នៅព្រឹកថ្ងៃទី១០ ខែកក្កដា ២០១៧ ក្រោមអធិបតីភាព សម្តេច ហេង សំរិន ប្រធានរដ្ឋសភា។

ការធ្វើវិសោធនកម្មនៃច្បាប់នេះ ត្រូវបានធ្វើឡើងក្រោយពេលដែលប្រមុខរដ្ឋាភិបាលបានអំពាវនាវជាសាធារណកាលពីថ្ងៃកំណើតគណបក្សកាន់អំណាច ដើម្បីហាមឃាត់អ្នកទោសមិនឲ្យធ្វើនយោបាយ។

ច្បាប់ស្តីអំពីគណបក្សនយោបាយត្រូវបានអនុម័តដំបូងកាលពីឆ្នាំ ១៩៩៧ ក្រោយមកនៅខែ កុម្ភៈ ច្បាប់នេះក៏បានធ្វើវិសោធនកម្មម្តង ដើម្បីថែរក្សាស្ថេរភាពនយោបាយ និងការពារប្រជាជាតិពីសង្គ្រាម និងការបែកបាក់ ប៉ុន្តែអ្នកវិភាគមួយចំនួនបានអះអាងថា ដើម្បីគាបសង្កត់គណបក្សប្រឆាំង ។

## ប្រាសាទសំបូរព្រៃគុកត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូបានអនុម័តទទួលយកការចុះបញ្ជី "តំបន់ប្រាសាទសំបូរព្រៃគុក" ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោកកាលពីថ្ងៃទី០៨ កក្កដា ២០១៧ កន្លងទៅនេះ។

បន្ទាប់ពីការចុះបញ្ជីនេះត្រូវបានអនុម័ត នៅថ្ងៃទី១០ ខែមករា រាជរដ្ឋាភិបាលកម្ពុជានិងបណ្តាអង្គ ទូតប្រទេសជាមិត្តអបអរសាទរចំពោះសេចក្តីសម្រេចនេះ ខណៈដែលមន្ត្រីរាជការ បុគ្គលិក ក្រុមហ៊ុន និងប្រជាពលរដ្ឋនានាបានទូងស្គរស្វាគមន៍។

ការសម្រេចដាក់បញ្ចូលប្រាសាទសំបូរព្រៃគុកក្នុងបញ្ជីបេតិកភណ្ឌពិភពលោកធ្វើឡើងក្នុងកិច្ចប្រជុំកំពូលលើកទី៤១ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដែលរៀបចំឡើងចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី១២ កក្កដា មាន ១៩៣ ប្រទេសជាសមាជិក និង២១ ប្រទេសជាគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងទីក្រុងក្រាកូហ្វ(Krakow) ប្រទេសប៉ូឡូញ។

សម្តេចតេជោ ហ៊ុន សែន បានបញ្ចេញសារអបអរថា "ជាការពិតការចុះបញ្ជីនេះគឺជាមហាសមិទ្ធផល និងជាកិត្យានុភាពដ៏ខ្ពស់ត្រដែតថ្មីមួយទៀតរបស់ជាតិយើងដែលកើតចេញពីការខិតខំប្រឹងប្រែងប្រកបដោយវិរិយភាពជាប់មិនដាច់ និងឥតរាថយរបស់រាជរដ្ឋាភិបាលកម្ពុជា"។

ដើម្បីអបអរព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ មន្ទីរ ក្រសួង គ្រប់រាជធានីខេត្ត ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ បានចូលរួមអបអរសាទរនៅម៉ោង១០ព្រឹក ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ដោយធ្វើការវាយគង ទូងស្គរ ទះប៉ោត និងគោះត្រដោក តាមគ្រប់មធ្យោបាយដែលខ្លួនមាន ។

ប្រាសាទសំបូរព្រៃគុកគឺជាប្រាសាទទីបីហើយដែលអង្គការយូណេស្កូសម្រេចចុះបញ្ជីជាសម្បត្តិបេតិកភណ្ឌពិភពលោកដែលលើកទី១ គឺប្រាសាទអង្គរវត្តត្រូវបានបញ្ចូលជាបេតិកភណ្ឌពិភពលោកនៅឆ្នាំ១៩៩២ ទី២ ប្រាសាទព្រះវិហារ នៅឆ្នាំ២០០៨ និងទី៣ ប្រាសាទសំបូរព្រៃគុកនេះតែម្តង។

សូមរំលឹកថាប្រាសាទសំបូរព្រៃគុកនេះគឺស្ថិតនៅភូមិសំបូរ ឃុំសំបូរ ស្រុកប្រាសាទសំបូរ ដែលមានចម្ងាយ ៣៧គីឡូម៉ែត្រពីទីរួមខេត្តកំពង់ធំ ដោយសង់លើដីរាបស្មើមានទំហំ៣០០០ហិកតា។ ប្រាសាទនេះ បានសាងឡើងនៅរជ្ជកាលស្តេចឥសានវរ្ម័នទី១ នៅក្នុងសត ទី៧ (គ.ស ៦១៦-៦៣៥)នាសម័យចេនឡា។

## ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំនេះទល់តែសិស្សបានពិន្ទុ២៣៧ទើបជាប់

លោក ហង់ ជួនណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសថា ការប្រឡង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិដែលគ្រោងនឹងរៀបចំនៅថ្ងៃទី២១ ខែសីហា ខាងមុខ សិស្សានុសិស្សទាល់តែធ្វើបាន២៣៧ពិន្ទុទើបជាប់ ខណៈឆ្នាំទៅ គឺត្រឹមតែ២២៤ ប៉ុណ្ណោះ។

លោករដ្ឋមន្ត្រីបានអះអាងថា ពិន្ទុជាប់នេះ ត្រូវបានតម្លើង ១៣ពិន្ទុ ដោយឡែក ពិន្ទុអតិបរិមា មានចំនួន ៥០០ពិន្ទុ ។

លោករដ្ឋមន្ត្រីបានបន្តទៀតថា ការប្រឡងខាងមុខនេះមានបេក្ខជនចូលរួមប្រឡងសរុបចំនួន ១០៣.១១២ នាក់ និងមានមណ្ឌលប្រឡងចំនួន ១៧៦ មណ្ឌល ចែងចេញជា៤.១៥៥បន្ទប់ នៅរាជធានី ខេត្តទាំង២៥។ លទ្ធផលនឹងប្រកាស នៅតាមមណ្ឌលប្រឡងនីមួយៗ នៅរសៀលថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៧ ។

ការប្រឡងបាក់ឌុបនៅក្នុងឆ្នាំនេះ គឺក្រសួងបានចំណាយថវិកាប្រមាណជាង១៥៣ពាន់លានរៀល ឬជាង៣៧លានដុល្លារ។

គួរបញ្ជាក់ថាកាលពីឆ្នាំ ២០១៦កន្លងទៅការប្រឡងនេះមានបេក្ខជនជាប់សរុបចំនួន៥៥.៧៥៣នាក់ ត្រូវជា ៦២,១៨ភាគរយនៃបេក្ខជនវត្តមានចំនួន ៨៩.៦៦១ នាក់។

## សេតវិមានច្រឡំហៅមេដឹកនាំចិនថា ជាប្រមុខរដ្ឋតៃវ៉ាន់

បណ្តាញ ព័ត៌មានបរទេសបានរាយការណ៍ថា សេតវិមានក្រោមរដ្ឋការរបស់លោក ដូណាល់ ត្រាំ បានប្រព្រឹត្តិកំហុសផ្នែកការទូតមួយ ដោយហៅមេដឹកនាំចិនថា ជាមេដឹកនាំនៃកោះតៃវ៉ាន់។

បន្ទាប់ពីហេតុការណ៍នេះ ក្រុមមន្ត្រីការទូតក្នុងសេតវិមានរបស់ លោក ត្រាំ បានសុំអភ័យទោស និងកែតម្រូវកំហុសរបស់ខ្លួន។

តាមរយៈសេចក្តីប្រកាសព័ត៌មានកាលពីថ្ងៃទី០៨ ខែកក្កដា ទាក់ទិននឹងកិច្ចប្រជុំក្នុងប្រទេសអាល្លឺម៉ង់ រវាងមេដឹកនាំចិន និង ប្រធានាធិបតីអាមេរិក ការិយាល័យព័ត៌មានរបស់សេតវិមានបានច្រឡំ ហៅលោក ស៊ី ជិនភីង ប្រធានាធិបតីចិន ថាជាប្រធានាធិបតីនៃសាធារណរដ្ឋចិន ដែលជាឈ្មោះផ្លូវការរបស់កោះតៃវ៉ាន់ ខណៈដែលឈ្មោះផ្លូវការរបស់ចិន គេហៅថា សាធារណរដ្ឋប្រជាមានិតចិន។

លោក កេង សួង អ្នកនាំពាក្យក្រសួងការបរទេសចិន បានថ្លែងថា នៅពេលរដ្ឋាភិបាលក្រុងប៉េកាំងស្នើឱ្យមានការបកស្រាយអំពីកំហុសការទូតនេះ មន្ត្រីរដ្ឋបាលលោក ត្រាំ បាននិយាយថា នេះជាកំហុសបច្ចេកទេស ហើយសេតវិមានបានសុំអភ័យទោស និងកែតម្រូវកំហុសនេះហើយ។

កំហុសបច្ចេកទេសនេះ គឺកើតឡើងចំពេលកំពុងមានការប្រឈមខាងការទូតរវាងតៃវ៉ាន់ និងចិន។ តាំងពីបំបែកចេញពីចិនដីគោកក្នុងឆ្នាំ ១៩៤៩ មក ប៉េកាំងតែងចាត់ទុកកោះតៃវ៉ាន់ជាដែនដីចិន ប៉ុន្តែអាជ្ញាធរតៃវ៉ាន់បានបដិសេធជាបន្តបន្ទាប់ ហើយបន្តរស់នៅក្នុងស្ថានភាពមួយដាច់ដោយឡែកពីចិន៕

## ជំងឺអាសន្នរោគកំពុងផ្ទុះខ្លាំងនៅប្រទេសយេម៉ែន

គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) បានប្រកាសថា ការឆ្លងរាលដាលនូវជំងឺអាសន្នរោគអស់រយៈពេលចំនួន១០សប្តាហ៍មកនេះ បានបណ្តាលឱ្យមនុស្សជាង៣០០.០០០នាក់ឆ្លងជំងឺនេះ នៅយេម៉ែន ដែលជាប្រទេសក្រីក្រមួយនៅលើពិភពលោក។

កាកបាទក្រហមអន្តរជាតិនេះ បានព្រមានថា ស្ថានភាពនេះ បានបន្តឆ្លងរាលដាលខ្លាំងហួសពីការគ្រប់គ្រងបាន ដោយមានករណីឆ្លងថ្មីចំនួន៧.០០០ករណី ក្នុងមួយថ្ងៃៗ។

អង្គការសុខភាពពិភពលោកបាននិយាយថា មានករណីសង្ស័យឆ្លងជំងឺនេះចំនួន ២៩៧.៤៣៨ករណី និងមនុស្សចំនួន១.៧០៦នាក់បានស្លាប់ដោយគិតត្រឹមថ្ងៃទី៧ ខែកក្កដា ។

ប្រភពដដែលបានបន្តថា ទោះយ៉ាងនេះក្តី អត្រាកើនឡើងប្រចាំថ្ងៃក្នុងចំនួនករណីឆ្លងជាទូទៅនេះ បានថយចុះអស់ជាង២ភាគរយកាលពីប៉ុន្មានសប្តាហ៍ថ្មីៗនេះ រីឯសន្ទុះនៃការឆ្លងរាលដាលជំងឺ ក៏បានធ្លាក់ចុះផងដែរនៅតំបន់ដែលមានការឆ្លងខ្លាំង ប៉ុន្តែតួលេខនៃការឆ្លងគឺនៅតែខ្ពស់ ។

ប្រភពដដែលបានបន្តថា ការឆ្លងរាលដាលខ្លាំងបំផុតគឺនៅតំបន់ជាច្រើននៅភាគខាងលិចនៃប្រទេសនេះ ដែលមានជម្លោះអស់រយៈពេល២ឆ្នាំរវាងក្រុមកងទ័ពចម្រុះដែលដឹកនាំដោយអារ៉ាប៊ីសាអូឌីត និងក្រុមឧទ្ទាមដែលគាំទ្រដោយអ៊ីរ៉ង់៕

# ពលរដ្ឋកម្ពុជា៖ អាជ្ញាធរគួរតែយកចិត្តទុកដាក់រឿងការ

ប្រជាពលរដ្ឋកម្ពុជា ជាទូទៅបាន សំណូមពរឲ្យអាជ្ញាធរយកចិត្តទុកដាក់ បន្តិចរឿងចេញច្បាប់អនុញ្ញាតយកផ្លូវថ្នល់ សារធារណៈរៀបចំជាពិធីផ្សេងៗ ដោយ ពួកគេអះអាងថា ផ្លូវសព្វថ្ងៃនេះមិនគួរឲ្យ មានអ្វីដែលនាំដល់ការកកស្ទះឃូនោះទេ។

ផ្លូវត្រូវបានគេបង្កើតឡើងសម្រាប់ការ ធ្វើដំណើររបស់ប្រជាពលរដ្ឋពីទីកន្លែង មួយទៅទីកន្លែងមួយ ប៉ុន្តែដោយឡែក នៅកម្ពុជាវាត្រូវបានគេប្រើប្រាស់មិនត្រឹម ជាច្រកសម្រាប់ធ្វើដំណើរប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងជាកន្លែងដែលគេឧស្សាហ៍ ឃើញ មានរៀបចំពិធីផ្សេងៗ នៅលើផ្លូវនេះតែ ម្តងតាំងពីពិធីរៀបអាពាហ៍ពិពាហ៍រហូត ដល់ពិធីបុណ្យផ្សេងៗ ដោយរួមទាំងពិធី បុណ្យសពជាដើម។

លោកស្រី រិន ចន្ទ ជាអ្នកដំណើរមួយ រូបដែលមានវ័យ៣៨ឆ្នាំ បានមានប្រសាសន៍ ថា យានយន្ត ឥឡូវនេះសំបូរណាស់ ដូច្នេះ អាជ្ញាធរគួរតែយកចិត្តទុកដាក់ជាងមុន ហើយនៅលើសណ្តាបធ្នាប់នៅ និងរបៀប រៀបរយនៃការប្រើប្រាស់ទ្រូងផ្លូវ នៅក្នុង ប្រទេស ជាពិសេសគឺនៅតាមបណ្តាទីក្រុង និងទីប្រជុំជននានា។ លោកស្រីបានថ្លែង ថា សម័យមុនចង់បិទផ្លូវធ្វើអ្វីមួយអាទិត្យ ក៏មិនអីដែរ ដោយសារផ្លូវវាច្រើន ឡាន ម៉ូតូ អីវាតិច ប៉ុន្តែឥឡូវនេះកុំថាឡើយ បិទ មួយអាទិត្យ ផ្លូវខ្លះបិទត្រឹមមួយចំហៀង ផង គឺស្ទះពិបាកធ្វើចរាចរណ៍ណាស់ ដោយ សារតែផ្លូវវានៅដដែល តែ ឡាន និងម៉ូតូ ព្រមទាំងមធ្យោបាយធ្វើដំណើរផ្សេងៗទៀត វាច្រើន ហើយធ្វើដំណើរពេញតែផ្លូវ។

លោកស្រីបានបន្តថា ថាបុណ្យទាន ឬ ពិធីបុណ្យអ្វីចុះគេរៀបចំម្តងម្កាល ប៉ុន្តែរឿង របៀបរបបលក់ដូចនៅតាមផ្សារ អាជ្ញាធរ គួរតែចាត់វិធានការណ៍ពង្រឹងរបៀបរបប លក់ដូរនេះចេញហើយ ដោយសារតែផ្លូវ មិនមែនជាកន្លែងលក់ ដូរ នោះទេ ប៉ុន្តែនៅ ពេលបច្ចុប្បន្ននេះមិនថា តែនៅតាមខេត្ត ឬនៅទីក្រុង និងទីប្រជុំជនទេ កន្លែងណា ដែលមានផ្សារ គឺមានប្រជាពលរដ្ឋលក់នៅ លើផ្លូវ ឡើងស្ទះពិបាកធ្វើដំណើរតែម្តង។

លោកស្រីបានបញ្ជាក់ថា "ទីណាក៏ ដូចទីណាដែរ ឲ្យតែមានអ្នកលក់នៅលើ ផ្លូវ គឺមានការកកស្ទះណែនណាំតានតាប់ តែម្តង។ ខ្ញុំដើរផ្សាររាល់ថ្ងៃ ខ្ញុំដឹងរឿង នេះ ហើយខ្ញុំបើកបរកាត់ផ្សាររាល់ថ្ងៃ ខ្ញុំក៏ យល់អំពីអារម្មណ៍អ្នកបើកបរ ដែលធុញ ថប់នឹងការកកស្ទះនេះដែរ" ។

លោក ខេង សាមេត ជាប្រជាពលរដ្ឋ មួយរូបដែលមានវ័យ ៤៩ ឆ្នាំ ហើយអះ អាងថា ជាប្រជាពលរដ្ឋនៅម្តុំផ្សារ ឱុយម៉េច បានមានប្រសាសន៍ថា វាគួរតែដល់ពេល ដែលយើងគួរតែលែងឲ្យទ្រូងផ្លូវក្លាយជា ចំណាប់ខ្មាំងនៃ ចំណត របស់សាលារៀន ក្រុមហ៊ុន ភោជនីយដ្ឋាន និងសណ្ឋាគារ ព្រមទាំងក្រសួងមន្ទីរនានាហើយ ពីព្រោះ យានយន្តឥឡូវមានច្រើនខ្លាំងណាស់ ជា ពិសេស គឺនៅតាមបណ្តាផ្លូវនៅរាជធានី ភ្នំពេញនេះតែម្តង។

លោកបានបញ្ជាក់ថា "ខ្ញុំមិនយល់មិន ដឹងគេ (អាជ្ញាធរ) គិតយ៉ាងម៉េច បាន អនុញ្ញាតឲ្យសណ្ឋាគារ ភោជនីយដ្ឋាន ប៉ុនៗណាណី មកយកមិនត្រឹមតែចិញ្ចើម ផ្លូវទៅធ្វើចំណតទេ ថែមទាំងយកទ្រូងផ្លូវ តែម្តងទៅធ្វើកន្លែងចំណតនៃក"។ លោក បានបញ្ជាក់ទៀតថា "ទិដ្ឋភាពបែបនេះមិន បាច់មើលទៅណាឆ្ងាយទេ មើលតែនៅលើ មហាវិថីមុនីវង្សទៅឃើញហើយ សណ្ឋាគារ ក្រុមហ៊ុន ភោជនីយដ្ឋាន ហាងលក់ទំនិញ និងក្រសួងមន្ទីរ ដែលយកចិញ្ចើម និងទ្រូង ផ្លូវធ្វើចំណតនោះ"។

លោកបានបន្តទៀតថា រឿងចំណត បែបនេះ គឺជារឿងប្រចាំតែម្តងនៅតាម



បណ្តោយផ្លូវនេះនិងតាមបណ្តាផ្លូវនានា នៅរាជធានីភ្នំពេញ និងតាមទីប្រជុំជន មួយចំនួនដែលអាជ្ញាធរគួរតែយកចិត្តទុក ដាក់ហើយ ដោយសារតែ ឡាន ក្រុង ឡាន ដឹកទំនិញ ឡានទេសចរណ៍ ឡានឯកជន ឡានតាក់ស៊ី ម៉ូតូឌុប ម៉ូតូឯកជន ម៉ូតូកង់បី ម៉ូតូរឺម៉ក ដែលគេហៅថា តុកតុក នោះ វា ច្រើនពេក ហើយបើនៅតែបណ្តោយឲ្យ បណ្តាសណ្ឋាគារ ភោជនីយដ្ឋាន និងម្ចាស់ សេវាកម្មមួយចំនួន នៅតែប្រើប្រាសផ្លូវ បែបនេះទៀតនោះ វាពិតមិនអាចដោះ ស្រាយអ្វីចេញនោះទេ ក្រៅពីការទទួល ការប្រទិច ពីអ្នកធ្វើដំណើរ។ ដោយឡែក រឿងពលរដ្ឋបិទផ្លូវធ្វើពិធីផ្សេងៗ បើអធ្យា- ស្រ័យបានក៏ គួរដែរដោយសារតែវា គឺជា ធុរៈម្តងម្កាល ប៉ុន្តែអាជ្ញាធរក៏គួរតែមើល ផងដែរ មិនមែនបិទផ្លូវមួយ ដោយគ្មានអ្នក សម្រួលចរាចរណ៍ ហើយការបិទនោះទៀត សោត គឺមិនគួរម្តងរាប់សិបថ្ងៃនោះទេ។

លោកបានបន្តថា "មិនស្រួលទេ បង ប្អូន! កាលណារៀបចំពិធីអ្វីមួយ ទោះធំក្តី មិនធំក្តី គឺត្រូវតែរិះគិតរឿង ចំណតនេះ ពីព្រោះផ្លូវខ្លះមិនចាំបាច់ដល់មានពិធីផង ត្រឹមតែចតបទចូលផ្ទះតែមួយភ្លែតនោះ គឺស្ទះពេញតែម្តងចុះទម្រាំដល់មានពិធី? ពិធីបុណ្យក្តី ឡើងផ្ទះក្តី រៀបការក្តី បង្កក់

## ប្រជាពលរដ្ឋសំណូមពរអាជ្ញាធរចុះពិនិត្យទីតាំងមុនពេលអនុញ្ញាតច្បាប់សុំសង់រោងសម្រាប់ពិធីផ្សេងៗ

ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ បាន ស្នើសុំអាជ្ញាធរមូលដ្ឋានជាពិសេសសង្កាត់ ចុះពិនិត្យទីតាំង មុនពេលចេញការអនុញ្ញាត ច្បាប់សុំសាងសង់រោងសម្រាប់ពិធីផ្សេងៗ នៅលើផ្លូវសាធារណៈ ដើម្បីងាយស្រួល ចាត់វិធានការណ៍ កាត់បន្ថយការកកស្ទះ។

លោករ៉េត កេត្យា បានមានប្រសាសន៍ ថា កន្លងមកការសាងសង់រោងនៅលើផ្លូវ សាធារណនេះគឺសុទ្ធតែមានច្បាប់មាន ទម្លាប់ពីអាជ្ញាធរមូលដ្ឋានទាំងអស់មិន មែនពលរដ្ឋចេះតែសង់នោះទេ ប៉ុន្តែគ្រាន់ តែអាជ្ញាធរមូលដ្ឋានមិនដែលយកចិត្តទុក ដាក់ទេ រឿងសណ្តាប់ធ្នាប់ចរាចរណ៍ចំពោះ ការអនុញ្ញាតទាំងនោះ។ ដូច្នេះមុនពេល ស៊ីញ៉េយល់ព្រមគួរណាស់តែ មានសេចក្តី ណែនាំរឿងរោងនេះ តាមការពិនិត្យជាក់ ស្តែង ដើម្បីកំណត់ពីពេលវេលា ការរៀបចំ កម្លាំង ដើម្បីជួយសម្រួលសណ្តាប់ធ្នាប់នៃ ការធ្វើដំណើរ មិនមែនគេដាក់មកចេះត ស៊ីញ៉េ ដើម្បីបានកម្រៃពីការចុះហត្ថលេខា ទាំងនោះទេ។

លោកខេង សាមេត ក៏បានជូនយោបល់ ផងដែរថា រឿងសាងសង់រោងនៅលើផ្លូវ សាធារណនេះគួរតែរិតបន្តឹង និងរៀបចំឲ្យ មានរបៀបរបបហើយ មិនមែននឹកឃើញ បិទ គឺបិទស្រេចតែចិត្តនោះទេ ពីព្រោះគ្មាន នរណាអាចធ្វើជា ម្ចាស់ផ្លូវបានទេ ។ រាល់ ការអនុញ្ញាតឲ្យសាងសង់គួរតែមានកាល កំណត់ មានបទដ្ឋានស្តង់ដាសាងសង់រោង មួយឲ្យប្រាកដ ដើម្បីកុំឲ្យថ្នាក់ថ្នាក់រវាង អ្នកដំណើរនិងសាមីម្ចាស់កម្មវិធីដែលសាង សង់រោង។ គ្រប់ពិធីទាំងអស់ គឺសុទ្ធតែមាន ផែនការ មានការកំណត់ច្បាស់លាស់ ដូច្នេះ អាជ្ញាធរមានពេលវេលាគ្រប់គ្រាន់ដើម្បី ធ្វើការសិក្សា លើកលែងតែបុណ្យសព ដែលគ្មាននរណាអាចដឹងបានច្បាស់។

# អនុញ្ញាតច្បាប់ឲ្យប្រើប្រាស់ទ្រូងផ្លូវធ្វើពិធីផ្សេងៗ



ថតដោយ រិទ្ធី

កូន បង្កក់ចៅក្តី មិនមែនឡាន ម៉ូតូមួយគ្រឿងទេ លោកអើយ សូមពិចារណាទាំងអស់គ្នា។ បើខានបានគួរតែខានទៅ កុំឲ្យគេដើរ" ។

លោក រ៉េត កេត្យា ជាប្រជាពលរដ្ឋដែលរស់នៅម្តុំសាលាទឹកល្អក់ បានមានប្រសាសន៍ថា រឿងយកផ្លូវសាងសង់រោងរៀបចំពិធីអាពាហ៍ពិពាហ៍ និងពិធីផ្សេងៗម្តងម្កាលមិនអីទេ ហើយគឺជារឿងដែលត្រូវយល់យោគគ្នា បើទោះបីជាលោកមានអារម្មណ៍ថា ធុញថបនឹងការកកស្ទះពេលធ្វើដំណើរឆ្លងកាត់ក៏ដោយ ប៉ុន្តែអ្នកខ្លះក៏ជ្រុលពេកដែរ ហើយមិនយល់តែម្តងមិនគិតពីអារម្មណ៍ មិនគិតពីការលំបាករបស់ដទៃ គិតតែពីខ្លួនយើង គ្រួសារយើងផ្ទាល់តែម្តង។ លោកបានបន្តថា ផ្លូវតំបន់ខ្លះតូចៗ ហើយច្រកចេញទៀតសោតវាមិនច្រើន ដូច្នេះតែបិទផ្លូវមួយ គឺពិតជាកកស្ទះមែនទែន ។

លោកកេត្យា បានបញ្ជាក់ថា "គ្មាននរណាអាចគេចរួចទេ រឿងរវល់ម្តងម្កាល ហើយក៏គេមិនថាដែររឿងធុរៈនោះ ប៉ុន្តែអ្នកខ្លះអត់ខួរតែម្តងបិទផ្លូវគេឯងធ្វើដំណើរយកមកការកូន ការចៅ សុទ្ធតែ៣ថ្ងៃ ហើយបុណ្យសពខ្លះសុទ្ធតែ៧ ទៅ៨ថ្ងៃ"។ លោកបានបញ្ជាក់ទៀតថា "ម្តងគេម្តងយើងគឺអាចអធ្យាស្រ័យឲ្យគ្នាបាន ប៉ុន្តែឲ្យចេះគិតផង ពីព្រោះគេគ្រប់គ្នាក៏មានអ្នកខ្លះអាចជួបវិបត្តិដោយសារតែ ការបិទផ្លូវទាំងនេះផងដែរ"។

លោកបានបន្តទៀតថា នរណាក៏មានជំនឿ នរណាក៏ចង់ខ្ពស់មុខខ្ពស់មាត់ ប៉ុន្តែយើងក៏ត្រូវតែរៀនសិក្សារៀនទទួលស្គាល់ការលំបាករបស់អ្នកដទៃ កុំចេះគិតតែខ្លួនឯង។ អ្នកដែលចេះគិត និងចេះដឹងមួយចំនួនឥឡូវនេះ ដោយសារតែគេបារម្ភរឿងកកស្ទះ និងការបង្កនូវការលំបាកដល់អ្នកដទៃនេះហើយបានជាគេសុខចិត្តទៅរកកន្លែងរៀបចំ នៅកន្លែងផ្សេង ពីព្រោះឥឡូវនេះគេមានកន្លែងរៀបចំពិធីទាំងនេះត្រឹមត្រូវងាយស្រួលទាំងកន្លែងរៀបចំ និងកន្លែងចំណត។

ជុំវិញបញ្ហាសណ្តាប់ធ្នាប់តាមដងផ្លូវសាធារណៈនេះលោក អៀង អូននី អភិបាលរងរាជធានីភ្នំពេញបានថ្លែងកាលពីពេលថ្មីៗថា នេះគឺជាបញ្ហាដែលសាលារាជធានីភ្នំពេញកំពុងតែយកចិត្តទុកដាក់។ ការកកស្ទះ និងការរៀបចំសណ្តាប់ធ្នាប់តាមទីសាធារណៈ តាមដងផ្លូវមិនមែនជា បញ្ហារបស់នរណាម្នាក់នោះទេ វាគឺជាបញ្ហារួម ហើយក៏មិនមែនជាបញ្ហាដែលអាជ្ញាធរអាចដោះស្រាយបានងាយស្រួលនោះដែរ។ វាជាបញ្ហាដែលត្រូវទាមទារទាំងពេលវេលា ទាមទារការសិក្សា ទាមទារគោលនយោបាយ ដូច្នេះហើយបានជាអាជ្ញាធរបានដាក់ឲ្យដំណើរការនូវសេវាកម្មរថយន្តក្រុងនៅក្នុងគោលបំណងជំរុញ ឲ្យប្រជាពលរដ្ឋឈប់ប្រើមធ្យោបាយដឹកជញ្ជូនផ្ទាល់ខ្លួន ហើយងាកមកប្រើសេវាកម្មរបស់សាធារណៈ ដើម្បីកាត់បន្ថយសំពាធនៃការកកស្ទះ។

*ដោយ អរិយបុត្រ*

## សាលារាជធានីភ្នំពេញប្រកាសយកផ្លូវ១១ខ្សែជាផ្លូវអាទិភាពរៀបចំសណ្តាប់ធ្នាប់

ឆ្លើយតបនឹងការត្អូញត្អែរឿងសណ្តាប់ធ្នាប់នៅក្នុងរាជធានីភ្នំពេញ សាលារាជធានីភ្នំពេញបានរៀបចំការប្រជុំ និងសម្រេចយកផ្លូវធំៗចំនួន១១ខ្សែក្នុងរាជធានី ជាអាទិភាពមុនគេ ដើម្បីរៀបចំសណ្តាប់ធ្នាប់។

លោក ម៉េត មាសភក្តី អ្នកនាំពាក្យសាលារាជធានីភ្នំពេញ បានប្រាប់អ្នកសារព័ត៌មានថា ការសម្រេចនេះបានធ្វើឡើងក្នុងកិច្ចប្រជុំមួយនៅសាលារាជធានីក្រោមអធិបតីភាពលោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ ជាមួយនឹងអភិបាលខណ្ឌទាំង១២ កាលពីរសៀលថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៧នេះ។ លោកមានប្រសាសន៍ថា ការរៀបចំសណ្តាប់ធ្នាប់សាធារណនៅទីក្រុងគឺជាបញ្ហាអទិភាពមួយ ហើយកន្លងមកអាជ្ញាធរក៏ជួបនឹងការលំបាកជាច្រើន ប៉ុន្តែឆ្លងការប្រជុំពិភាក្សាអង្គប្រជុំក៏បានសម្រេចយកផ្លូវធំៗចំនួន១១ ជាអាទិភាពមុនគេ ក្នុងការរៀបចំសណ្តាប់ធ្នាប់ក្នុងនោះរួមមាន មហាវិថីធំ ដូចជាមហាវិថីព្រះនរោត្តម ព្រះសីសុវត្ថិ ព្រះសីហនុ ព្រះមុនីវង្ស សហព័ន្ធរុស្សី ម៉ៅសេទុង កម្ពុជាក្រោម ព្រមទាំងវិថី មុនីរ៉េត ហ្សាដើហ្គោល ផ្លូវ២៧១ និងផ្លូវលេខ៧០។ល។ លោកបន្តថា ការងាររៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនេះមិនមែនធ្វើត្រឹមតែ ១១ផ្លូវនេះទេ អាជ្ញាធរនឹងបន្តរៀបចំជាបន្តបន្ទាប់តាមជំហាន។

លោកបានបន្តទៀតថា នៅក្នុងកិច្ចប្រជុំនេះ លោកអភិបាលរាជធានីភ្នំពេញក៏បានស្នើឱ្យមានការចូលរួម សហការពីអាជ្ញាធរដែនដី សង្កាត់ ខណ្ឌ ក៏ដូចជាកម្លាំងនគរបាល មានសមត្ថកិច្ចពិសេសនគរបាលសណ្តាប់ធ្នាប់ ឲ្យយកចិត្តទុកដាក់ដល់បញ្ហាផ្សេងៗដែលអាចបង្កឱ្យមានការបាត់បង់សណ្តាប់ធ្នាប់។

លោកបានបន្តទៀតថា ពាក់ព័ន្ធនិងបញ្ហាសណ្តាប់ធ្នាប់នេះ រដ្ឋបាលរាជធានីភ្នំពេញ និងធ្វើសេចក្តីជូនដំណឹងមួយដើម្បីពន្យល់ណែនាំដល់ម្ចាស់ផ្ទះ ក៏ដូចជាម្ចាស់ទីតាំង ឲ្យបញ្ឈប់ ឬធ្វើការកែរសម្រួល ការចត ការលក់ដូរ ដោយគ្មានសណ្តាប់ធ្នាប់នេះឡើងវិញ។

# សិក្ខាកាមចំនួន ១៤៣នាក់ទទួល វិញ្ញាបនបត្របញ្ចប់វគ្គ សិក្សាជំនាញវិជ្ជាជីវៈ

សិក្ខាកាមជំនាន់ទី២៥ ចំនួន ១៤៣ នាក់ ទទួលវិញ្ញាបនបត្របញ្ចប់ការសិក្សា ក្រោយពីបានទទួលការបណ្តុះបណ្តាល លើមុខជំនាញខុសៗគ្នាពីកម្មវិធី អភិវឌ្ឍយុវជន នៃអង្គការការីតាសកម្ពុជា។ ពិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាព លោកអូលីវីយេ ដ្មឺតអឺស្វ៊ែរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ និងលោកជំទាវ ហ៊ុន កុសនី អភិបាលរងខេត្តកណ្តាល រួមជាមួយភ្ញៀវកិត្តិយសជាច្រើននាក់ផងដែរ នាថ្ងៃទី២៣ មិថុនា ២០១៧ នៅភូមិតាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល។

តាមរបាយការណ៍របស់លោក ឆាយ ពិសិដ្ឋ ប្រធានកម្មវិធីអភិវឌ្ឍយុវជននៃអង្គការការីតាសកម្ពុជា បានឲ្យដឹងថា អង្គការការីតាស បានយកចិត្តទុកដាក់ចំពោះយុវជនក្រីក្រ ដែលគ្មានលទ្ធភាព បន្តការសិក្សា ដើម្បីឲ្យពួកគេធ្វើឲ្យបានប្រសើរឡើងនូវគុណភាពជីវិត។ លោកបន្តថា យុវជន យុវនារីដែលជាសិក្ខាកាមទាំងនោះ ជាអ្នកងាយទទួលការរងគ្រោះ ជាកូនកំព្រា និងជាជនចំណាកស្រុកជាដើម។ ជំនាញដែលបានបណ្តុះបណ្តាលមានដូចជា ជំនាញវេជ្ជបាល និងមូលដ្ឋានគ្រឹះគណនេយ្យ ជំនាញអភិវឌ្ឍន៍ជនបទ ជំនាញផ្នែករោងជាង និងគ្រឿងអេឡិចត្រូនិច ជំនាញផាត់មុខ និងធ្វើសក់ ជំនាញនីមួយៗមានថេរវេលាបណ្តុះបណ្តាលចំនួនមួយឆ្នាំ។

លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ដោយអំណរសប្បាយថា អង្គការការីតាសប្រៀបបានទៅ នឹងដៃស្តាំនៃព្រះសហគមន៍កាតូលិក បានជួយធ្វើការជាច្រើននៅក្នុងសង្គមខាងផ្នែកមនុស្សធម៌។ លោកអភិបាលក៏បាន កោតសរសើរដល់អង្គការការីតាសដែលបានខិតខំយកចិត្តទុកដាក់បណ្តុះបណ្តាលយុវជន ដើម្បីឲ្យពួកគេទទួលបានទាំង ចំណេះដឹង និងជំនាញច្បាស់លាស់។ លោកអូលីវីយេក៏មានប្រសាសន៍ផងដែរថា មុននេះលោកបានមានព្រួយបារម្ភ ចំពោះយុវនារីដែលបោះបង់ការសិក្សា ហើយទៅធ្វើការរោងចក្រ តែថ្ងៃនេះមាននារីដល់ទៅ៥០នាក់ដែលមកទទួលវិញ្ញាបនបត្រ។

អភិបាលព្រះសហគមន៍កាតូលិក លោកអូលីវីយេ បានថ្លែងទៅកាន់មាតាបិតា និងអាណាព្យាបាលទាំងអស់ ដោយអបអរសាទរ និងកោតសរសើរ ពួកគេដែលបានតស៊ូបញ្ជូនកូនមករៀននៅទីនេះ ទោះបីជាមានភាពលំបាកមួយរយៈក្តី តែសុខចិត្តធ្វើ ដើម្បីអនាគតរបស់កូន។ ស្របពេលនោះផងដែរ លោកអភិបាល ក៏បានផ្តាំផ្ញើដល់សិក្ខាកាមទាំងនោះ ឲ្យមានការទទួលខុសត្រូវខ្ពស់នៅក្នុងការងាររបស់ខ្លួន និងចេះបង្កើតទំនាក់ទំនងល្អរវាងគ្នានិងគ្នា ដោយចេះសម្រុះសម្រួល លើកលែងទោសឲ្យគ្នានិងមានសាមគ្គីភាពចំពោះគ្នាយ៉ាងពិតប្រាកដ។

យុវតី យិន មករា តំណាងសិក្ខាកាម បានថ្លែងថា "នាងខ្ញុំ និងមិត្តភក្តិសុទ្ធតែជាកូនកសិករ និងកូនកំព្រាតាមបណ្តាខេត្តផ្សេងៗ ដែលមិនសូវមានភាពក្លាហានក្នុងការប្រាស្រ័យទាក់ទងនៅក្នុងសង្គម តែក្រោយពីបានចូលរៀននៅការីតាស និងតាមរយៈកម្មវិធីផ្សេងៗបានធ្វើឲ្យខ្ញុំ និងសិស្សទាំងអស់មានភាពក្លាហាន និងអាចក្លាយទៅជាពលរដ្ឋល្អនៅក្នុងសង្គម"។ កញ្ញាបានឲ្យដឹងទៀតថា បច្ចុប្បន្នគាត់ទទួលបានការងារមួយ មានប្រាក់កំរៃសមរម្យ ហើយក៏សូមអរគុណចំពោះអង្គការការីតាសដែលបានផ្តល់ឱកាសដល់នាងដើម្បីទទួលបាននូវជីវភាពថ្មីផងដែរ។

នៅក្នុងពិធីប្រគល់វិញ្ញាបនបត្រដល់សិក្ខាកាមដែលបញ្ចប់ ការសិក្សានេះដែរ កម្មវិធីអភិវឌ្ឍយុវជន នៃអង្គការការីតាសកម្ពុជាក៏បានបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជំនាន់ទី២៦ បន្តទៀត។ ដោយ ដាលីស


ថតដោយ សុធីរិទ្ធ

# លោកប្រាក់ប៊ុនហុង៖ ជីវិតជាបូជាចារ្យមិនងាយស្រួល....សំខាន់ គឺជំនឿនិងសេចក្តីស្រឡាញ់


លោក ប្រាក់ ប៊ុនហុង ថតដោយ លីហៀង

លោកប្រាក់ប៊ុនហុង មានស្រុកកំណើតពីភូមិប៊្រស្រាជាភូមិដ៏តូចមួយដែលមានគ្រីស្តបរិស័ទជាង១០០គ្រួសារ ស្ថិតក្នុងខេត្តមណ្ឌលគីរី។ក្នុងសហគមន៍ខ្មែរជនជាតិភាគតិចពួណង ប៊ុនហុង ស្ថិតក្នុងកម្រិតជីវភាពរស់នៅមិនសូវមានសក្តានុពល ហើយការសិក្សាក៏ទាប។ ឈានដល់វ័យយុវជនលោកក៏សម្រេចចិត្តធ្វើដំណើរចាកចេញពីក្រុមគ្រួសារ មករកការងារធ្វើនៅទីក្រុងភ្នំពេញ ដោយសង្ឃឹមថានឹងអាចជួយសម្រួលដល់ឳពុកម្តាយ និងអាចជួយដល់ប្អូនៗក្នុងបន្ទុកគ្រួសារឲ្យអាចចូលរៀនបានប្រសើរជាងខ្លួន។ ដោយចំណេះដឹងនៅមានកម្រិត លោកត្រូវបានគេទទួលឲ្យធ្វើការក្នុងភោជនីយដ្ឋានមួយកន្លែង ដោយមានប្រាក់ខែតិចតួចអាចចិញ្ចឹមខ្លួនរស់តែប៉ុណ្ណោះ។

ប្រាក់ ប៊ុនហុង មកពីក្រុមគ្រួសារគ្រីស្តបរិស័ទដែលជាកសិករ និងមានបងប្អូនចំនួន៧នាក់ ដែលលោកជាកូនទី៤ក្នុងគ្រួសារ។ លោកទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងឆ្នាំ២០០៨ នៅព្រះសហគមន៍កំពង់ចាមក្រុង ភូមិភាគកំពង់ចាម។

ជីវិតការងារក្នុងទីក្រុងភ្នំពេញធ្វើឲ្យ ប៊ុនហុងមិនអាចទៅព្រះវិហារដើម្បីចូលរួមជាមួយព្រះសហគមន៍កាតូលិកបានឡើយ ព្រោះការងារនោះគ្មានថ្ងៃឈប់សម្រាកត្រឹមត្រូវ។ ចំពោះអវត្តមាននៅក្នុងព្រះវិហារនេះលោក ហុងក៏មិនបានភ្លេចព្រះជាម្ចាស់ដែរគឺលោកតែងធ្វើការអធិដ្ឋាន និងឆ្លៀតពេលដើម្បីមើលព្រះគម្ពីរខ្លះៗតាមតែអាចធ្វើទៅបាន។ បម្រើការងារជាច្រើនឆ្នាំលោកចាប់អារម្មណ៍ថា "ហាក់ដូចជាខ្លួនផ្ទាល់មិនបានបំពេញតួនាទីរបស់ខ្លួនឯងជាគ្រីស្តបរិស័ទ មានអារម្មណ៍ដូចជានៅខ្វះអ្វីម៉្យាងអីចឹងនៅក្នុងខ្លួន"។ លោកបន្តថា "ខ្ញុំមិនហត់នឿយក្នុងកិច្ចការប្រចាំថ្ងៃដែលត្រូវធ្វើនោះទេតែអ្វីដែលសំខាន់នោះគឺពេលខ្លះហាក់ដូចជាអស់សង្ឃឹមដោយសារតែខ្ញុំឃ្លាតឆ្ងាយពីព្រះសហគមន៍ក៏ដូចជាព្រះវិហារ។ ខ្ញុំភ័យខ្លាចថាថ្ងៃណាមួយធ្វើអោយខ្ញុំបាត់បង់ជំនឿដោយមិនដឹងខ្លួន"។

ក្រោយធ្វើការជាចុងភៅបានប៉ុន្មានឆ្នាំ ក្នុងឆ្នាំ២០១៤ លោកប្រាក់ ប៊ុនហុងបានសម្រេចចិត្តសរសេរលិខិតសុំចូលទេវវិទ្យាល័យពីលោកអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាមដើម្បីអប់រំខ្លួនជាបូជាចារ្យកាតូលិកក្នុងឆ្នាំ២០១៤។ ការសម្រេចចិត្តចូលរៀនទេវវិទ្យាល័យនេះ គឺជាការតាំងចិត្តមួយយ៉ាងខ្ពស់របស់លោកប្រាក់ ប៊ុនហុង។ លោកបានអោយដឹងថា "ខ្ញុំពិតជាស្រលាញ់ជីវិតជាអ្នកបម្រើរបស់ព្រះជាម្ចាស់ និងបងប្អូនទាំងអស់នៃព្រះសហគមន៍ទាំងមូល។ គឺខ្ញុំចង់អោយព្រះសហគមន៍នៅប្រទេសកម្ពុជាមានវត្តមានលោកបូជាចារ្យជាជនជាតិខ្មែរកាន់តែច្រើន"។ ប៊ុនហុងបន្តថា បើគិតអំពីឳពុកម្តាយគាត់មិនសូវបារម្ភទេ ដោយសារតែគាត់មានបងប្អូនច្រើនដើម្បីមើលថែរក្សាពួកគាត់។

ក្នុងជីវិតជានិស្សិតទេវវិទ្យាល័យលោកតែងទទួលបានការគាំទ្រពីក្រុមគ្រួសាររបស់លោកជានិច្ច ដែលជាកំលាំងឲ្យលោកអាចពុះពារនូវឧបសគ្គនានាក្នុងការសិក្សាអប់រំជាបូជាចារ្យ។

យុវជនដែលមានវ័យ ៣០ឆ្នាំរូបនេះ ឲ្យដឹងថាសម្រាប់លោកផ្ទាល់ជីវិតជាបូជាចារ្យគឺជាការលះបង់មួយដ៏ខ្ពស់ក្នុងជីវិត គឺត្រូវលះបង់ប្រយោជន៍ផ្ទាល់ខ្លួនចោលទាំងអស់ ជ្រើសរើស និងទទួលកិច្ចការជាអ្នកបម្រើក្នុងបងប្អូនទាំងអស់ដែលនៅជុំវិញខ្លួន ដោយស្រលាញ់ព្រះជាម្ចាស់ ប្រកាសដំណឹងល្អគ្រប់ទីកន្លែងនិងសុខចិត្តរួមស្លាប់រួមរស់ព្រះនាមព្រះជាម្ចាស់អស់មួយជីវិត។ លោកបន្តថា "ពិតណាស់ជីវិតជាលោកបូជាចារ្យមិនសូវស្រួលដូចការនិយាយតែអ្វីដែលសំខាន់គឺជំនឿ សេចក្តីស្រលាញ់ បើទោះបីជាមានការលំបាកយ៉ាងណាក៏យើងអាចជំនះបានដែរ"។

លោកប៊ុនហុងសង្ឃឹមថា ក្នុងការហ្វឹកហាត់ខ្លួនក្នុងទេវវិទ្យាល័យដែលត្រូវចំណាយពេល៧ឬ៨ឆ្នាំ និងអាចឲ្យគាត់បានក្លាយជាបូជាចារ្យម្នាក់ដែលនៅក្បែរព្រះយេស៊ូស្តាប់ព្រះអង្គនិងបម្រើដូចព្រះអង្គ។

លោកបានផ្តាំដល់គ្រីស្តបរិស័ទឯទៀតៗថា កុំឲ្យបោះបង់ជំនឿ ព្រោះជំនឿ គឺជាសេចក្តីស្រលាញ់។ លោកបញ្ជាក់ថា "ពេលណាយើងមានសេចក្តីស្រលាញ់នោះយើងអាចបំពេញកិច្ចការផ្សេងៗដោយសេចក្តីស្រលាញ់ដែរ"។ ដោយ រឿន ស្រីម៉ាច

# គ្រីស្តបរិស័ទត្រូវធ្វើជាមេម្សៅនៅក្នុងជីវិតរបស់បងប្អូនដទៃ



ថតដោយ សម្បត្តិ

ក្រោមអាកាសធាតុត្រជាក់លាយឡំដោយដំណក់ទឹកភ្លៀងរលឹមផ្សែងក្រូច បេក្ខជនចំនួន ៤៦នាក់ បានទទួលអគ្គសញ្ញាលាបថ្វាសនៅព្រះសហគមន៍សន្តីម៉ារីញញឹម ភូមិចំការទៀង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧។

កម្មវិធីនេះ មានការចូលរួមពីគ្រីស្តបរិស័ទនៅព្រះសហគមន៍សន្តីម៉ារីញញឹម និងដំណាងគ្រីស្តបរិស័ទនៅតាមព្រះសហគមន៍នានាក្នុងមណ្ឌលសកម្មភាពព្រះសហគមន៍ខេត្តតាកែវ ប្រមាណជាង៣០០នាក់ ក្រោមអធិបតីភាពរបស់លោកអភិបាល អូលីវីយេ។

ក្នុងធម្មទេសនា លោកអភិបាល អូលីវីយេ បានថ្លែងថា បងប្អូនដែលនឹងទទួលអគ្គសញ្ញាលាបថ្វាសថ្ងៃនេះ បានទទួលខុសត្រូវមួយយ៉ាងសំខាន់បំផុត គឺធ្វើដូចម្ដេចដើម្បីឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ អាចឲ្យមនុស្សទាំងអស់នៅក្នុងខេត្តតាកែវស្ដាប់ឮ។ នៅក្នុងចំណោមប្រជាជនជាង៨០០០០០នាក់ក្នុង ខេត្តតាកែវ យើងជាគ្រីស្តបរិស័ទមួយចំនួនតូចដែលទទួលខុសត្រូវខ្ពស់ ដូចព្រះយេស៊ូមានព្រះបន្ទូលថា "នៅពេលយើងសាបព្រោះតិច យើងច្រូតតិច នៅពេលយើងសាបព្រោះច្រើនយើងច្រូតច្រើន"។

លោកអភិបាលបានបន្តថា ព្រះវិញ្ញាណដ៏វិសុទ្ធដែលជាកម្លាំងរបស់ព្រះជាម្ចាស់ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងមានប្រាជ្ញាឈ្លៀសវៃ ឲ្យយើងចេះពិចារណាដឹងខុសដឹងត្រូវ ឲ្យយើងដឹងសេចក្ដីពិត ឲ្យយើងមានយោបល់ល្អ ឲ្យយើងមានសេចក្ដីអង់អាចឲ្យយើងធ្វើតាមព្រះវិញ្ញាណតែម្ដង និងឲ្យយើងចេះគោរពកោតខ្លាចព្រះជាម្ចាស់ជានិច្ច។

ជាចុងក្រោយលោកអភិបាលបានផ្ដាំដល់បេក្ខជនដែលទទួលអគ្គសញ្ញាលាបថ្វាសថា នៅតាមកន្លែងដែលបងប្អូនរស់នៅឲ្យបងប្អូនទទួលស្គាល់ថាយើងជាមេម្សៅនៅក្នុងម្សៅនៃជីវិត ទោះយើងជាមេតូច ប៉ុន្តែជាមេដែលមានឥទ្ធិពលនៃសេចក្ដីស្រឡាញ់។ ឲ្យបន្តប្រកាសដំណឹងល្អរួមជាមួយព្រះយេស៊ូដែលមានព្រះបន្ទូលថា "ព្រះរាជ្យរបស់ព្រះជាម្ចាស់ជិតមកដល់ហើយ ចូរកែប្រែចិត្តគំនិត ហើយជឿលើដំណឹងល្អចុះ"។

លោក ឯម និល ជាគ្រីស្តបរិស័ទមកពីព្រះសហគមន៍ក្រុងដូនកែវបានថ្លែងថា បន្ទាប់ពីបានទទួលអគ្គសញ្ញាលាបថ្វាស ធ្វើឲ្យលោកមានអំណរសប្បាយរីករាយ ដោយសារបានក្លាយជាគ្រីស្តបរិស័ទពេញលក្ខណៈមួយរូប។ ក្នុងជីវិតជាគ្រីស្តបរិស័ទ លោកបានខិតខំបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ តាមរយៈការអនុវត្តព្រះបន្ទូលនៅក្នុងជីវិតប្រចាំថ្ងៃរបស់លោក។ លោក ឯម និល ក៏បានបញ្ជាក់ថា លោកនឹងព្យាយាមផ្សព្វផ្សាយដំណឹងល្អរបស់ព្រះជាម្ចាស់អស់ពីសមត្ថភាព ដើម្បីឲ្យប្រជាពលរដ្ឋដទៃទៀតបានយល់ និងដើម្បីឲ្យប្រទេសកម្ពុជាទទួលបាននូវសុខសន្តិភាព ដោយចេះស្រឡាញ់គ្នា និងជួយគ្នាទៅវិញទៅមក ដូចព្រះជាម្ចាស់ដែលបានស្រឡាញ់មនុស្សលោក។

លោកស្រី គង់ សំណាង ជាគ្រីស្តបរិស័ទនៅព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀងបានប្រាប់ថា នៅពេលបានទទួលអគ្គសញ្ញាលាបថ្វាសហើយ នៅក្នុងជីវិតរបស់លោកស្រីហាក់បីដូចជាបានទទួលនូវជំនឿមួយយ៉ាងច្បាស់ និងមានសេចក្ដីសង្ឃឹមថ្មីដោយបង្កើតឲ្យសិរីរុងរឿងនៅក្នុងក្រុមគ្រួសាររបស់លោកស្រី។ ដើម្បីប្រកាសដំណឹងល្អលោកស្រីបានខិតខំធ្វើអំពើល្អជាមួយអ្នកដទៃ ដូចជាការសួរសុខទុក្ខ និងលើកទឹកចិត្តឲ្យគេមានសេចក្ដីសង្ឃឹមនៅក្នុងជីវិតជាពិសេសអស់អ្នកដែលសង្គមបោះបង់ចោល ដូចជាអ្នកជំងឺ ជនពិការជាដើម។

លោកស្រី បានបន្ថែមថា សព្វថ្ងៃលោកស្រីបានខិតខំបង្កើតទំនាក់ទំនងល្អជាមួយពុទ្ធបរិស័ទ និងបងប្អូនដទៃទៀត ដើម្បីពន្យល់អំពីព្រះសហគមន៍ឲ្យគេយល់ ជាពិសេសសមាជិកនៅក្នុងក្រុមគ្រួសារលោកស្រីតែម្ដង គឺលោកស្រីសង្ឃឹមថាពួកគាត់នឹងយលអំពីសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ហើយនឹងដើរតាមមាគ៌ារបស់ព្រះអង្គដូចលោកស្រីដែរ។

បន្ទាប់ពីបញ្ចប់អភិបូជា លោកអភិបាល អូលីវីយេ បានដឹកនាំគ្រីស្តបរិស័ទទាំងអស់ដើម្បីដង្ហែព្រះកាយព្រះគ្រីស្ត ទៅតាមផ្ទះគ្រីស្តបរិស័ទដែលស្ថិតក្នុងភូមិពងទឹកខាងត្បូង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ គឺមានចម្ងាយប្រហែល៣គីឡូម៉ែត្រពីព្រះសហគមន៍សន្តីម៉ារីញញឹមចំការៀង។ ក្នុងដំណើរនៃជំនឿ លោកអភិបាល លោកបូជាចារ្យ បងប្រុសបងស្រី និងបងប្អូនគ្រីស្តបរិស័ទទាំងអស់ បានធ្វើដំណើរក្រោមដំណក់ភ្លៀង ដើម្បីនាំព្រះកាយព្រះគ្រីស្តដល់ផ្ទះគ្រីស្តបរិស័ទ ដែលបានទន្ទឹងរង់ចាំទទួលស្វាគមន៍ដោយជំនឿ និងអំណរសប្បាយ។

*ដោយ សុធិរិទ្ធ*

# លោកអេនរីគេ៖ ខ្ញុំមានកម្លាំង ដោយសារមានបងប្អូនជួយ និងទទួលការណែនាំពីព្រះជាម្ចាស់


ថតដោយ ឡុង សម្ផស្ស

"អស់រយៈពេល១៧ឆ្នាំ ដែលព្រះជាម្ចាស់បានជ្រើសរើសខ្ញុំ ឲ្យណែនាំព្រះសហគមន៍ ដើម្បីឲ្យខ្ញុំដើររួមជាមួយបងប្អូន និងដើរតាមមាគ៌ារបស់ព្រះជាម្ចាស់ ដែលនេះណែនាំឲ្យខ្ញុំមានកម្លាំង ដើម្បីដើរទៅខាងមុខ។ ខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់ ចំពោះបេសកកម្មដែលយើងបានទទួលនេះ"។ នេះជាប្រសាសន៍របស់លោកអេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍ភូមិភាគបាត់ដំបង ទៅកាន់គ្រីស្តបរិស័ទជាច្រើន នៅក្នុងពិធីថ្វាយអភិបូជាអរព្រះគុណព្រះជាម្ចាស់ សម្រាប់បុណ្យខួប១៧ឆ្នាំ នៃការតែងតាំងលោកជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង។

ពិធីថ្វាយអភិបូជានោះ បានរៀបចំធ្វើឡើងនៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ក្រុងបាត់ដំបង កាលពីព្រឹកថ្ងៃទី០២ កក្កដា ២០១៧នេះ ដោយមានការអញ្ជើញចូលរួមពីសំណាក់លោកបូជាចារ្យ គ្រីស្តបរិស័ទប្រមាណជាង៥០០នាក់។ រួមជាមួយគ្នាដែរ ថ្ងៃទី០២ ខែកក្កដានេះក៏ជាពិសេសសម្រាប់លោកបូជាចារ្យទម្លាប់ សុផល គឺខួប២២ឆ្នាំ ក្នុងជីវិតជាបូជាចារ្យកាតូលិក ដែលបានទទួលអគ្គសញ្ញាតែងតាំង ក្នុងឆ្នាំ១៩៩៥។ ក្នុងធម្មទេសនា លោកបូជាចារ្យទម្លាប់ សុផល បានមានប្រសាសន៍ថា ព្រះបន្ទូលព្រះជាម្ចាស់នៅថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលប្រមូលផ្តុំយើង គឺព្រះអង្គបានត្រាស់ហៅយើង ឲ្យចូលរួមជាមួយព្រះអង្គ ហើយព្រះអង្គស្វាគមន៍យើង។ បើទោះបយើងមិនស្វាគមន៍ព្រះអង្គ ក៏ព្រះអង្គបានស្វាគមន៍យើង ឲ្យយើងធ្វើជាសាវ័ករបស់ព្រះអង្គ។ តែសូមបញ្ជាក់ថា គឺធ្វើជាសាវ័កពិតប្រាកដ មិនមែនជាសាវ័កលេងៗនោះទេ។ ដូចក្នុងព្រះគម្ពីរបានបញ្ជាក់ថា អ្នកណាមិនលីឈើឆ្កាងរបស់ខ្លួន ហើយដើរតាមខ្ញុំ អ្នកនោះមិនសមធ្វើជាសាវ័ករបស់ខ្ញុំទេ។ លោកបូជាចារ្យសុផល បន្ថែមថា សេចក្តីនេះបានបញ្ជាក់ន័យថា គឺយើងត្រូវស្រឡាញ់ព្រះយេស៊ូខ្លាំងជាងនរណាៗទាំងអស់ និងលើសពីអ្វីៗទាំងអស់។ នៅពេលព្រះយេស៊ូត្រាស់ហៅយើង គឺព្រះអង្គត្រូវការការរិះគិត និងឲ្យយើងជ្រើសរើសផ្លូវមួយដ៏ត្រឹមត្រូវដែលមកពីខ្លួនយើងផ្ទាល់ និងក៏ត្រូវការកម្លាំងដែលមកពីព្រះជាម្ចាស់ផងដែរ។

ជាមួយគ្នានោះ លោកបូជាចារ្យទម្លាប់ សុផល ក៏បានលើកឡើងអំពីគុណសម្បត្តិនៃការបំពេញតួនាទី ក្នុងមុខងាររបស់លោកអភិបាលអេនរីគេ នៅក្នុងកិច្ចការបម្រើ និងណែនាំព្រះសហគមន៍បាត់ដំបងនេះ។ លោកបានគូសបញ្ជាក់ថា ក្រោយពេលទទួលការតែងតាំងជាអភិបាលបំពេញមុខងារណែនាំព្រះសហគមន៍កាតូលិកនៅភូមិភាគបាត់ដំបង លោកអភិបាលអេនរីគេ បានខិតខំប្រឹងប្រែងយកអស់ពីកម្លាំងកាយចិត្តគឺលោកប្រៀបដូចជា បុរសដែលជាអ្នកស្រុកសាម៉ារីម្នាក់ ដែលមានចិត្តសប្បុរស គឺលោកអភិបាល ព្រមស្ម័គ្របម្រើបងប្អូន និងរីករាយក្នុងការទទួលអ្នកក្រីក្រ ជនរងគ្រោះ អ្នកជម្ងឺ ជនពិការ កុមារកំព្រាផ្សេងៗ ដោយបើកចិត្តយ៉ាងទូលំទូលាយទទួលស្វាគមន៍ចំពោះពួកគេ។ នេះជាបេសកកម្មមួយដែលលោកអភិបាលត្រូវបំពេញកិច្ចការតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដោយដើរតាមមាគ៌ារបស់ព្រះអង្គ។

ក្នុងពិធីដ៏វិសេសវិសាលនេះលោកអភិបាលអេនរីគេ បានមានប្រសាសន៍មកកាន់អ្នករាយការណ៍ស៊ីអេសស៊ីថា ក្នុងរយៈពេល១៧ឆ្នាំ កន្លងទៅនេះ បាននាំឲ្យខ្ញុំមានអនុស្សាវរីយ៍ជាច្រើន ជាពេលវេលាដែលនាំឲ្យខ្ញុំសប្បាយចិត្ត គឺមានបងប្អូនជាច្រើនបានជួយខ្ញុំ គឺតាមរយៈលោកគ្រូអ្នកគ្រូអប់រំជំនឿ តាមរយៈគណៈកម្មការនៅក្នុងព្រះសហគមន៍ដែលនាំឲ្យខ្ញុំសប្បាយចិត្ត។ អំឡុងពេលនោះ ក៏ទទួលការលំបាកខ្លះៗដែរ ប៉ុន្តែការលំបាកទាំងនោះយើងបានរួមគ្នាដោះស្រាយបញ្ហា។ ប៉ុន្តែអំណរសប្បាយមានច្រើនជាង ដោយសារតែខ្ញុំមើលឃើញប្រៀបហាក់បីដូចជាមានស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅក្នុងព្រះសហគមន៍ជាពិសេស គឺការយកចិត្តទុកដាកនៅក្នុងការអប់រំ និងបន្តជំនឿដែលបានបង្ហាញឲ្យឃើញថាបងប្អូនគ្រីស្តបរិស័ទយកចិត្តទុកដាក់អំពីជំនឿរបស់ខ្លួនលើព្រះជាម្ចាស់។

ចំណែកឯលោកបូជាចារ្យទម្លាប់សុផល ក៏បានចែករំលែកនូវ បទពិសោធន៍អំពីជីវិតជាបូជាចារ្យរយៈពេល២២ឆ្នាំនេះ និងប្រវត្តិនៃការត្រាស់ហៅផងដែរ។ លោកក៏បានលើកទឹកចិត្តយុវជន ឲ្យបន្តមានចិត្តក្លាហាន រស់នៅក្នុងជំនឿរឹងមាំ និងហ៊ានឆ្លើយតបចំពោះការត្រាស់ហៅផងដែរ។ បន្ទាប់ពីពិធីថ្វាយអភិបូជាតំណាងគណៈកម្មាធិការព្រះសហគមន៍បាត់ដំបង ព្រមទាំងបងប្អូនគ្រីស្តបរិស័ទ បានជូនផ្កា និងជូនពរដល់លោកអភិបាល លោកបូជាចារ្យ ទម្លាប់សុផល និងបានជូនពរលោកទាំងពីរ សូមឲ្យលោកមានសុខភាពល្អ កម្លាំងខ្លាំងក្លា ដើម្បីបំពេញបន្តនូវបេសកកម្មរបស់ព្រះជាម្ចាស់ នៅក្នុងការកសាងព្រះរាជ្យរបស់ព្រះអង្គឲ្យចម្រើនឡើង ៕

*ដោយ ឡុង សម្ផស្ស*

## លោកសិលា ឈុំ សំចៃ (១៩៣៣-១៩៧៧)

### Pierre CHHUM SOMCHAY

### គ្រហស្ថ និងជំនួយព្រះសហគមន៍



សិលាឈុំសំចៃកើតនៅថ្ងៃទី២៣ មេសា ១៩៣៣ នៅភ្នំពេញជាកូនប្រុសទោលក្នុងគ្រួសារគ្រីស្តបរិស័ទកាតូលិកមួយ។ លោកបានទទួលពិធីជ្រមុជទឹកនៅ ព្រះវិហារព្រះនាងម៉ារីគ្មានជំពាក់បាបកម្មនៃព្រះសហគមន៍កាតូលិកព្រះមាតានាទីក្រុងភ្នំពេញ ។ លោកសិក្សាមុខវិជ្ជាច្បាប់ ហើយក៏ក្លាយទៅជាមន្ត្រីរាជការគយរដ្ឋករ ។

ថ្ងៃទី១១ មេសា ១៩៦០ សិលាឈុំសំចៃរៀបអាពាហ៍ពិពាហ៍ជាមួយកញ្ញាអាណានឿមយក់ តាន់ កើតនៅឆ្នាំ១៩៣៩ នៅខេត្តបាត់ដំបង ។ គូស្រករនេះមានកូនប្រុសស្រី ១២នាក់ (ស្រី ២ ប្រុស ១០) កូនទី ១២ បានទទួលមរណភាពក្នុងអាយុ ៣ឆ្នាំ ។ ពេលខ្មែរក្រហមចូលកាន់កាប់ក្រុងភ្នំពេញនៅថ្ងៃទី១៧ មេសា ១៩៧៥ ក្រុមគ្រួសារសិលាឈុំសំចៃរស់នៅក្នុងព្រះសហគមន៍ព្រះមាតាភ្នំពេញ ។

ថ្ងៃទី២១ មេសា ខ្មែរក្រហមនិរទេសគ្រួសារគាត់ចេញពីទីក្រុងភ្នំពេញបន្ទាប់ពីដើរអស់រយៈពេល ៣០ថ្ងៃខ្មែរក្រហមបង្ខំឲ្យកាប់ឆ្ការព្រៃនៅក្នុងព្រៃថ្មពង ។ ចុងខែមិថុនា ឆ្នាំ១៩៧៥ កូនប្រុសស្រីរបស់លោកចំនួន ២ នាក់ ដែលមានអាយុ ៥ឆ្នាំ និង៦ឆ្នាំត្រូវបាត់បង់ជីវិត ។ សិលាឈុំសំចៃបានកត់ត្រារឿងរ៉ាវទាំងអស់ ជាភាសាបារាំងចូលទៅក្នុងសៀវភៅប្រចាំគ្រួសារ គឺជាសារលោគ្នាលុះអវសានពោរពេញដោយជំនឿ និងសេចក្តីសង្ឃឹម ។ សិលាឈុំសំចៃបានសរសេរសារលោគ្នារបៀបនេះនៅគ្រប់មរណភាពរបស់កូនៗចំនួន ៨នាក់ទៀត ។ អ្នកស្រីយ៉ក់ តាន់ បានថែរក្សាសៀវភៅកំណត់ហេតុនេះទុកជាមរតកដ៏មានតម្លៃបំផុត ។ បួនខែក្រោយមកគ្រួសារនេះត្រូវផ្លាស់ប្តូរបញ្ជូនឲ្យទៅស្រុកមោងជិតខេត្តបាត់ដំបង ។ ក្រុមគ្រួសារនេះរស់នៅបែកខ្ញែកគ្នា ។ ប្តី-ប្រពន្ធសិលាឈុំសំចៃក៏រស់នៅបែកគ្នាតាមការដ្ឋានរៀងៗខ្លួនដែរ ។ កូនបងៗធ្វើជាកងចល័ត ។ ឆ្នាំ១៩៧៦ ម្តាយក្មេករបស់លោកព្រមទាំងកូនៗបួននាក់ បានទទួលមរណភាពបន្ទាប់មកនៅឆ្នាំ ១៩៧៧ កូន ២ នាក់ក៏ទទួលមរណភាពទៀត ។

អាណាយ៉ក់ តាន់ ផ្តល់សក្ខីភាព "ថ្ងៃទី ៥ សីហា ១៩៧៧ អង្គការបានចាប់ប្តីខ្ញុំក្នុងពេលគាត់កំពុងដឹកជញ្ជូនថង់ដាក់ប្រដាប់បំពង់សម្លេងនិងថង់ស្រូវសម្រាប់សហករណ៍។ ប្រធានភូមិបានសារភាពប្រាប់ខ្ញុំថាគាត់ត្រូវតែសម្លាប់ប្តីខ្ញុំ... គាត់ជាបុរសម្នាក់ស្លូតបូតនិងស្មោះត្រង់ ខ្ញុំស្រឡាញ់គាត់ណាស់។ ប៉ុន្តែគាត់បានសម្តែងការស្មោះត្រង់ថា គាត់ជាមន្ត្រីគយដូច្នេះជាចាំបាច់ខ្ញុំត្រូវគោរពតាមការដាក់ទិសរបស់អង្គការ...។ កូនប្រុសស្រីរបស់ខ្ញុំចំនួន ១០ នាក់ បាត់បង់ជីវិតអស់ ។ ចំណែកប្តីរបស់ខ្ញុំក៏ត្រូងអង្គការសម្លាប់ទៀត ។ ខ្ញុំមិនស្អប់ចងគំនុំគុំកួនណាម្នាក់ឡើយ ។ ប្តីខ្ញុំមិនបានស្អប់ខ្ពើមខ្មែរក្រហមទ គោត់ក៏គ្មានបំណងសងសឹកតបនឹងអំពើអាក្រក់ដែលពួកគេបានធ្វើមកលើគាត់ដែរ ។ ខ្ញុំក៏ដូចប្តីខ្ញុំដែរ... ខ្ញុំមិនស្អប់ខ្ពើមឬមានចិត្តចងគំនុំព្យាបាទឈ្នានីសឡើយ ។ ខ្ញុំបានលះបង់ចោលគ្រប់យ៉ាងអស់ហើយ" ។

# ការប្រើប្រាស់ឱសថ និងជំនឿរបស់គ្រីស្តបរិស័ទ

សេចក្តីពិតរបស់មនុស្សយើងម្យ៉ាងគឺ "ជំងឺ" ដែលគ្មានមនុស្សណាជៀសវាងបានឡើយ ។ មនុស្សឆ្លើយតប សេចក្តីពិតនេះ ដោយព្យាយាមរក្សាជីវិតរបស់ខ្លួនឲ្យគង់វង្សមិនអាចវិនាសបាត់បង់ ហេតុដូច្នេះហើយ នាំឲ្យមនុស្សយើងមានការស្រាវជ្រាវរបៀបព្យាបាលជាច្រើន ហើយមនុស្សបានរកឃើញជំនួយសំខាន់មួយគឺ "ថ្នាំ" ឬ "ឱសថ" សម្រាប់ព្យាបាលជំងឺឲ្យជាសះស្បើយ ។

សព្វថ្ងៃនេះ យើងបានស្រាវជ្រាវរកឃើញថា ជំងឺដែលកើតឡើងក្នុងជីវិតមនុស្ស ក្រៅពីខាងផ្លូវកាយ ក៏មានជំងឺខាងផ្លូវចិត្តដែរ។ ជំងឺខាងផ្លូវចិត្ត នោះអាចប៉ះពាល់ដល់រាងកាយ នាំឲ្យកើតជំងឺផ្សេងៗមកតាមក្រោយដែរ ដូចជា ជំងឺក្រពះ, ជំងឺបេះដូង, ប្រព័ន្ធការពាររាងកាយខ្សោយ, ដេកមិនលក់ ជាដើម។

សម្រាប់យើងជាគ្រីស្តបរិស័ទ យើងមិនបដិសេធទេថា ជំងឺទាំងពីររបៀបនេះមិនបានកើតឡើងក្នុងជីវិត របស់គ្រីស្តបរិស័ទ។ ប៉ុន្តែគ្រីស្តបរិស័ទ គឺ មនុស្សដែលមានជំងឺទៅលើព្រះគ្រីស្ត នោះច្បាស់ថា ជំនឿផ្តល់ឥទ្ធិពលយ៉ាងមានន័យ សម្រាប់ការព្យាបាលជំងឺនោះដែរ។ ដូចបងប្អូនសាសនិកឯទៀតៗ ក៏ពឹងលើការព្យាបាល ដោយប្រើជំនឿ ដែលមានរបៀបផ្សេងៗ ដែលយើងអាចឃើញសព្វថ្ងៃនេះ។

នៅក្នុងព្រះគម្ពីរ យើងអត់ឃើញថ្នាំឈឺក្បាល ថ្នាំក្រពះទេ ព្រោះជំនាន់នោះមិនទាន់ជឿនលឿនខាងបច្ចេកទេសថ្នាំទំនើបដូចយើងសព្វថ្ងៃនេះ ប៉ុន្តែយើងឃើញកត្តា២ នៃការព្យាបាលរបស់ព្រះយេស៊ូ គឺទីមួយគឺ"ជំនឿ"មានច្រើនដង ដែលព្រះយេស៊ូព្យាបាលដោយបញ្ជាក់ ជំនឿបានព្យាបាលគាត់ដូចជា ពេលព្រះអង្គព្យាបាល មនុស្សខ្វាក់ឈ្មោះបារទីមេ ព្រះអង្គមានព្រះបន្ទូលថា "សុំអញ្ជើញទៅចុះ! ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ!ៗ"។ (មក ១០,៥២) ឬ ពេលព្រះអង្គព្យាបាលស្ត្រីមានជំងឺធ្លាក់ឈាម។ ព្រះអង្គប្រាប់នាងក្រោយព្យាបាលថា "កូនស្រីអើយ! ជំនឿរបស់នាងបានសង្គ្រោះនាងហើយ"។(លក.៨,៤៨) ។ល។

ទីពីរគឺ "សញ្ញា" ឬ"កាយវិការ" ព្រះយេស៊ូប្រើកាយវិការនិងប្រើសញ្ញាជាច្រើន ដើម្បីឲ្យអ្នកជំងឺដឹងថា ព្រះជាម្ចាស់កំពុងព្យាបាលគាត់ នេះជាលក្ខណៈរបស់មនុស្សដែលត្រូវការសញ្ញាអ្វីមួយ ។ ដូចជា ពេលព្រះអង្គ ព្យាបាល មនុស្សគ និងថ្លង់ "ទ្រង់ដាក់ព្រះអង្គុលីក្នុងត្រចៀកគាត់ ហើយស្តោះទឹកព្រះឱស្ឋយកទៅផ្តិតលើ អណ្តាតគាត់" (មក.៧,៣៣)។ ត្រង់ចំណុចនេះយើងអាចវាយតម្លៃបានថា គឺរបៀបប្រើឱសថនៅជំនាន់នោះ។ សន្តៈយ៉ាកុប ធ្លាប់និយាយថា ប្រសិនបើក្នុងព្រះសហគមន៍មានអ្នកជំងឺឲ្យហៅចាស់ទុំមកលាបប្រេងឲ្យគាត់ (មើល យក.៥,១៤)។ សម័យបុរាណ ប្រេងដែលពួកគាត់ប្រើគឺ ប្រេងអូលីវ ដែលជាថ្នាំសំខាន់មួយរបស់ពួកគេដែរ ។

សព្វថ្ងៃនេះ យើងប្រើឱសថច្រើនប្រភេទជាងអតីតកាល ។ តែសម្រាប់អ្នកមានជំនឿ ថ្នាំទាំងអស់នោះ គ្រាន់តែជាការព្យាបាលជំងឺខាងក្រៅ ដែលត្រូវមានការគាំទ្រពីការព្យាបាលខាងផ្លូវចិត្តដែរ ជាពិសេស សម្រាប់ គ្រីស្តបរិស័ទ ជំងឺត្រូវប្រយ័ត្នមួយទៀតគឺ "ជំងឺខាងផ្លូវវិញ្ញាណ" ដូចជា ការមើលតែខ្លួនឯង, ចិត្តលោភលន់, ចិត្តខឹង, ចិត្តមារ ។ល។ ជំងឺទាំងអស់នោះត្រូវការព្រះយេស៊ូជួយព្យាបាល ព្រោះឱសថធម្មតាមិនអាចព្យាបាលបានឡើយ ។

សរុបសេចក្តីបានថា ឱសថនានា អាចជួយព្យាបាលជំងឺខាងផ្លូវកាយបាន ប៉ុន្តែដោយសារមានជំងឺខាងផ្លូវចិត្តនិងជំងឺខាងផ្លូវវិញ្ញាណថែមទៀត ដែលអ្នកជំងឺត្រូវយកចិត្តទុកដាក់ស្វែងរកការជ្រោមជ្រែង ការលើកទឹកចិត្ត ដើម្បីជួយឲ្យឱសថដែលអ្នកជំងឺទទួល កាន់តែមានប្រសិទ្ធភាព ។ ហើយជាពិសេស សម្រាប់គ្រីស្តបរិស័ទយើងត្រូវការមិនគ្រាន់តែថ្នាំខាងផ្លូវកាយតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវការថ្នាំខាងផ្លូវវិញ្ញាណដែរ ។ សញ្ញាសំខាន់បំផុត ដែលចាត់ទុកថា ជាឱសថពីស្ថានបរមសុខមកគឺ "ព្រះកាយព្រះគ្រីស្ត" ដែលគ្រីស្តបរិស័ទកាតូលិក តែងតែទទួល ជាពិសេសសម្រាប់អ្នកជំងឺឬមនុស្សជិតស្លាប់ យើងហៅព្រះកាយនេះថា "ព្រះកាយស្បៀង" ដើម្បីឲ្យគាត់ជួបសេចក្តីសុខ និងអាចទៅជួបព្រះជាម្ចាស់ ដែលជាប្រភពនៃជីវិតរបស់ពួកគេគ្រប់ពេលវេលា ដោយមិនខ្វល់ខ្វាយអ្វីឡើយ ៕

# ការសម្តែងសិល្បៈដើម្បីប្រកាសដំណឹងល្អ


ថតដោយ សម្បត្តិ

ក្រុមសិល្បៈព្រះសហគមន៍កាតូលិកសន្តីម៉ារីញញឹមចំការទៀង បានរៀបចំកម្មវិធីការប្រកាសដំណឹងល្អតាមរយៈការសម្តែងសិល្បៈក្នុងទម្រង់ផ្សេងៗ លើវេទិការដ៏ធំទូលាយនៃព្រះសហគមន៍ កាលពីថ្ងៃទី២៤ មិថុនា ២០១៧ ដោយមានលោកអភិបាល អូលីវីយេ ជាអធិបតី។

ពេលនោះមានការចូលរួមសម្តែងពីក្រុមសិល្បៈ ព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង និងមានវត្តមានតារាល្បីៗមួយចំនួនមកពីរាជធានីភ្នំពេញ គឺមានលោកចន អេឡិចហ្សូរ៉ា កញ្ញាសូនីតា លោកម៉ាដូណា រួមជាមួយក្រុមរបស់ពួកគាត់។

ព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង រៀបចំកម្មវិធីនេះឡើង ក្នុងគោលបំណងប្រកាសដំណឹងល្អតាមរយៈការសម្តែងសិល្បៈវប្បធម៌ខ្មែរ ដើម្បីឲ្យប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានបានស្គាល់ព្រះសហគមន៍ឲ្យកាន់តែច្បាស់ឡើងថែមទៀត។ ម្យ៉ាងវិញទៀត ព្រះសហគមន៍ក៏មានបំណងចូលរួមថែរក្សាវប្បធម៌ដ៏ត្រចះត្រចង់ ដែលបុព្វបុរសខ្មែរបានបន្សល់ទុកសម្រាប់កូនចៅជំនាន់ក្រោយ បានដឹងបានឃើញ បានយល់អំពីតម្លៃនៃសិល្បៈវប្បធម៌ទាំងនោះផងដែរ។ ការសម្តែងសិល្បៈក្នុងមានដូចជា របាំជូនពរ របាំត្រុដិរបាំច្រូតស្រូវ ចម្រៀង កំប្លែង ជាដើម។

លោកអភិបាល អូលីវីយេ បានមានប្រសាសន៍ថា ពីថ្ងៃដែលព្រះសហគមន៍បានកសាងឆាកសិល្បៈនេះឡើង គឺលោកចង់ឲ្យមានការសម្តែងសិល្បៈផ្សេងៗជារៀងរាល់ខែ ដើម្បីឲ្យបងប្អូនទាំងអស់មានអំណរសប្បាយរួមគ្នា។ លោកបានបញ្ជាក់ថា ចាប់ពីខែកញ្ញាខាងមុខនេះ លោកនឹងបញ្ចូលប្រហែល១៥នាទី ដើម្បីសម្តែងអំពីរឿងសម្ព័ន្ធមេត្រីចាស់ ដើម្បីប្រកាសដំណឹងល្អខ្លះៗដល់ប្រជាជន។ លោកសង្ឃឹមថា ការសម្តែងសិល្បៈទាំងអស់នេះនឹងធ្វើឲ្យបងប្អូនទាំងអស់គ្នានៅភូមិចំការទៀង និងភូមិផ្សេងៗទៀតក្នុងឃុំគុសទាំងមូលមានអំណរសប្បាយដោយគិតថាយើងទាំងអស់គ្នាចូលរួមដើម្បីថែរក្សាសិល្បៈវប្បធម៌ខ្មែរជាមួយគ្នា។ ហើយលោកក៏បានជូនពរឲ្យបងប្អូនទាំងអស់ឲ្យមានសេចក្តីសង្ឃឹមជានិច្ច ដើម្បីកសាងគ្រួសារ ដើម្បីកសាងប្រទេសជាតិ ដើម្បីកសាងជីវិតផ្ទាល់ខ្លួនឲ្យកាន់តែមានការអភិវឌ្ឍន៍។

លោក អ៊ុំ សាមាន ជាប្រធានក្រុមសិល្បៈនៃព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង បានថ្លែងថា ការសម្តែងសិល្បៈនេះគឺគ្រាន់តែជាជំហានដំបូងដើម្បីឲ្យប្រជាពលរដ្ឋនៅជុំវិញព្រះសហគមន៍សន្តីម៉ារីញញឹមចំការទៀង បានស្គាល់អំពីគោលបំណងរបស់កម្មវិធីនេះសិន ហើយជំហានបន្ទាប់ គឺក្រុមសិល្បៈរបស់លោកនឹងរៀបចំឲ្យមានការសម្តែងផ្សេងៗដែលទាក់ទងនិងជីវិតរបស់ព្រះសហគមន៍និងបន្ថែមឲ្យមានការចូលរួមបង្ហាញសមត្ថភាពសិល្បៈពីបងប្អូនប្រជាពលរដ្ឋផងដែរ។ លោកបន្តថា នេះជាលើកទីពីរហើយដែលព្រះសហគមន៍បានរៀបចំការសម្តែងសិល្បៈសម្រាប់ចែកជូនប្រជាពលរដ្ឋបានទស្សនាការសម្តែងសិល្បៈផ្សេងៗរបស់ប្អូនៗដែលជាសិស្សនៃវិទ្យាល័យសន្តហ្វ្រង់ស្វ័រ រួមជាមួយតារាល្បីៗមួយចំនួនមកពីភ្នំពេញ។ នៅថ្ងៃខាងមុខ លោកនិងក្រុមការងារលោកនឹងធ្វើការពិភាក្សាជាមួយគណៈកម្មការព្រះសហគមន៍ ដើម្បីធ្វើការរិះគិតអំពីដំណើរការនៃការអភិវឌ្ឍកម្មវិធីសម្តែងសិល្បៈនេះ ហើយអាចនឹងមានការសម្តែងសិល្បៈបែបបុរាណ ដែលកូនខ្មែរមួយចំនួនស្ទើរតែមិនដែលបានទស្សនា និងមិនដឹងថា នេះជារបស់ខ្មែរទៀតផងដែលដូចជា ចាប៉ី អាយ៉ៃ យីកេ ល្ខោន សៀកខ្មែរជាដើម។ លោកសាមាន ក៏បានកោតសរសើរស្នាដៃសិល្បៈនៃការសម្រាប់របស់ក្មេងៗ ដែលមានទេពកោសល្យខ្ពស់ក្នុងការសម្តែងយ៉ាងមានភាពរស់រវើក។

លោកស្រី ចន្ថា ជាប្រជាពលរដ្ឋមកពីភូមិសែនអោក ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ដែលបានចូលរួមកម្មវិធីនេះថ្លែងថា នេះជាលើកទីមួយសម្រាប់លោកស្រីផ្ទាល់ដែលបានមកមើលការសម្តែងសិល្បៈនេះ វាជាកម្មវិធីមួយល្អដែលអាចជួយឲ្យបងប្អូនអ្នកស្រុកបានស្គាល់អំពីសិល្បៈប្រពៃណីខ្មែរ ហើយជាពិសេសអាចឲ្យក្មេងៗមានឱកាសក្នុងការសម្តែងទៀត។ លោកស្រី បន្តថា ក្រោយពីបានទស្សនាការសម្តែងសិល្បៈរួមមកមិនថា រូបលោកស្រីផ្ទាល់ មិនថាអ្នកភូមិដទៃទៀតបានសាទរយ៉ាងខ្លាំងក្នុងការគាំទ្រកម្មវិធីបែបនេះ ព្រោះយើងជាខ្មែរត្រូវតែខិតខំថែរក្សាប្រពៃណីវប្បធម៌ខ្មែរ ដោយមានទាំងអ្នកសម្តែងមានទាំងអ្នកទស្សនា ដើម្បីបញ្ជូនបន្តទៅក្មេងៗជំនាន់ក្រោយៗទៀត។ លោកស្រី ក៏បានសំណូមពរថា ប្រសិនបើមានការចូលរួមសម្តែងពីអ្នកភូមិទៀតកាន់តែប្រសើរ ព្រោះថា អាចឲ្យពួកគាត់បញ្ចេញទេពកោសល្យផ្ទាល់ខ្លួន និងចូលរួមការសប្បាយជាមួយគ្នាផងដែរ។

គួរបញ្ជាក់ផងដែរថា ព្រះសហគមន៍សន្តីម៉ារីញញឹម ដែលស្ថិតក្នុងភូមិចំការទៀង ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ បានកសាងឆាកសិល្បៈធំមួយនេះដោយយកគំរូពីឆាកសិល្បៈនៅភូមិវប្បធម៌ ខេត្តសៀមរាបហើយបានសម្ភោធដាក់ឲ្យប្រើប្រាស់នៅចុងឆ្នាំ២០១៦កន្លងមក។ យើងក៏អាចនិយាយបានថា គ្រប់បងប្អូនប្រជាពលរដ្ឋទាំងអស់ដែលបានមកឃើញឆាកសិល្បៈនៅភូមិចំការទៀងនេះ គឺដូចជាបានទៅដល់ទឹកដីនៃខេត្តសៀមរាបដូច្នោះដែរ ព្រោះថាឆាកនេះបានរំលេចនូវក្បូរក្បាច់រចនាយ៉ាងល្អឯកនៅកណ្តាលវាលស្រែ។

# គណៈកម្មការពិធីបុណ្យសម្រេចបានសៀវភៅក្បួនពិធីបុណ្យថ្មី

សៀវភៅក្បួនពិធីបុណ្យថ្មីដែលបានរៀបចំឡើងរយៈពេលជាង១០ឆ្នាំមកនេះ បានសម្រេចចេញជារូបរាង និងបានចែកចាយឲ្យប្រើប្រាស់នៅតាមព្រះសហគមន៍នានាក្នុងប្រទេសកម្ពុជា។ សៀវភៅក្បួនពិធីអភិបូជាដែលមានក្របពណ៌ក្រហម និងមានរូបឈើឆ្កាងនៃមរណសាក្សីនៃប្រទេសកម្ពុជា ត្រូវបានបកប្រែឲ្យសមស្របតាមក្បួនពិធីនៃទីក្រុងរ៉ូម។

លោកអភិបាលអន់តូនីសាមី ស៊ូសៃរាជ្យ ជាអភិបាលទទួលបន្ទុកគណៈកម្មការពិធីបុណ្យនៃព្រះសហគមន៍កាតូលិកនៅកម្ពុជា បានមានប្រសាសន៍ថា ក្នុងពេលកន្លងមក យើងបានប្រើប្រាស់របៀបនៃការប្រារព្ធពិធីបុណ្យរបស់យើងជាភាសាខ្មែរ ដែលលោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍បានបកប្រែ។ ហើយសព្វថ្ងៃនេះ យើងមានកិត្តិយសប្រើសៀវភៅអភិបូជារបៀបថ្មី។

សៀវភៅក្បួនពិធីអភិបូជាថ្មីនេះ មានកម្រាស់ជាង៨០០ទំព័រ ប្រើប្រាស់សម្រាប់គ្រប់ពិធីបុណ្យទាំងអស់ក្នុងព្រះសហគមន៍ ដែលមានរៀបរាប់អំពីអត្ថន័យនៃពិធីនីមួយៗ របៀបរៀបចំមានទាំងកាយវិការ ពាក្យសំដី និងសម្ភារៈប្រើប្រាស់ពាក្យសូត្រក្នុងពិធីបុណ្យធំៗជាដើម។

កាលពីដើមឆ្នាំ២០១៧នេះ លោកអភិបាលនៃព្រះសហគមន៍កម្ពុជាក្នុងឱកាសចូលគាល់សម្តេចប៉ាប នៅក្នុងទីក្រុងរ៉ូម ។ អស់លោកបាននាំយកនូវសៀវភៅក្បួនពិធីអភិបូជាថ្មីនេះជូនដល់លោកកាឌីណាល់ទទួលបន្ទុកផ្នែកពិធីបុណ្យដើម្បីពិនិត្យ។

លោកអភិបាលអន់តូនីសាមី បន្ថែមថា ក្នុងរយៈពេលជាង១០ឆ្នាំនេះ គណៈកម្មការអន្តរភូមិភាគនេះមានសកម្មភាពប្រជុំរៀងរាល់មួយខែម្តងដែលមានពេល ៣ឬ៤ថ្ងៃ។ លោកអភិបាលបញ្ជាក់ថា "ការងាររបស់យើងគ្មានអ្វីដែលឲ្យយើងអួតខ្លួនទេ ព្រោះយើងដឹងអំពីសមត្ថភាពរបស់យើង យើងជាកូនសិស្សទាំងអស់គ្នា....ប៉ុន្តែយើងរួមជាមួយក្រុមជាកម្លាំងពិសេស"។ គណៈកម្មការពិធីបុណ្យមានសមាជិកប្រមាណជិត២០នាក់ដែលក្នុងនោះមានអ្នកជំនាញ និងអ្នកបច្ចេកទេសជាច្រើនផ្នែកចូលរួម ដូចជា ព្រះគម្ពីរ ភាសាឡាតាំង ភាសាខ្មែរ ភាសាថៃ អ្នកបកប្រែសេចក្តីពីសន្និបាតវ៉ាទីកង់ទី២ និងអ្នកបច្ចេកទេសកុំព្យូទ័រ។

កាលពីសម័យមុនឆ្នាំ១៩៦៥ ព្រះសហគមន៍កាតូលិកទូទាំងសកលលោកបានរៀបចំពិធីបុណ្យតាមរបៀបទីក្រុងរ៉ូម ដោយក្បួនពិធីគឺមានជាភាសាឡាតាំងទាំងអស់ ប៉ុន្តែក្រោយមហាសន្និបាតវ៉ាទីកង់ទី២ បានធ្វើឲ្យមានការផ្លាស់ប្តូរមួយក្នុងក្បួនពិធីអភិបូជា ដោយបានអនុញ្ញាតឲ្យប្រទេសនីមួយៗអាចប្រើប្រាស់ភាសារបស់តំបន់ដើម្បីលើកតម្កើងព្រះជាម្ចាស់។

ក្រោយមកប្រទេសនីមួយៗបានខិតខំប្រឹងប្រែងដើម្បីបកប្រែក្បួនពិធីអភិបូជានេះ ជាភាសារៀងៗខ្លួន ហើយព្រះគម្ពីរក៏ត្រូវបានបកប្រែជាភាសាខ្មែរដើម្បីប្រារព្ធក្នុងអភិបូជាផងដែរ។

លោកអភិបាលអន់តូនីសាមី បានបញ្ជាក់ថា មូលហេតុចម្បងនៃការរិះគិតកែសម្រួលអំពីសៀវភៅក្បួនពិធីអភិបូជានេះសារជាថ្មី គឺ "ដោយសារការវិវត្តន៍នៃភាសាខ្មែរ និងអត្ថន័យនៃភាសាដើមរបស់ឡាតាំង....។ ក្រោយវ៉ាទីកង់ទី២គេបកប្រែតាមរបៀបខ្លួនឯងយល់។ តាំងពីពេលគេប្រើ ឥឡូវគេឃើញថា ខ្លះៗអត់ត្រូវ(តាម)ភាសាឡាតាំងទេ ដល់ពេលឥឡូវគ្រប់ភាសាគេកែសម្រួលតាមអត្ថន័យដើមភាសាឡាតាំង...។ ចំណុចតូចមួយ(គឺ)ការវិវត្តន៍នៃភាសាខ្មែរ យើងមិនមែនជាម្ចាស់ទេ វាត្រូវតែប្រែប្រួល ដប់ឆ្នាំទៀតត្រូវប្រែប្រួល ហើយជំនាន់ពេលនោះគេនឹងគិតបន្ថែម(ថា) ផ្លាស់ប្តូរ កែបានរហូត"។

លោកអភិ បាលបានមានប្រសាសន៍ឲ្យដឹងថា ក្នុងការបកប្រែពីភាសាឡាំងមកខ្មែរ គឺគណៈកម្មាការនេះបានរិះគិតជាច្រើនអំពីអត្ថន័យនៃពាក្យដែលគ្រីស្តបរិស័ទកាតូលិកធ្លាប់ប្រើពីមុនមកដើម្បីឲ្យវាមានលក្ខណៈស៊ីជម្រៅកាន់តែខ្លាំងទៅលើជំនឿលើព្រះជាម្ចាស់។ លោកអភិបាលបន្ថែមថា "យើងបានឃើញឃ្លាមួយនៅលើលិខិតឆ្លងដែនរបស់កម្ពុជា បានសរសេរថា In the name of His Majesty the King of Cambodia ឃ្លានោះប្រែជាខ្មែរថា ក្នុងព្រះនាមព្រះបរមនាមរបស់ព្រះមហាក្សត្រ....ដូច្នេះយើងកែសម្រួលអ្វីដែលយើងធ្លាប់(ប្រើ) ហើយ។ ឥឡូវយើងគិតបន្តិច ដើម្បីស្រួលបន្តិច ច្បាស់ជាងមុនបន្តិច"។

ទោះជាយ៉ាងណាក្តីនៅតាមព្រះសហគមន៍នាភូមិភាគកំពង់ចាមបានចាប់ផ្តើមប្រើប្រាស់ និងមានឃ្លាឆ្លើយតបនៅក្នុងពិធីបុណ្យតាមរបៀបថ្មីនេះ តាំងពីខែឧសភាម្ល៉េះ។ ហើយនៅតំបន់ខ្លះរបស់ព្រះសហគមន៍ភូមិភាគភ្នំពេញ ក៏បានប្រើប្រាស់ផងដែរ។

សែត សោភា អាយុ២៥ ជាទទួលខុសត្រូវផ្នែកបណ្ណាល័យនៅព្រះសហគមន៍កំពង់ចាមក្រុង បានឲ្យដឹងថាពាក្យឆ្លើយមួយចំនួនដែលផ្លាស់ប្តូរមានលក្ខណៈងាយស្រួលយល់ និងងាយស្រួលពន្យល់ដល់អ្នកដទៃច្រើនជាងមុន។ សោភានិយាយថា "(ការឆ្លើយតប)ខុសគ្នាខ្លះៗ។ សូមព្រះវិញ្ញាណគង់នៅជាមួយលោកផង។ អត្ថន័យវាស៊ីជម្រៅជាងមុន និងល្អ។ ពេលគេសួរយើងពន្យល់គេងាយស្រួល"។

បច្ចុប្បន្ន សៀវភៅក្បួនពិធីអភិបូជាថ្មីត្រូវបានចែកចាយទៅកាន់បូជាចារ្យក្នុងប្រទេសកម្ពុជាដើម្បីប្រារព្ធពិធីបុណ្យ ហើយសៀវភៅសម្រាប់គ្រីស្តបរិស័ទកំពុងរៀបចំដើម្បីបោះពុម្ពនិងចែកចាយ។ តាមប្រសាសន៍របស់កញ្ញាប៉ាត ចាន់ណោង ជាអ្នករចនាទំព័រនៅមណ្ឌលអប់រំជំនឿព្រះសហគមន៍កាតូលិកបានឲ្យដឹងថា សៀវភៅអភិបូជាសម្រាប់គ្រីស្តបរិស័ទដែលមានរួមទាំងចម្រៀងនឹងអាចបោះពុម្ពរួចរាល់ និងចែកចាយឲ្យប្រើប្រាស់នៅទូទាំងប្រទេសបាននៅចុងឆ្នាំ២០១៧នេះ។ ចាន់ណោង "ជិតចប់ហើយ នូវបន្ថែមបទចម្រៀងថ្មីៗបន្ថែម។ អាស្រ័យលើលោកអភិបាលគាត់នៅថែមថយ។ អាចប្រើចុងឆ្នាំនេះបាន។ លើកនេះខ្ញុំកែចប់ហើយ"។

ដោយ កញ្ញា



ថតដោយ លីហៀង

## សម្តេចប៉ាបតែងតាំងប្រធានថ្មីនៃគណៈកម្មការគោលលទ្ធិនៃជំនឿ

វិទ្យុវ៉ាទីកង់បានរាយការណ៍ថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីសប្តាហ៍មុនបានតែងតាំង អគ្គអភិបាលមួយរូបសម្រាប់តំណែងជាប្រធាន គណៈកម្មការគោលលទ្ធិនៃជំនឿ ។

ប្រភពដដែលបានរាយការណ៍ថា លោកអគ្គអភិបាល លូី ឡាដារៀ ត្រូវបានតែងតាំងជាប្រធានគណៈកម្មការនេះ ជំនួសលោកកាឌីណាល់ ជ័ហាត លូតវិង មូលឺ ក្រោយពេលដែលបានទទួលតំណែងនេះ នៅក្នុងអាណត្តិ៥ ឆ្នាំកន្លងទៅមកនោះ ។

ប្រភពដដែលបានប្រកាសថា លោកអគ្គអភិបាល ឡាដារៀ ត្រូវបានគេដឹងថា គឺជាបព្វជិតនៃក្រុមជេស៊ូតមកពីប្រទេសអេស្ប៉ាញ ដែលលោកបានចំណាយពេលវេលារាប់សិបឆ្នាំបង្រៀន នៅសាកលវិទ្យាល័យធម្មសភាពនៃព្រះសហគមន៍ នៅក្នុងទីក្រុងរ៉ូម ហើយក៏បានបម្រើការងារនៅក្នុងគណៈកម្មការនេះស្រាប់តាំងពីឆ្នាំ ២០០៨ មក ។

តាមការគ្រោងទុក លោកអគ្គអភិបាល ឡាដារៀ នឹងចូលជំនួសគ្រប់កិច្ចការដែលលោក កាឌីណាល់ ជ័ហាត លូតវិង មូលឺទទួលខុសត្រូវរាប់តាំងពីប្រធានគណៈកម្មការព្រះគម្ពី និងគណៈកម្មការអេប់រំជំនឿអន្តរជាតិ ។ល។

លោក កាឌីណាល់ ជ័ហាត លូតវិង មូល័រ គឺបានឈានចូលដល់អាណត្តិរបស់លោក នៅត្រឹមថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០១៧ តែម្តង ។

## សម្តេចប៉ាបអធិដ្ឋានសម្រាប់ប្រជាពលរដ្ឋនៅក្នុងទីក្រុងរ៉ូម

កាលពីថ្ងៃទី២៩ មិថុនា ២០១៧កន្លងទៅនេះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានចូលរួមអធិដ្ឋានជូនប្រជាពលរដ្ឋនៅក្នុងទីក្រុងរ៉ូម នាថ្ងៃដែលគ្រីស្តបរិស័ទនៅទីនោះ អបអរព្រឹកពីការតែងតាំងសន្តសិលា និងសន្តយ៉ូហានប្រចាំនៅរដ្ឋធានី នៃប្រទេសអ៊ីតាលី ។

ដោយអធិដ្ឋានបួងសួងតាមបង្អួចជាមួយនឹងគ្រីស្ត-បរិស័ទជាច្រើននាក់ ដែលប្រមូលផ្តុំគ្នា នៅទីលានសន្តសិលា សម្តេចប៉ាប បានថ្លែងរំលឹក គ្រីស្តបរិស័ទ អំពីការប្រលមមួយចំនួន ហើយនឹងជំរុញគ្រីស្តបរិស័ទយកចិត្តទុកដាក់នឹងការបម្រើព្រះសហគមន៍ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា ទោះបីជារងនូវទុក្ខទោសយ៉ាងណាគឺ សូមក្សោខ្លួន និងប្រតិបត្តិឲ្យជាប់ជាមួយនឹងលោក សិលា និងលោកយ៉ូហាន ដែលបានដើរតាម មាគ៌ានៃព្រះជាម្ចាស់ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងថា លោកសិលា និងលោក យ៉ូហាន គឺតែងតែយកចិត្តទុកដាក់ជួយគ្រីស្តបរិ-ស័ទទាំងអស់ឲ្យមានលទ្ធភាព រំដោះខ្លួនចេញពីការគំរាមកំហែងពីមាសត្រូវនានា ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានសង្កត់ធ្ងន់ថា សត្រូវនៅក្នុងន័យនេះ គឺគ្មានអ្វីក្រៅអំពីអំពើបាបនោះទេ ប៉ុន្តែព្រះជាម្ចាស់អាចបង្ហាញផ្លូវយើង តាមរយៈការសារភាពបាប ។

## សម្តេចប៉ាបអំពាវនាវឲ្យមានសន្តិភាព និង ការផ្សះផ្សាយនៅវេណេហ្ស៊ុយអេឡា

វិទ្យុវ៉ាទីកង់បានរាយការណ៍ថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីថ្ងៃអាទិត្យ ដើមសប្តាហ៍កន្លងទៅថ្មីៗនេះ បានអំពាវនាវឲ្យមានការផ្សះផ្សារ នៅក្នុងប្រទេសវេណេហ្ស៊ុយអេឡា ។

ថ្លែងនៅទីលានសន្តសិលា ទៅកាន់គ្រីស្តបរិស័ទដែលជួបជុំគ្នានៅទីនោះ សម្តេចប៉ាបក៏បានអធិដ្ឋានរួមជាមួយនឹងគ្រីស្តបរិស័ទ និងអ្នកទេសចរ ទាំងអស់ដែលមកលេងនៅទីលានសន្តសិលាថា សាមគ្គីភាព គឺជាចំណុចសំខាន់ណាស់របស់ប្រជាពល-រដ្ឋវេណេហ្ស៊ុយអេឡា ។

ប្រភពដដែលបានបន្តថា ការអធិដ្ឋាននេះ គឺបានធ្វើឡើងនៅមុនថ្ងៃឯករាជ្យនៃប្រទេស វេណេហ្ស៊ុយអេឡា នៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៧។ សម្តេចប៉ាបបានថ្លែងថា "ខ្ញុំសូមសន្យានឹងនឹងអធិដ្ឋានដោយផ្ទាល់បន្ថែមទៀតសម្រាប់ប្រជាជននៅវេណេហ្ស៊ុយអេឡា ហើយក៏សូមបង្ហាញនូវភាពជិតស្និទ្ធ សេចក្តីសោកសង្រេង ទៅនឹងក្រុមគ្រួសារដែលមានអ្នកដែលបានបាត់បង់សមាជិកគ្រួសារ និងកូនៗរបស់ពួកគេនៅក្នុងកន្លែងចលាចលនៅតាមដងផ្លូវនានា។

គួររំឭកថា ប្រទេសវេណេហ្ស៊ុយអេឡា នៅពេលនេះ កំពុងតែវឹកវរ ដោយសារតែការផ្ទុះការតវ៉ាមួយ ដែលបានកើតមានឡើងតាំងតែពីខែមីនាដោយវិបត្តិនយោបាយនេះ បានសម្លាប់មនុស្សប្រមាណជាជិត១០០នាក់។

នៅក្នុងឱកាសនោះ សម្តេចប៉ាបក៏បានជំរុញឲ្យគ្រប់ភាគី ស្វែងរកដំណោះស្រាយសន្តិភាពតាមដំណោះស្រាយនៃលទ្ធិប្រជាធិបតេយ្យ ឆ្លើយតបទៅនឹងវិបត្តិ ។

## សម្តេចប៉ាប ថ្លែងទៅកាន់កិច្ចប្រជុំនៃអង្គការអាមេរិកឡាទិន និង អ៊ីតាលី

កាលពីថ្ងៃសុក្រសប្តាហ៍មុននេះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានអនុញ្ញាតទទួលជួបតំណាងនៃអង្គការអាមេរិកឡាទិននិងអ៊ីតាលី ដែលជាស្ថាប័នមួយដែលកំពុងតែសម្របសម្រួល និងអភិវឌ្ឍន៍នៅក្នុងតំបន់ ។

នាឱកាសនោះ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងទៅកាន់សមាជិកនៃអង្គការនោះថា អង្គការគួរតែធ្វើសកម្មភាពដោយឈរនៅលើ គោលការណ៍បី គឺរួមមានកំណត់ឲ្យឃើញនូវអ្វីដែលជាសក្តានុពល សកម្មភាពសម្របសម្រួល និង ការឈានឆ្ពោះទៅមុខ។

សម្តេចប៉ាបបានថ្លែងថា បណ្តាប្រទេសនៅអាមេរិកឡាទិន គឺជាប្រទេសដែលសំបូរទៅដោយប្រវត្តិសាស្ត្រ វប្បធម៌ និងធនធានធម្មជាតិ ដែលសុទ្ធតែជាធនធានល្អសម្រាប់ប្រជា-ពលរដ្ឋ ហើយត្រូវតែប្តេជ្ញាថែរក្សាវាឲ្យបានតាមរយៈសាមគ្គីភាព ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយពលរដ្ឋនៅតំបន់ គឺកំពុងតែប្រឈមមុខនឹងវិបត្តសង្គម និងសេដ្ឋកិច្ចជាបន្តបន្ទាប់ ដែលគួរតែរិះគិត ដើម្បីញុំាងឲ្យតំបន់ គេចចេញពីភាពក្រីក្រ ភាពគ្មានការងារធ្វើ និងវិសមភាពសង្គមព្រមទាំងបញ្ចប់នូវការធ្វើអាជីវកម្ម និងការរំលោភបំពានសិទ្ធិសេរីភាពទាំងឡាយ។ សម្តេចប៉ាបបានជំរុញឲ្យតំបន់រិះរកចម្លើយ ដើម្បីឆ្លើយនឹងភាពចាំបាច់ទាំងឡាយសម្រាប់បុត្រធីតានៅក្នុងប្រទេស ដែលកំពុងតែ ស្រេកឃ្លានចង់បាន ហើយសម្តេចប៉ាបក៏បានជំរុញគ្រប់ភាគីប្រើប្រាស់នូវវប្បធម៌នៃការសន្ទនា។ ការសន្ទនាគឺសំខាន់ណាស់ ដើម្បីដោះស្រាយបញ្ហា ដែលកើតមានដោយសារតែ វិបត្តិសង្គម និងនយោបាយ ព្រមទាំងវិបត្តិសេដ្ឋកិច្ច ។

## អង្គការសហប្រជាជាតិ កាត់បន្ថយថវិកា៦០០លានដុល្លារសម្រាប់បេសកកម្មថែរក្សាសន្តិភាព

កាលពីថ្ងៃសុក្រ ទី៣០ ខែមិថុនា អង្គការសហប្រជាជាតិ បានយល់ព្រមកាត់បន្ថយថវិកាជិត៦០០លានដុល្លារសម្រាប់ថវិកាចំណាយសម្រាប់ការបំពេញបេសកកម្មថែរក្សាសន្តិភាពរបស់ខ្លួននៅលើពិភពលោក។

បណ្តាញសារព័ត៌មានបស្ចិមប្រទេសបានរាយការណ៍ថា ការសម្រេចបែបនេះគឺធ្វើឡើងបន្ទាប់ពីមានសម្ពាធពីសហរដ្ឋអាមេរិកដែលប្រកាសកាត់បន្ថយការផ្តល់មូលនិធិរបស់ខ្លួនដល់អង្គការនេះ។

មហាសន្និបាតអង្គការសហប្រជាជាតិ បានព្រមព្រៀងគ្នាចំពោះថវិកាប្រចាំឆ្នាំនេះដែលត្រូវបានរំពឹងថានឹងមានសរុបចំនួន៧,៣ពាន់លានដុល្លារ។

ក្រុមប្រទេសជាសមាជិកអង្គការសហប្រជាជាតិបានយល់ព្រមលើថវិកាចំនួន៦,៨ពាន់លានដុល្លារ សម្រាប់ការផ្តល់លុយដល់បេសកកម្មចំនួន១៤ ប៉ុន្តែថវិកាបន្ថែមចំនួន៥០០លានដុល្លារសម្រាប់បេសកកម្មថែរក្សាសន្តិភាពនៅប្រទេសហៃទី និងតំបន់ដាហ្វួរ នៅប្រទេសស៊ូដង់ នឹងទទួលបានការយល់ព្រមជាចុងក្រោយនៅខែធ្នូ។

សហរដ្ឋអាមេរិក ដែលជាអ្នកផ្តល់លុយដ៏ច្រើនបំផុតសម្រាប់ការថែរក្សាសន្តិភាពនោះ បានស្វែងរកការកាត់បន្ថយប្រាក់ជំនួយជិត១ពាន់លានដុល្លារសម្រាប់កិច្ចព្រមព្រៀងផ្តល់ថវិកានេះ ហើយសហភាពអឺរ៉ុបក៏បានជំរុញឱ្យមានការរក្សាទុកថវិកាមួយចំនួនផងដែរដែលនាំឱ្យថវិកាសម្រាប់បេសកកម្មថែរក្សាសន្តិភាពធ្លាក់មកនៅត្រឹម៧,៣ពាន់លានដុល្លារ។

លោកស្តេហ្វានី ឌូចារិក អ្នកនាំពាក្យអង្គការសហប្រជាជាតិ បាននិយាយថា "ការផ្តល់ថវិកានេះ គឺពិតជាមានចំនួនតិចជាងអ្វីដែលយើងមានកាលពីឆ្នាំមុន ប៉ុន្តែអង្គការពិភពលោកនេះ នឹងខំប្រឹងប្រែងដើម្បីធានាថា អាណត្តិនៃការបំពេញបេសកម្មទាំងនោះត្រូវបានប្រព្រឹត្តទៅ៕

# អត្ថាធិប្បាយព្រះគម្ពីរខែមេសា ឆ្នាំ ២០១៧ ដោយ លោករឿន ផ័ត្រសិរី



**អាទិត្យទី ៦ ខែសីហា ២០ ១៧ បុណ្យឱទ្បារិក ព្រះយេស៊ូ បញ្ចេញរស្មីពណ្ណរាយ**



ការបញ្ចេញរស្មីពណ្ណរាយ ជាព្រឹត្តិការណ៍ដែលព្រះយេស៊ូបង្ហាញសភាវៈជាព្រះជាម្ចាស់។ គ្រីស្តបរិស័ទត្រូវដឹងថា ព្រះយេស៊ូមិនគ្រាន់តែជាលោកយេស៊ូ ដែលជាមនុស្សដូចយើងតែប៉ុណ្ណោះទេ ប៉ុន្តែព្រះអង្គជាព្រះជាម្ចាស់ដែរ។ ព្រះអម្ចាស់ព្រះបិតាបានបញ្ជាក់ឋានៈជា "ព្រះបុត្រា" របស់ព្រះអង្គថា "នេះជាបុត្រជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់ ចូរស្តាប់ព្រះអង្គចុះ!"។(**មថ ១៧,៥**)។ យើងស្តាប់ការប្រៀនប្រដៅរបស់ព្រះយស៊ូ ក៏ដូចជាយើងស្តាប់ព្រះជាម្ចាស់ជាព្រះបិតាដែរ។

រីឯលោកអេលី ជាតំណាងអស់ព្យាការី និងលោកម៉ូសេ ជាតំណាងនៃច្បាប់ជនជាតិយូដា។ អ្វីៗដែលនិយាយក្នុងសម្ព័ន្ធមេត្រីចាស់ បានពេញលក្ខណៈក្នុងព្រះយេស៊ូនៅសម្ព័ន្ធមេត្រីថ្មី។

អត្ថន័យថ្ងៃអាទិត្យនេះ គឺទីមួយសូមឲ្យបងប្អូនបង្ហាញរស្មីរបស់ព្រះគ្រីស្ត ឲ្យអ្នកដទៃតាមរយៈកិច្ចការល្អៗ ដូចព្រះយេស៊ូបានបង្រៀនយើង។ ទីពីរគឺ យើងត្រូវដឹងថាសិរីរុងរឿង របស់ព្រះយេស៊ូ គឺជាក្តីសង្ឃឹមរបស់យើង ព្រោះនៅពេលអនាគត យើងនឹងទទួលសិរីរុងរឿង ដូចព្រះអង្គនៅស្ថានបរមសុខដែរ។

**អាទិត្យទី ១៣ ខែសីហា ២០១៧៖ អាទិត្យទី ១៩ រដូវធម្មតា**

មួយថ្ងៃទៅមួយថ្ងៃ យើងធ្វើការរកស៊ុចិញ្ចឹមជីវិត។ ការងារនាំឲ្យយើងមានតម្លៃ ប៉ុន្តែ យើងត្រូវរកពេលសម្រាក ហើយអធិដ្ឋានដែរ ដូចព្រះយេស៊ូតាមព្រះបន្ទូលថ្ងៃនេះ។ ព្រះអង្គចិញ្ចឹមមនុស្ស អប់រំពួកគេឲ្យស្គាល់ព្រះរាជ្យរបស់ព្រះជាម្ចាស់។ ព្រះអង្គបញ្ចប់ថ្ងៃ ដោយការ "អធិដ្ឋាន" ព្រោះការអធិដ្ឋាន ធ្វើឲ្យព្រះអង្គជិតស្និទ្ធជាមួយព្រះបិតា។ការអធិដ្ឋាននេះ ជួយយើងមានជីវិតនិងកំលាំងឡើងវិញ។

ព្រះអង្គយាងលើទឹកសមុទ្រដែលកំពុងមានខ្យល់ទៅរកពួកសាវ័កក្នុងទូក ហើយលោកសិលាសុំដើរទៅរកព្រះអង្គលើទឹក ប៉ុន្តែពេលឃើញខ្យល់ក៏ចាប់ផ្តើមលិចទឹក ពេលនោះព្រះយេស៊ូបានលូក ដៃជួយគាត់។ ជីវិតយើងគ្រីស្តបរិស័ទ ក៏ដូចលោកសិលាដែរ គឺទោះបីយើងមានជំនឿ ប៉ុន្តែពេលខ្លះមាន រឿងបារម្ភជួបបញ្ហាឧបសគ្គ ក៏ធ្លាក់ទឹកចិត្ត។ លោកសិលាសំឡឹងមើល និងតម្រង់ទៅព្រះយេស៊ូយ៉ាងណា សូមឲ្យបងប្អូនទូលអង្វរព្រះអម្ចាស់យេស៊ូគ្រីស្ត ដូចលោកសិលាយ៉ាងនោះដែរ។ ពិតមែនព្រះអង្គនឹងជួយយើងឲ្យផុតពីឧបសគ្គជាមិនខាន។

**អាទិត្យទី ២០ ខែសីហា ២០១៧៖ អាទិត្យទី ២០ រដូវធម្មតា**

រឿងស្រីសាសន៍កាណាន ដែលជនជាតិអ៊ីស្រាអែលចាត់ទុកថា ជាជនកសាសន៍មិនត្រូវរាប់អាន ព្រោះនាំឲ្យបាត់ភាពបរិសុទ្ធ។ របៀបដែលនាងធ្វើនោះ គួរចាប់អារម្មណ៍និងជាគំរូ សម្រាប់ការ អធិដ្ឋានរបស់យើងមែន។ ព្រោះនាងអធិដ្ឋានអង្វរព្រះយេស៊ូ ដោយស្មោះអស់ពីចិត្ត គ្មានរកទីពឹងណាទៀត ទេ ក្រៅពីអង្វរព្រះអង្គ។ ពេលយើងជួបបញ្ហាឧបសគ្គ ជួនកាលជាបញ្ហា ដែលលើសសមត្ថភាពរបស់យើង ដូចរឿងខ្មោចចូលកូនស្រីរបស់ស្ត្រីនោះ ពិតជាហួសសមត្ថភាពការព្យាបាលហើយ។ដូច្នេះ ពេលយើងត្រូវមារល្បួង មានបញ្ហា ដែលពិបាកដោះស្រាយ។ សូមធ្វើដូចស្ត្រីសាសន៍កាណាននេះ គឺអង្វរព្រះអង្គជួយ។

ចំណុចទីពីរ ជួនកាលព្រះយេស៊ូ អនុញ្ញាតឲ្យយើងជួបបញ្ហាឧបសគ្គខ្លះ ប្រហែលព្រះអង្គចង់ សាកល្បងលជំនឿរបស់យើងដែរ។ ព្រោះការពិសោធន៍ជំនឿល្អបំផុត មិនមែនពេលយើងសុខស្រួលទេ ផ្ទុយទៅវិញ គឺពេលដែលយើងជួបបញ្ហា នោះគឺពេលល្អដើម្បីព្រះជាម្ចាស់មើលជំនឿរបស់យើង។ ស្ត្រីនោះ ទោះបីព្រះយេស៊ូដាក់ពាក្យធ្ងន់ប្រៀបធៀបដូចនាងជាកូនឆ្កែ ប៉ុន្តែនាងបានប្រាប់ថា "កូនឆ្កែស៊ីកំទេចអាហារដែលជ្រុះពីតុរបស់ម្ចាស់វា"។ មានន័យថា នាងជឿថា ព្រះជាម្ចាស់ឲ្យប្រជាជាតិនានាទទួលព្រះពរ តាមរយៈព្រះអង្គដែលជាជនជាតិអ៊ីស្រាអែល។ ព្រះសហគមន៍ជាប្រជាជនថ្មីរបស់ព្រះជាម្ចាស់ យើងត្រូវជាស្ពាននៃព្រះពររបស់ព្រះជាម្ចាស់សម្រាប់បងប្អូនជនរួមជាតិយើងទាំងអស់ដែរ។

**អាទិត្យទី ២៧ ខែសីហា ២០១៧៖ អាទិត្យទី ២១ រដូវធម្មតា**

"តើមនុស្សទាំងឡាយថា បុត្រមនុស្សជានរណា?" ជាសំណួរដ៏សំខាន់មួយដែរ សម្រាប់យើងអំពីព្រះយេស៊ូគ្រីស្ត។ ជីវិតយើងសព្វថ្ងៃ មានតម្លៃ និងមោទនភាពណាស់ ព្រោះជីវិតយើងភ្ជាប់ជាមួយព្រះយេស៊ូគ្រីស្ត។ ប៉ុន្តែសម្រាប់យើង ព្រះយេស៊ូមានឥទ្ធិពលអ្វីខ្លះលើយើង? តើយើងជឿព្រះអង្គ តាមទំនៀមទំលាប់ ឬជឿដោយចិត្តជឿជាក់យ៉ាងពិតប្រាកដ? តើយើងបន្តការស្វែងយល់ព្រះអង្គជារៀងរាល់ថ្ងៃ ឬទុកព្រះអង្គតែក្នុងព្រះវិហារ?

ព្រះអង្គប្រាប់លោកសិលាថា "លើផ្ទាំងសិលានេះ ខ្ញុំនឹងសង់ព្រះសហគមន៍របស់ខ្ញុំ។ សេចក្តីស្លាប់ ពុំមានអំណាចលើព្រះសហគមន៍នេះបានឡើយ" (**មថ ១៦,១៨**) ដោយសារ ព្រះបន្ទូលនេះ ហើយព្រះសហគមន៍កាតូលិកយើង បានបន្តអំណាចរបស់ព្រះអង្គតាមរយៈសន្តៈសិលា ដែលយើងហៅថា "សម្តេចប៉ាប" ហើយយើងបានបន្តអំណាចរបស់ក្រុមគ្រីស្តទូតមកដល់សព្វថ្ងៃនេះតាមរយៈ "លោកអភិបាល"។ នេះនាំឲ្យយើងព្រះសហគមន៍មាន ភាពជាធ្លុងតែមួយ, ដ៏វិសុទ្ធ, សាកល និងបន្តជំនឿពីក្រុម គ្រីស្តទូត។ ព្រះសហគមន៍យើងឆ្លងកាត់បញ្ហាជាច្រើន ដូចជា មានការបាក់បែក មានរឿងអាស្រូវក្នុងព្រះសហគមន៍ រឿងការប្រើអំណាច ។ល។ ក៏ប៉ុន្តែព្រះសហគមន៍មានព្រះយេស៊ូជាសិរសា និងមានក្រុមគ្រីស្តទូតជាគ្រឹះ បានជាយើងនៅគង់វង្សរហូតដល់សព្វថ្ងៃនេះ។ ហេតុដូច្នេះហើយ យើងត្រូវ ទុកចិត្តលើការដឹកនាំរបស់ព្រះសហគមន៍កាតូលិក ដែលមានសម្តេចប៉ាបន ជាសិលាគ្រឹះដ៏សំខាន់។

# រូបភាពសកម្មភាពរបស់ព្រះសហគមន៍





លោកអភិបាលអូលីវីយេ ថ្មីតអីស្លែរ បានទទួលស្វាគមន៍ ដំណើរទស្សនកិច្ច និងជួបពិភាក្សាការងារជាមួយ Fr. Arturo Sosa, the Father General Superior of Jesuits (ប្រធានបព្វជិតសហជីវិនព្រះយេស៊ូ (ជេស្វីត) នៅមណ្ឌលសកម្មភាពភ្នំពេញថ្មី ។



ព្រះសហគមន៍កាតូលិកសន្ត ប៉ូល



ព្រះសហគមន៍កាតូលិក បាទី



ព្រះសហគមន៍កាតូលិក ត្រពាំងក្រញូង

## ដំណើរទស្សនកិច្ចរបស់លោកអភិបាល អូលីវីយេ ថ្មីតអីស្លែរ នៅមណ្ឌលសកម្មភាព តាកែវ



ព្រះសហគមន៍កាតូលិកសន្តី តេរេសា ព្រៃកប្បាស់



ព្រះសហគមន៍កាតូលិក ព្រះត្រៃឯក គិរីវង់



អង្គការបុត្រីមេត្តាករុណា ក្រុងដូនកែវ ខេត្តតាកែវ


Radio Veritas Asia

Khmer Service

RADIO VERITAS ASIA-KHMER SERVICE

# វិទ្យុវ៉ារីតាស់អាស៊ីខេមរភាសា

## សំលេងពីព្រះសហគមន៍កាតូលិកកម្ពុជា

### ✤ ផ្សាយតាមរលកធាតុអាកាស FM

| | | |
|---|---|---|
| ភ្នំពេញ | : FM 104 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : FM 91.0 Mhz | ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| សៀមរាប | : FM 98.75 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| កំពង់ធំ | : FM 102.5 Mhz | ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| កំពង់ចាម | : FM 100.5 Mhz | ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : FM 100.5 Mhz | ម៉ោង ៦:០០- ៧:០០ រាល់ថ្ងៃ |
| កំពត | : FM 93.25 Mhz | ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

### ✤ ផ្សាយតាមរលកធាតុអាកាសខ្លី (SW)

ជាភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃពីម៉ោង ៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

### ✤ តាមប្រព័ន្ធអ៊ីនធឺណែត ២៤ម៉ោង

លោកអ្នកអាចស្តាប់កម្មវិធីវិទ្យុវ៉ារីតាស់អាស៊ីជាភាសាខ្មែរ ២៤ម៉ោង តាមរយៈទូរស័ព្ទ **Smart Phone** ដែលប្រើប្រព័ន្ធ **Android** ឬប្រព័ន្ធ **IOS** ដោយគ្រាន់តែចូលទៅកាន់ **Play Store** ឬ **App Store** វាយពាក្យ **Radio Varitas Asia** រួច **Download** កម្មវិធីនោះដោយស្វែងរកប៊ូតុង **(Khmer Live Audio)** ។

Radio Varitas Asia

Khmer Live audio

ឬ តាមរយៈវេបសាយ៖ http://rvakhmer.com